រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

# របាយការណ៍សន្និបាតបូកសរុបការងារ ឆ្នាំ ២០១៩ និងទិសដៅ ឆ្នាំ២០២០









2020

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា
និងអធិការកិច្ច

# របាយការណ៍
# បូកសរុបលទ្ធផលការងារឆ្នាំ២០១៩
# និងទិសដៅឆ្នាំ២០២០
# របស់
# ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា
# និងអធិការកិច្ច

ឆ្នាំ ២០២០

# មាតិកា


**ក. សេចក្ដីផ្ដើម** ........ 1
**ខ. សមិទ្ធផលការងារ** ........ 1
១. រដ្ឋបាលកិច្ចការទូទៅ ........ 1
១.១. រដ្ឋបាល ........ 1
១.២. បុគ្គលិក និងធនធានមនុស្ស ........ 3
១.៣. ការបណ្ដុះបណ្ដាល ........ 4
១.៤. ហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ........ 4
១.៥. ផែនការ និងស្ថិតិ ........ 5
១.៦. សហប្រតិបត្តិការអន្តរជាតិ ........ 6
២. ការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា ........ 8
២.១. នីតិកម្ម ........ 8
២.២. ការអប់រំ ផ្សព្វផ្សាយច្បាប់ ........ 9
២.៣. ទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល ........ 10
២.៤. ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា ........ 10
២.៥. ទំនាក់ទំនងជាមួយប្រជាពលរដ្ឋ ........ 10
៣. សកម្មភាពការងារអធិការកិច្ច ........ 10
៣.១. អធិការកិច្ចទី ១ លើវិស័យសេដ្ឋកិច្ច ........ 10
៣.២. អធិការកិច្ចទី ២ លើវិស័យរដ្ឋបាលទូទៅ ........ 10
៣.៣. អធិការកិច្ចទី ៣ លើវិស័យសង្គមកិច្ច ........ 11
៣.៤. ការតាមដានការអនុវត្តច្បាប់ ........ 11
៣.៥. ការទទួលពាក្យបណ្ដឹង និងអង្កេតស្រាវជ្រាវ ........ 13
៣.៦. លទ្ធផលការងារអធិការកិច្ច ........ 14
៤. សវនកម្មផ្ទៃក្នុង ........ 25
៥. វិទ្យាស្ថានជាតិអធិការកិច្ច ........ 26
៦. ការងារផ្សេងទៀត ........ 27
៦.១ យេនឌ័រ ........ 27
៦.២. ការចងសម្ព័ន្ធមេត្រីភាព ........ 28
៦.៣. ការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មាន ........ 29
៦.៤. អ្នកនាំពាក្យក្រសួង ........ 29
៦.៥. ការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ........ 29
**គ. ការប្រឈម** ........ 30

១. ការប្រឈមក្នុងផ្នែករដ្ឋបាល កិច្ចការទូទៅ ........ 30
២. ការប្រឈមក្នុងផ្នែកទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា ........ 30
៣. ការប្រឈមក្នុងផ្នែកអធិការកិច្ច ........ 31
**ឃ. ទិសដៅការងារបន្ត** ........ 31
១.រដ្ឋបាលកិច្ចការទូទៅ ........ 31
១.១. រដ្ឋបាល ........ 31
១.២. បុគ្គលិក និងធនធានមនុស្ស ........ 32
១.៣. ហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ........ 32
១.៤. ផែនការ និងស្ថិតិ ........ 33
១.៥. សហប្រតិបត្តិការអន្តរជាតិ ........ 33
២. ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា ........ 33
២.១. នីតិកម្ម ........ 33
២.២. ការអប់រំផ្សព្វផ្សាយច្បាប់ ........ 34
២.៣. ទំនាក់ទំនងរវាងរាជរដ្ឋាភិបាល និងរដ្ឋសភា-ព្រឹទ្ធសភា ........ 34
៣. អធិការកិច្ច ........ 34
៣.១. អធិការកិច្ច (លើវិស័យសេដ្ឋកិច្ច រដ្ឋបាលទូទៅ និង សង្គមកិច្ច) ........ 34
៣.២.ការតាមដានការអនុវត្តច្បាប់ ........ 35
៣.៣. ការទទួលពាក្យបណ្ដឹង និងអង្កេតស្រាវជ្រាវ ........ 35
៣.៤.ការពង្រឹងស្ថាប័ន និងគ្រប់គ្រងមន្ត្រីរាជការ ........ 35
៤.សវនកម្មផ្ទៃក្នុង ........ 35
៥. វិទ្យាស្ថានជាតិអធិការកិច្ច ........ 36
៦. ការងារផ្សេងៗ ........ 37
៦.១. យេនឌ័រ ........ 37
៦.២.ការចងសម្ព័ន្ធមេត្រីភាព ........ 38
៦.៣. ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ........ 38
**ង.សេចក្ដីសន្និដ្ឋាន** ........ 38
**ឧបសម្ព័ន្ធ ១. កម្មវិធីសន្និបាត** ........ 40
**ឧបសម្ព័ន្ធ ២. របាយការណ៍សង្ខេបការងារ ២០១៩-២០២០** ........ 43
**ឧបសម្ព័ន្ធ ៣. របាយការណ៍បូកសរុបសន្និបាត** ........ 57
**ឧបសម្ព័ន្ធ ៤. សុន្ទរកថា បើកសន្និបាត** ........ 60
**ឧបសម្ព័ន្ធ ៥. សុន្ទរកថាបិទសន្និបាត** ........ 66

# ក. សេចក្ដីផ្ដើម

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ភ្លឺស្វាង និងចក្ខុវិស័យ ដ៏វែងឆ្ងាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** រាជរដ្ឋាភិបាលកម្ពុជាបានដឹកនាំប្រទេសឱ្យទទួលបានសេចក្ដីសុខសន្តិភាព កិត្យានុភាព និងការអភិវឌ្ឍន៍លើគ្រប់វិស័យ។ កម្ពុជាដែលធ្លាប់ជាសមរភូមិ នៃការប្រទាញប្រទង់ពីសំណាក់មហាអំណាច ក្នុងភូមិសាស្ត្រនយោបាយ ជាវាលពិឃាត នៃរបបប្រល័យពូជសាសន៍ និងជាប់ផុងក្នុងសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃបានប្រែក្លាយទៅជាប្រទេសមួយ ដែលមានទីផ្សារសេរីបើកចំហរ ស្វាគមន៍វិនិយោគបរទេស ដ៏ទាក់ទាញ ជារម្មណីយដ្ឋាន និងទីផ្សារទេសចរណ៍ដ៏ល្បីល្បាញលំដាប់ពិភពលោក និងមានមោទនភាពជាតិស្មើមុខស្មើមាត់ជាមួយប្រទេសនានាលើពិភពលោក។

ដោយមានយុទ្ធសាស្ត្រ និងផែនការច្បាស់លាស់ រាជរដ្ឋាភិបាលកម្ពុជា បានប្រកាន់យករបបនយោបាយតាមបែបប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបសេដ្ឋកិច្ចបែបទីផ្សារសេរី និងបើកចំហ ដោយធ្វើការកែទម្រង់គ្រប់ជ្រុងជ្រោយ និងស៊ីជម្រៅ និងដាក់ចេញផែនការ និងគោលនយោបាយប្រទាក់ក្រឡាគ្នាជាច្រើន ជាពិសេសយុទ្ធសាស្ត្រចតុកោណ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងបានធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងតំបន់ និងពិភពលោក។

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាលបានអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម ក្នុងការងារចំបង គឺការទំនាក់ទំនងសម្របសម្រួលរវាងរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា ការចូលរួមតាក់តែង សេចក្ដីព្រាងច្បាប់ការអប់រំផ្សព្វផ្សាយច្បាប់ ការទទួល និងដោះស្រាយពាក្យបណ្ដឹង របស់ប្រជាពលរដ្ឋ ការតាមដានការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា និងធ្វើអធិការកិច្ចលើគ្រប់វិស័យ សំដៅបង្ការ ទប់ស្កាត់ កែលម្អ និងមានវិធានការ ដើម្បីប្រឆាំងនឹងអំពើពុករលួយ ការរំលោភដោយអំណាច និងបាតុភាពអសកម្មនានា ដើម្បីពង្រឹងអភិបាលកិច្ចល្អ ការពារសិទ្ធិរបស់ប្រជាពលរដ្ឋ និងការពារសុវត្ថិភាពសាធារណៈ និងរួមចំណែកដល់ការអភិវឌ្ឍន៍ សេដ្ឋកិច្ច សង្គម។

ក្នុងឆ្នាំ២០១៩ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចសម្រេចបាននូវសមិទ្ធផលនានា ជាច្រើនដូចរៀបរាប់ខាងក្រោម៖

# ខ. សមិទ្ធផលការងារ

## ១. រដ្ឋបាលកិច្ចការទូទៅ

### ១.១. រដ្ឋបាល

នាយកដ្ឋានរដ្ឋបាល បានសម្រេចការងារដូចខាងក្រោម៖

-ទទួលលិខិតចូលពីក្រសួង-ស្ថាប័ននានាចំនួន៩៧១ច្បាប់ និងបញ្ជូនលិខិតចេញ ចំនួន១១៨៩ច្បាប់។

-ថតចម្លងរាល់លិខិតចេញ-ចូលក្នុងក្រសួង និងរៀបចំតម្កល់ទុកជាឯកសារ។

-ថតចម្លងរបាយការណ៍ប្រចាំឆ្នាំ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចាប់ពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០១៨ ជូនថ្នាក់ដឹកនាំក្រសួង។

-ចុះទំនាក់ទំនងជាមួយបណ្ណសារដ្ឋានជាតិ ដើម្បីស្រាវជ្រាវឯកសារពាក់ព័ន្ធនឹងរដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយសភា និងបានថតចម្លងឯកសារដែលពាក់ព័ន្ធនឹងរដ្ឋលេខាធិការដ្ឋានទំនាក់ទំនងសភា ដើម្បីតម្កល់ទុកជាឯកសារ។

-រៀបចំតាំងបដាពាក្យស្លោក ទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ ក្នុងពិធីបុណ្យជាតិ-អន្តរជាតិ នៅទីស្តីការក្រសួង។

-រៀបចំសារលិខិតថ្វាយព្រះពរព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថសីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល និងធ្វើសារលិខិតជូនពរថ្នាក់ដឹកនាំជាន់ខ្ពស់របស់ជាតិ ក្នុងពិធីបុណ្យជាតិ-អន្តរជាតិ។

-រៀបចំពិធីទទួលជួបសវនាការការងារ រវាងថ្នាក់ដឹកនាំក្រសួងជាមួយគណៈប្រតិភូបរទេស និងឯកឧត្តមឯកអគ្គរាជទូតមួយចំនួន នៅទីស្តីការក្រសួង។

-រៀបចំប្រជុំតាមកម្មវិធីប្រជុំរបស់ថ្នាក់ដឹកនាំក្រសួង នៅទីស្តីការក្រសួង។

-រៀបចំធ្វើអត្តសញ្ញាណបណ្ណជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការចំនួន២៥៩រូប និងបន្តធ្វើជាប្រចាំ។

-រៀបចំលិខិតបង្គាប់ការចាត់មន្ត្រីរាជការ ចូលរួមពិធីបុណ្យជាតិ-អន្តរជាតិ និងទទួល-ជូនដំណើរគណៈប្រតិភូជាន់ខ្ពស់បរទេស មកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា។

-រៀបចំបូកសរុបរបាយការណ៍របស់អគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ និងរបាយការណ៍ក្រសួងប្រចាំខែ ត្រីមាស ឆមាស រយៈពេល៩ខែ និងប្រចាំឆ្នាំសម្រាប់ជូនទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងផែនការ។

-គ្រប់គ្រង ពិនិត្យតាមដានជាប្រចាំនូវការសរសេរ និងរូបថត សរសេរខ្លឹមសារ និងថតសកម្មភាពការងារថ្នាក់ដឹកនាំ និងមន្ត្រីរាជការបញ្ចូលក្នុងគេហទំព័រផ្លូវការរបស់ក្រសួង www.monasri.gov.kh ។

-ត្រួតពិនិត្យ និងថែទាំម៉ាស៊ីនមេ (Server) និងស្រាវជ្រាវឯកសារពាក់ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍។

-តាមដានរាល់សកម្មភាពព័ត៌មានដែលចេញតាមវិបសាយក្រសួង និងតាមប្រព័ន្ធ Facebook page។

-ចូលរួមពិធីបុណ្យជាតិ-អន្តរជាតិ ពិធីប្រកាសចូលកាន់មុខតំណែង សន្និបាតបូកសរុបលទ្ធផលការងារ សិក្ខាសាលា មីទ្ទីញ ពិធីសម្ពោធវិមានអនុស្សាវរីយ៍ សម្ពោធការតាំងពិព័រណ៍ វគ្គផ្សព្វផ្សាយ ទទួល-ជូនដំណើរគណៈប្រតិភូជាន់ខ្ពស់បរទេស និងចុះសួរសុខទុក្ខកងកម្លាំងប្រដាប់អាវុធ ដែលឈរជើងការពារព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រខេត្តកោះកុង។

-ចូលរួមប្រជុំស្តីពីការត្រៀមលក្ខណៈរៀបចំពិធីបុណ្យជាតិ-អន្តរជាតិ និងការត្រៀមលក្ខណៈទទួល-ជូនដំណើរ គណៈប្រតិភូជាន់ខ្ពស់បរទេស នៅគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិចំនួន១០លើក។

## ១.២. បុគ្គលិក និងធនធានមនុស្ស

នាយកដ្ឋានបុគ្គលិក និងធនធានមនុស្សបានបំពេញការងារ ដូចខាងក្រោម៖

-ធ្វើសេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មការតាំងស៊ប់បំពេញសិទ្ធិ នៅក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការ។

-ធ្វើសេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មការដំឡើងឋានន្តរស័ក្តិ ថ្នាក់ជូនមន្ត្រីរាជការប្រចាំឆ្នាំ ២០២០។

-ធ្វើសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមប្រឹក្សាវិន័យ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-ធ្វើប្រកាស ស្តីពីការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជម្ងឺអេដស៍ នៅក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-ធ្វើលិខិតបង្គាប់ការ ស្តីពីការចាត់តាំងមន្ត្រីរាជការ ចូលរួមក្នុងកម្មវិធីនាទី ព្រះពុទ្ធសាសនា ផ្សារភ្ជាប់នឹងសង្គម។

-ធ្វើប្រកាស ស្តីពីការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន៥០រូប ជាជំនួយការក្រសួងចំនួន១រូប ជំនួយការរដ្ឋលេខាធិការចំនួន១រូប នាយករងវិទ្យាស្ថានជាតិអធិការកិច្ចចំនួន១រូប អនុប្រធាននាយកដ្ឋានចំនួន១២រូប ប្រធានមន្ទីរចំនួន៣រូប ប្រធានការិយាល័យចំនួន៩រូប និងអនុប្រធានការិយាល័យចំនួន២៣រូប។

-ធ្វើប្រកាស ស្តីពីការទទួលក្របខ័ណ្ឌមន្ត្រីរាជការចំនួន១៣រូប ពីក្រសួងអប់រំ យុវជន និងកីឡាចំនួន៥រូប ពីទីស្តីការគណៈរដ្ឋមន្ត្រីចំនួន៤រូប ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន២រូប ពីក្រសួងសាធារណការ និងដឹកជញ្ជូនចំនួន១រូប និងពីក្រសួងទេសចរណ៍ចំនួន១រូប ឱ្យមកបម្រើការងារក្នុង ក្របខ័ណ្ឌក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-ធ្វើប្រកាស ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការចំនួន១១រូប ពីក្របខ័ណ្ឌក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឱ្យទៅបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃចំនួន៣រូប ក្របខ័ណ្ឌគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចំនួន៣រូប ក្របខ័ណ្ឌក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចំនួន១រូប ក្របខ័ណ្ឌក្រសួងបរិស្ថានចំនួន១រូប ក្របខ័ណ្ឌក្រសួងមុខងារសាធារណៈចំនួន១រូប ក្របខ័ណ្ឌក្រសួងពាណិជ្ជកម្មចំនួន១រូប និងក្របខ័ណ្ឌក្រសួងយុត្តិធម៌ចំនួន១រូប។

-ធ្វើប្រកាសស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការចំនួន៦រូប ពីវិទ្យាស្ថានជាតិអធិការកិច្ចចំនួន ២រូបឱ្យទៅបម្រើការងារនៅនាយកដ្ឋានផែនការ និងនាយកដ្ឋានតាមដានការអនុវត្តច្បាប់ ពីនាយកដ្ឋានរដ្ឋបាលចំនួន ១រូបឱ្យទៅបម្រើការងារ នៅនាយកដ្ឋានតាមដានការអនុវត្តច្បាប់ ពីមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តមណ្ឌលគិរីចំនួន១រូបឱ្យទៅបម្រើការងារ នៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តត្បូងឃ្មុំ ពីមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តស្វាយរៀងចំនួន១រូប ឱ្យទៅបម្រើការងារ នៅនាយកដ្ឋានតាមដានការអនុវត្តច្បាប់ និងពីមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចព្រៃវែងចំនួន១រូបឱ្យទៅបម្រើការងារនៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តសៀមរាប។

-ធ្វើប្រកាសស្តីពីការលុបឈ្មោះមន្ត្រីរាជការចំនួន៦រូប ពីក្របខ័ណ្ឌក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដោយលាឈប់ពីការងារចំនួន៥រូប និងទទួលមរណភាពចំនួន១រូប។

-ធ្វើប្រកាសស្តីពីការដាក់មន្ត្រីរាជការចំនួន២រូប ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស។

-ធ្វើប្រកាសស្តីពីការផ្លាស់ប្តូរមន្ត្រីជាប់កិច្ចសន្យាចំនួន២រូប ឱ្យបម្រើការងារនៅទីស្តីការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

## ១.៣. ការបណ្តុះបណ្តាល

ក្នុងការបណ្តុះបណ្តាល ក្រសួងបានបំពេញការងារដូចខាងក្រោម៖

-បណ្តុះបណ្តាលជំនាញអធិការកិច្ចបឋមជូនមន្ត្រីរាជការចំនួន៣២៧រូបស្តីពីមូលដ្ឋានគ្រឹះនៃការងារអធិការកិច្ច គណនេយ្យ ការគ្រប់គ្រងការងាររដ្ឋបាល និងសវនកម្ម នៅទីស្តីការក្រសួង។

-ចាត់បញ្ជូនមន្ត្រីរាជការចំនួន៥រូបទៅបណ្តុះបណ្តាលភាសាចិន នៅសាធារណរដ្ឋប្រជាមានិតចិន។

-ចាត់បញ្ជូនមន្ត្រីរាជការចំនួន២រូបទៅបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ និងរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល(ករស)តាមអនឡាញ នៅសណ្ឋាគារអង្គរប៉ារ៉ាឌី ខេត្តសៀមរាប។

-ចាត់បញ្ជូនមន្ត្រីរាជការចំនួន៣រូប ទៅសិក្សាកម្រិតថ្នាក់បរិញ្ញាបត្រ និងថ្នាក់អនុបណ្ឌិត នៅសាកលវិទ្យាល័យឯកទេសកម្ពុជាសាខាខេត្តបាត់ដំបង។

-ចាត់បញ្ជូនមន្ត្រីរាជការចំនួន១៣រូប ទៅបណ្តុះបណ្តាលស្តីពីជំនាញបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-ចាត់បញ្ជូនមន្ត្រីរាជការចំនួន៤រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីវគ្គថ្នាលថ្មី នៃកម្មវិធីអភិវឌ្ឍភាពជាអ្នកដឹកនាំនយោបាយ នៅអាគារខេមរានី វិថីវិចិត្រសិល្បៈ។

## ១.៤. ហិរញ្ញវត្ថុ និងផ្គត់ផ្គង់

ក្រសួងបានបំពេញការងារដូចខាងក្រោម៖

-ទាក់ទងការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារជាតិ និងធនាគារជាតិ ក្នុងកិច្ចការស្នើសុំថវិកានានាតាមខ្ទង់ជំពូក ដើម្បីបម្រើការងារក្រសួងឱ្យដំណើរការល្អប្រសើរ ដូចជាថវិកាសម្រាប់បៀវត្ស ដំណើរការរដ្ឋបាលទូទៅ បេសកកម្មក្នុងប្រទេស និងក្រៅប្រទេស។

-កែសម្រួលក្រុមការងារកែទម្រង់ ហិរញ្ញវត្ថុសាធារណៈ និងបង្កើតលេខាធិការដ្ឋាន នៃក្រុមការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈក្រសួង។ ក្រុមការងារបានបំពេញភារកិច្ចយ៉ាងសកម្ម ជាពិសេសក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានលេខាធិការដ្ឋាន នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធ្វើការជាមួយក្រុមការងារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) ដែលប្រព័ន្ធនោះនឹងត្រូវតម្លើងនៅក្រសួងនៅឆ្នាំ២០២០។

-ក្រុមការងារកែទម្រង់ ហិរញ្ញវត្ថុសាធារណៈរួមនឹងថ្នាក់ដឹកនាំ អង្គភាពថវិកាទាំងអស់ក្នុងក្រសួងបានចូលរួមសិក្ខាសាលាផ្សព្វផ្សាយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ(FMIS) និងការណែនាំសម្រាប់អនាគត ដែលធ្វើបទបង្ហាញ និងឆ្លើយសំណួរ ដោយក្រុមការងារមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ បានរៀបចំរបាយការណ៍ប្រៀបធៀបផែនការចំណាយ តាមកម្មវិធីប្រចាំត្រីមាស និងការអនុវត្តជាក់ស្តែងដោយឆ្លុះបញ្ចាំងនូវគោលដៅចំណាយក្នុងត្រីមាសនីមួយៗ ក្រុមការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈក្រសួងបានជួបពិភាក្សាការងារ ជាមួយអគ្គលេខាធិការរង នៃអគ្គលេខាធិការ នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ នៅទីស្តីការក្រសួង។

-ផ្សព្វផ្សាយព័ត៌មាន ស្តីពីលទ្ធកម្មសាធារណៈ តាមរយៈកាសែតដែលផ្សព្វផ្សាយកិច្ចលទ្ធកម្មសាធារណៈ ដល់អ្នកដេញថ្លៃ និងក្រុមលទ្ធកម្មត្រៀមអនុវត្តសេចក្តីជូននិងសារាចរណែនាំស្តីពីការត្រៀមរៀបចំផែនការ យុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២។

## ១.៥. ផែនការ និងស្ថិតិ

នាយកដ្ឋានផែនការ និងស្ថិតិបានបំពេញការងារដូចខាងក្រោម៖

-រៀបចំធ្វើផែនការកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០២០-២០២២ របស់ក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចមានចំនួន ៧ គម្រោងសម្រាប់ដាក់ជូនថ្នាក់ដឹកនាំពិនិត្យ-សម្រេចដើម្បីផ្ញើជូនក្រសួងផែនការ។

-រៀបចំពង្រាងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ របស់នាយកដ្ឋានផែនការ និងស្ថិតិ។

-រៀបចំរបាយការណ៍វឌ្ឍនភាពលទ្ធផលសម្រេចបានឆ្នាំ២០១៦-២០១៨ សម្រាប់ជាធាតុចូលស្តីពីការរៀបចំរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិ ដោយស្ម័គ្រចិត្ត ឆ្នាំ២០១៩ ស្តីពីការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០។

-រៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ឆ្នាំ២០២០-២០២២ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បញ្ជូនទៅក្រសួងផែនការ។

-រៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-ទំនាក់ទំនងជាមួយមន្ត្រីជំនាញ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីសារាចរណែនាំរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២។

-បញ្ចូលតារាងតាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ តាមអគ្គនាយកដ្ឋានទាំង៣ និងតាមមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្ត។

-ចូលរួមពិធីផ្សព្វផ្សាយក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០ (ថ្នាក់ជាតិ) នៅសណ្ឋាគារភ្នំពេញ។

-ចូលរួមពិធីប្រកាសផ្សព្វផ្សាយការដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) ២០១៩-២០២៣ នៅសណ្ឋាគារសុខាភ្នំពេញ។

-ធ្វើស្ថិតិផ្លូវការដែលមានការចាត់តាំងតាមវិស័យ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចប្រចាំឆ្នាំ២០១៨ ទៅវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងទីស្តីការគណៈរដ្ឋមន្ត្រី។

-រៀបចំគម្រោងថវិការដ្ឋសម្រាប់គ្រប់គ្រងឆ្នាំ២០២០ រដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី-ខេត្ត ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-កែសម្រួលបច្ចុប្បន្នភាពស្ថិតិទូទៅរបស់ក្រសួង និងបម្រែបម្រួលមន្ត្រីរាជការតាមនាយកដ្ឋាននីមួយៗ ព្រមទាំងថ្នាក់មន្ទីររាជធានី-ខេត្ត។

-រៀបចំលិខិតស្នើសុំផ្តល់របាយការណ៍សមិទ្ធកម្ម ស្តីពីលទ្ធផល នៃការអនុវត្តថវិកាឆមាសទី១ ឆ្នាំ ២០១៩ ពីអង្គភាពក្រោមឱវាទក្រសួង ដើម្បីធ្វើការបូកសរុបផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-រៀបចំកែសម្រួលកម្រិតបច្ចេកទេសគម្រោងផែនការថវិការដ្ឋ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-ចូលរួមពិនិត្យ និងពិភាក្សាកែសម្រួលចំណាត់ថ្នាក់រដ្ឋបាល នៃមាតិកាថវិការដ្ឋបាលថ្នាក់ជាតិ និងក្រោមជាតិ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-ផ្តល់គំរូសម្រាប់របាយការណ៍ស្ថិតិផ្លូវការ តាមការចាត់តាំងតាមវិស័យរបស់ក្រសួង ទៅគ្រប់នាយកដ្ឋានក្រោមឱវាទក្រសួង។

-ទទួលទិន្នន័យស្ថិតិផ្លូវការ ពីនាយកដ្ឋានមួយចំនួនដូចជា នាយកដ្ឋានអប់រំផ្សព្វផ្សាយច្បាប់ នាយកដ្ឋានអធិការកិច្ចទី១ នាយកដ្ឋានអធិការកិច្ចទី២ នាយកដ្ឋានទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ និងនាយកដ្ឋាននីតិកម្ម។

-ស្រង់ទិន្នន័យតាមនាយកដ្ឋានជាបណ្តើរៗ និងរង់ចាំទិន្នន័យនៅសល់មិនទាន់ផ្តល់ឱ្យសរុបជាបន្តបន្ទាប់ និងត្រៀមរៀបចំដាក់ជូនថ្នាក់ដឹកនាំពិនិត្យ-សម្រេច និងផ្តល់របាយការណ៍ទៅក្រសួងផែនការ វិទ្យាស្ថានជាតិស្ថិតិ និងទីស្តីការគណៈរដ្ឋមន្ត្រីឱ្យទាន់ពេលវេលា។

-ទទួលទិន្នន័យស្ថិតិផ្លូវការដែលបានចាត់តាំងតាមវិស័យរបស់ក្រសួង ពីបណ្តានាយកដ្ឋាននៅថ្នាក់កណ្តាលរួចរាល់។

-បញ្ចប់ការចងក្រងស្ថិតិផ្លូវការរួចរាល់ និងត្រៀមផ្ញើជូនក្រសួងផែនការ និងទីស្តីការគណៈរដ្ឋមន្ត្រី។

-ចូលរួមសិក្ខាសាលា ស្តីពីការរៀបចំរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិ ដោយស្ម័គ្រចិត្ត ឆ្នាំ២០១៩ ស្តីថពីការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០ នៅសណ្ឋាគារភ្នំពេញ។

-ចូលរួមសិក្ខាសាលាអន្តរក្រសួងលើកទី១ ស្តីពីការកសាងផែនការមេជាតិ ស្តីពីហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ ឆ្នាំ២០២០-២០២៥ នៅកម្ពុជា។

-ចូលរួមសិក្ខាសាលាអន្តរក្រសួង ស្តីពីការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិប្រជាជន ឆ្នាំ២០១៦-២០៣០ សម្រាប់ឆ្នាំ២០១៩។

-ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីដំណើររបស់កម្ពុជាឆ្ពោះទៅសន្និសីទកំពូលក្រុងណៃរ៉ូប៊ី (សន្និសីទអន្តរជាតិស្តីពីប្រជាជន និងការអភិវឌ្ឍន៍ ក្រោយពេល២៥ឆ្នាំ International Conference on Population and Development, ICPD+25) ។

-ចូលរួមសិក្ខាសាលាអន្តរក្រសួង ស្តីពីសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាព ឆ្នាំ២០១៦-២០១៩ នៃគោលនយោបាយជាតិប្រជាជន ឆ្នាំ២០១៦-២០៣០។

-បានរៀបចំប្រជុំ និងចូលរួមប្រជុំ ចំនួន១៣លើក។

## ១.៦. សហប្រតិបត្តិការអន្តរជាតិ

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ បានសម្រេចការងារដូចខាងក្រោម៖

-អមលោកជំទាវឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីដើម្បីទទួលជួបសវនាការការងារជាមួយ៖

- ឯកឧត្តម **ត្រឹន ភីមទួ** លេខាធិការមជ្ឈិមបក្ស និងជាប្រធានគណៈត្រួតពិនិត្យមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម
- ឯកឧត្តម **វ៉ាង ទិនឆាន** ឯកអគ្គរដ្ឋទូតសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា
- គណៈប្រតិភូសភាបារាំង ដឹកនាំដោយឯកឧត្តម **ហ្វ្រង់ស័រ ក្រូសឌីឌីយេ** (Fancois Crosdidier )
- ឯកឧត្តមឯក ឯកឧត្តម **អែលឌីន ហូសេនី ប៊ីន ម៉ូដ ហាសស៊ីម** អគ្គរាជទូតម៉ាឡេស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា
- លោក **រ៉ូស៊ីល អិម ណិលសុន** (Russell M. Nelson) ប្រធានសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយសកលលោក
- លោកជំទាវឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុប និងឯកឧត្តម **ឡេ ជុនមី៉** អនុប្រធានសភានៃខេត្តហ្វូជៀន សាធារណរដ្ឋប្រជាមានិតចិន នៅទីស្តីការក្រសួង។

-ចូលរួមពិធីទទួល និងជូនដំណើរគណៈប្រតិភូជាន់ខ្ពស់ដឹកនាំដោយឯកឧត្តម NGUYEN PHU TRONG អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម និងជាប្រធានរដ្ឋសាធារណរដ្ឋសង្គមនិយមវៀតណាម និងគណៈប្រតិភូ ជាន់ខ្ពស់ដឹកនាំដោយឯកឧត្តម **មូន ចេអ៊ីន** ប្រធានាធិបតីនៃសាធារណរដ្ឋកូរ៉េ នៅមុខព្រះបរមរាជវាំង។

-ទទួលជួបសម្តែងការគួរសមជាមួយឯកឧត្តម **វុ ចៀនថាំង** ប្រធានគណៈកម្មាធិការសាសនារដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

-ទំនាក់ទំនងជាមួយស្ថានទូត នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងស្ថាប័នពាក់ព័ន្ធដើម្បីត្រៀមទទួលគណៈប្រតិភូជាន់ខ្ពស់អធិការកិច្ចរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម មកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា។

-ទំនាក់ទំនងជាមួយភាគីវៀតណាម ស្តីពីដំណើរទស្សនកិច្ចរបស់គណៈប្រតិភូក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅសាធារណរដ្ឋសង្គមនិយមវៀតណាម។

-ទំនាក់ទំនងសម្របសម្រួលជាមួយវិទ្យាស្ថានខុងជឺ រាជបណ្ឌិតសភាកម្ពុជា ក្នុងការបញ្ជូនសិក្ខាកាមចំនួន៥រូបទៅសិក្សានៅសាធារណរដ្ឋប្រជាមានិតចិន រយៈពេល១០ខែ។

-បញ្ជូនលោកស្រី សូ ណារ៉េន អគ្គនាយករងនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដើម្បីចូលរួមក្នុងកម្មវិធីទស្សនកិច្ចសិក្សា នៅសាធារណរដ្ឋប្រជាមានិតចិន រយៈពេល៨ថ្ងៃ។

-ចូលរួមកិច្ចប្រជុំកំពូលអាស៊ីប៉ាស៊ីហ្វិក ឆ្នាំ២០១៩ នៅកម្ពុជា ស្តីពីកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងសង្គមស៊ីវិល នៅទីស្តីការគណៈរដ្ឋមន្ត្រី។

-រៀបចំសំណើសុំការអនុញ្ញាតទទួលគណៈប្រតិភូអធិការកិច្ច រដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម មកបំពេញទស្សនកិច្ច នៅព្រះរាជាណាចក្រកម្ពុជា។

-រៀបចំដំណើរទស្សនកិច្ចគណៈប្រតិភូជាន់ខ្ពស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចទៅបំពេញទស្សនកិច្ច នៅសាធារណរដ្ឋប្រជាមានិតចិន។

-រៀបចំសម្របសម្រួលបញ្ជូនសិក្ខាកាមដែលទៅសិក្សាភាសាចិន នៅសាធារណរដ្ឋប្រជាមានិតចិន រយៈពេល១០ខែ។

-រៀបចំសម្របសម្រួលជូន និងទទួលគណៈប្រតិភូក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចទៅបំពេញទស្សនកិច្ច នៅសាធារណរដ្ឋសង្គមនិយមវៀតណាម។

-រៀបចំបដិសណ្ឋារកិច្ច និងជួបប្រជុំជាមួយគណៈប្រតិភូជាន់ខ្ពស់វៀតណាម ដឹកនាំដោយឯកឧត្តម **វឿង ហ៊័ងមិញ** ឧបនាយករដ្ឋមន្ត្រីប្រចាំការនៃសាធារណរដ្ឋសង្គមនិយមវៀតណាម មកបំពេញទស្សនកិច្ចផ្លូវការ នៅព្រះរាណាចក្រកម្ពុជា។

# ២. ការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

## ២.១. នីតិកម្ម

នាយកដ្ឋាននីតិកម្មបានបំពេញការងារដូចខាងក្រោមៈ

-រៀបចំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច នៅទីស្តីការក្រសួងចំនួន ៣៨លើក។

-រៀបចំកិច្ចប្រជុំឆ្លងសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច នៅទីស្តីការក្រសួងចំនួន១លើក។

-ចូលរួមការពារសេចក្តីព្រាងច្បាប់ ស្តីពីអធិការកិច្ចក្នុងកិច្ចប្រជុំជំនាញបច្ចេកទេស នៅទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន៦លើក។

-ចូលរួមប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបណ្ណាសារ នៅទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន១លើក។

-ចូលរួមប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងសេវាសុខាភិបាល នៅក្រសួងសុខាភិបាល ចំនួន១លើក។

-ចូលរួមប្រជុំពិភាក្សា ស្តីពីក្រុមការងារទំនាក់ទំនងវិជ្ជាជីវៈជាមួយឯកជន នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន១លើក។

-ចូលរួមប្រជុំ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២០-២០២២ និងនីតិវិធីនៃការអនុវត្តថវិកាកម្មវិធី នៅទីស្តីការក្រសួង ចំនួន២លើក។

-ចូលរួមប្រជុំពិភាក្សា និងផ្តល់យោបល់លើគេហទំព័រថ្មី និងកម្មវិធី (Application) ថ្មីរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចំនួន១លើក។

-ចូលរួមសិក្ខាសាលា ស្តីពីការផ្សព្វផ្សាយសមិទ្ធផល១០ឆ្នាំ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងការអនុវត្តកម្មវិធីវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត នៅសណ្ឋាគារសុខាភ្នំពេញ ចំនួន១លើក។

-ចូលរួមវេទិកា ស្តីពីនីតិកម្ម និងការងារកែទម្រង់របស់រាជរដ្ឋាភិបាល ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅសណ្ឋាគារសុខាភ្នំពេញ ចំនួន១លើក។

-បញ្ជូនមន្ត្រីរាជការ ចំនួន៥រូប ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការកសាងសមត្ថភាពស្រាវជ្រាវ នៅវិទ្យាស្ថានជាតិអធិការកិច្ច ចំនួន១លើក។

-រៀបចំធ្វើបច្ចុប្បន្នភាព បណ្ណាល័យច្បាប់អេឡិចត្រូនិច http://www.cll-monasri.com/ ចំនួន១លើក។

-បញ្ចូលអត្ថបទច្បាប់ ចំនួន៤៩៨ច្បាប់ ទៅក្នុងបណ្ណាល័យច្បាប់អេឡិចត្រូនិច។

-បញ្ចូលលិខិតបទដ្ឋានគតិយុត្ត ចំនួន១៨៤លិខិត ទៅក្នុងបណ្ណាល័យច្បាប់អេឡិចត្រូនិច។

-ចូលរួមមូលនិធិគន្ធបុប្ផាកម្ពុជាជាសមាជិកគាំទ្ររយៈពេល១ឆ្នាំ ពីថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៩ ដល់ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២០។

-ចុះស្ទង់មតិប្រជាពលរដ្ឋ ស្តីពីការយល់ដឹងលើច្បាប់ភូមិបាល ចំនួន១០លើក នៅខេត្តស្វាយរៀង ចំនួន២លើក ព្រៃវែង ចំនួន២លើក សៀមរាប ចំនួន២លើក កំពង់ធំ ចំនួន២លើក និងខេត្តកែប ចំនួន២លើក ដោយមានអ្នកចូលរួម ចំនួន៩២៥នាក់ (ស្ត្រី ចំនួន៤៤៨ នាក់)។

-ចុះស្ទង់មតិប្រជាពលរដ្ឋ ស្តីពីការយល់ដឹងលើច្បាប់ចរាចរណ៍ផ្លូវគោក នៅខេត្តកំពង់ធំ ចំនួន៧លើក ដោយមានអ្នកចូលរួម ចំនួន៣៨៧នាក់ (ស្ត្រី ចំនួន៧៧នាក់)។

-ចុះស្ទង់មតិសិស្សានុសិស្ស ស្តីពីការយល់ដឹងលើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅខេត្តព្រះសីហនុចំនួន៤លើក ដោយមានអ្នកចូលរួម ចំនួន២២០នាក់ (ស្ត្រី ចំនួន១០៩នាក់)។

## ២.២. ការអប់រំ ផ្សព្វផ្សាយច្បាប់

ក្រសួងបានបំពេញភារកិច្ចដូចខាងក្រោម៖

-ចុះផ្សព្វផ្សាយច្បាប់ សរុបចំនួន១៤៤លើក ក្នុងនោះ អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា ចំនួន២៣លើក និងមន្ទីររាជធានី-ខេត្ត ចំនួន១២១លើក ដោយមានអ្នកចូលរួម សរុបចំនួន ៤៨ ២៤០នាក់ (ស្ត្រី ចំនួន១៩ ៣៧៦នាក់) និងបានទទួលសំណួរ ចំនួន៤ ៦៧៤សំណួរ។

-ច្បាប់ដែលផ្សព្វផ្សាយរួមមាន៖

- ស្តីពីចរាចរណ៍ផ្លូវគោក ចំនួន៧០លើក (ក្នុងខេត្តកំពង់ធំចំនួន១៣លើក ព្រះសីហនុ ចំនួន១០លើក ស្ទឹងត្រែង ចំនួន៩លើក កណ្តាល ចំនួន៨លើក ស្វាយរៀង ចំនួន៨លើក កំពង់ស្ពឺ ចំនួន៧លើក ព្រៃវែង ចំនួន៤លើក កំពង់ចាម ចំនួន៤លើក បាត់ដំបង ចំនួន៣លើក បន្ទាយមានជ័យ ចំនួន២លើក កំពត ចំនួន១លើក និងខេត្តកែប ចំនួន១លើក)។
- ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចំនួន៦៣លើក (ក្នុងខេត្តក្រចេះ ចំនួន២២លើក តាកែវ ចំនួន១១លើក កណ្តាល ចំនួន៥លើក ព្រះសីហនុ ចំនួន៥លើក ឧត្តរមានជ័យ ចំនួន ៤លើក កំពង់ចាម ចំនួន៣លើក ស្វាយរៀង ចំនួន៣លើក ត្បូងឃ្មុំ ចំនួន២លើក កំពត ចំនួន ២លើក កែប ចំនួន២លើក កំពង់ធំ ចំនួន២លើក ព្រៃវែង ចំនួន១លើក និងខេត្តសៀមរាប ចំនួន១លើក)។
- ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចំនួន៦លើក (ក្នុងខេត្តព្រៃវែងចំនួន៦លើក) ច្បាប់ស្តីពីជលផល ចំនួន៣លើក (ក្នុងខេត្តក្រចេះ ចំនួន៣លើក)។
- ច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ ជម្ងឺអេដស៍ ចំនួន១លើក (ក្នុងខេត្តកំពត ចំនួន១លើក) និង
- ច្បាប់ភូមិបាល ចំនួន១លើក (ក្នុងខេត្តសៀមរាប ចំនួន១លើក)។

### ២.៣. ទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល

ក្រសួងបានបញ្ជូនតំណាងឱ្យចូលរួមប្រជុំអន្តរក្រសួង នៅទីស្តីការគណៈរដ្ឋមន្ត្រី លើសេចក្តីព្រាងច្បាប់ ចំនួន១៧លើក សេចក្តីព្រាងអនុក្រឹត្យ ចំនួន១២លើក និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត ចំនួន១៧លើក។

### ២.៤. ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

ក្រសួងបានបញ្ជូនតំណាងឱ្យ៖

-ចូលរួមស្តាប់សម័យប្រជុំពេញអង្គរដ្ឋសភា ដើម្បីអនុម័តលើសេចក្តីស្នើច្បាប់ ចំនួន២លើក សេចក្តីព្រាងច្បាប់ ចំនួន២០លើក ការបោះឆ្នោតជ្រើសតាំង ចំនួន៤លើក ព្រះរាជសារ ចំនួន២លើក របាយការណ៍របស់រដ្ឋសភា ចំនួន២លើក និងការប្រកាសសុពលភាព ចំនួន១លើក។

-ចូលរួមអមដំណើរជាមួយគណៈកម្មការទី៧នៃរដ្ឋសភា ចំនួន២លើក។

-ចូលរួមស្តាប់សម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភា លើសេចក្តីស្នើច្បាប់ ចំនួន២លើក សេចក្តីព្រាងច្បាប់ចំនួន២០លើក ការប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី ចំនួន៤លើក និងការបោះឆ្នោតជ្រើសតាំង ចំនួន២លើក។

### ២.៥. ទំនាក់ទំនងជាមួយប្រជាពលរដ្ឋ

ក្រសួងបានរៀបចំវេទិកាសាធារណៈដើម្បីទទួលសំណូមពរពីប្រជាពលរដ្ឋ ចំនួន១០លើក នៅខេត្តបាត់ដំបងចំនួន២លើក កំពង់ចាម ចំនួន២លើក ព្រៃវែង ចំនួន២លើក កំពត ចំនួន២លើក និងខេត្តពោធិ៍សាត់ ចំនួន២លើក ដោយមានអ្នកចូលរួម ចំនួន២ ៦៥៦នាក់ (ស្ត្រី ចំនួន១ ១៨៥នាក់) និងបានទទួលសំណូមពរពីប្រជាពលរដ្ឋ ចំនួន២៧៣សំណូមពរ។

## ៣. សកម្មភាពការងារអធិការកិច្ច

### ៣.១. អធិការកិច្ចទី ១ លើវិស័យសេដ្ឋកិច្ច

នាយកដ្ឋានអធិការកិច្ចទី១ បានបំពេញការងារដូចខាងក្រោម៖

-ចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ២០១៨ និងបណ្តាឆ្នាំពាក់ព័ន្ធនៅក្រសួងចំនួន៩ អង្គភាពថ្នាក់ជាតិចំនួន២ និងមន្ទីរ-អង្គភាពក្នុង២៥រាជធានី-ខេត្ត ស្មើនឹង៣០៣មន្ទីរ- អង្គភាព។

-ធ្វើលិខិតជូនដំណឹងស្តីពីការជំរុញការកែលម្អចំណុចខ្វះខាតទៅក្រសួង-ស្ថាប័នរងអធិការកិច្ចចំនួន៦០ច្បាប់។

-ទទួលលិខិតឆ្លើយតប ស្តីពីការជំរុញការកែលម្អចំណុចខ្វះខាតពីក្រសួង-ស្ថាប័ន អង្គភាព ចំនួន៤ច្បាប់។

### ៣.២. អធិការកិច្ចទី ២ លើវិស័យរដ្ឋបាលទូទៅ

នាយកដ្ឋានអធិការកិច្ចទី ២បានបំពេញការងារដូចខាងក្រោម៖

-ចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ២០១៨ និងបណ្តាឆ្នាំពាក់ព័ន្ធនៅក្រសួង ចំនួន១ និងមន្ទីរ-អង្គភាពក្នុង២៣រាជធានី-ខេត្ត ស្មើនឹង២៣៧មន្ទីរ-អង្គភាព។

-ចុះទំនាក់ទំនង និងក្តាប់សភាពការការងារអធិការកិច្ចនៅក្រសួង ចំនួន១៤ គឺក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងព័ត៌មាន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសុខាភិបាល ក្រសួងរ៉ែ និងថាមពល ក្រសួងទេសចរណ៍ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងពាណិជ្ជកម្ម ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងកិច្ចការនារី។

-ទទួលរបាយការណ៍ និងលិខិតជូនជ្រាបពីក្រសួង ចំនួន១១ គឺ(១) ក្រសួងមុខងារសាធារណៈ លិខិតជូនជ្រាប ចំនួន២៧លើក (២) ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចំនួន២៤លើក ក្នុងនោះ របាយការណ៍ ចំនួន១៣លើក និងកំណត់ហេតុ ចំនួន១១លើក (៣) ក្រសួងការពារជាតិ ចំនួន១២លើក (៤) ក្រសួងមហាផ្ទៃចំនួន៧លើក (៥) ក្រសួងទេសចរណ៍ ចំនួន៦លើក (៦) ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំនួន៥លើក (៧) ក្រសួងពាណិជ្ជកម្ម ចំនួន២លើក (៨) ក្រសួងព័ត៌មាន ចំនួន២លើក (៩) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន១លើក (១០) ក្រសួងអប់រំ យុវជន និងកីឡា ចំនួន១លើក (១១) ក្រសួងធម្មការ និងសាសនា ចំនួន១លើក។

## ៣.៣. អធិការកិច្ចទី ៣ លើវិស័យសង្គមកិច្ច

នាយកដ្ឋានអធិការកិច្ចទី ៣ បានបំពេញការងារដូចខាងក្រោម៖

-ចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ ២០១៨ និងបណ្តាឆ្នាំពាក់ព័ន្ធនៅក្រសួង ចំនួន៧ និងមន្ទីរ-អង្គភាពក្នុង២៥រាជធានី-ខេត្ត ស្មើនឹង២៣០ មន្ទីរ-អង្គភាព។

-ធ្វើលិខិតជូនដំណឹងស្តីពីការជំរុញការកែលម្អចំណុចខ្វះខាត ដែលគណៈប្រតិភូបានពិនិត្យឃើញក្នុងការិយបរិច្ឆេទ២០១៨ ចំនួន១៣ច្បាប់ ទៅក្រសួង-ស្ថាប័ន ចំនួន៨ គឺក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងព័ត៌មាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងកិច្ចការនារី និងក្រសួងធម្មការ និងសាសនា។

-ទទួលលិខិតឆ្លើយតបស្តីពីការជំរុញការកែលម្អចំណុចខ្វះខាតចំនួន៥ច្បាប់ ពីក្រសួងអប់រំ យុវជន និងកីឡា។

## ៣.៤. ការតាមដានការអនុវត្តច្បាប់

នាយកដ្ឋានតាមដានការអនុវត្តច្បាប់បានបំពេញការងារដូចខាងក្រោម៖

-ចុះតាមដានការអនុវត្តច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានា ចំនួន៣៨លើក ក្នុងនោះ តាមបណ្តាក្រសួង-ស្ថាប័នចំនួន៥ (ច្បាប់ ចំនួន៣ និងអនុក្រឹត្យចំនួន៧) រួមមាន៖

- ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ នៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។
- ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។
- ច្បាប់ស្តីពីគយ នៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- អនុក្រឹត្យលេខ១១៨អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

- អនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងមជ្ឈមណ្ឌលថែទាំមនុស្សចាស់ នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។
- អនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការបង្កើតបេឡាជាតិអតីតយុទ្ធជន នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។
- អនុក្រឹត្យលេខ២៣៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ស្តីពីការបង្កើតវិទ្យាស្ថានជាតិសង្គមកិច្ច នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។
- អនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ ស្តីពីវិធាន និងនីតិវិធី នៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងតាមដានត្រួតពិនិត្យការអនុវត្តសារាចរលេខ០៧.សរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ នៅអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- អនុក្រឹត្យលេខ០៦អនក្រ.បក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា នៅអាកាសយានដ្ឋានអន្តរជាតិព្រះសីហនុ អាកាសយានដ្ឋានអន្តរជាតិសៀមរាប និងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
- អនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីការកម្រិតកំណត់ទំងន់អតិបរមា នៃយានយន្តដឹកជញ្ជូនផ្លូវគោក ដែលបើកបរលើបណ្តាញផ្លូវជាតិ នៃព្រះរាជាណាចក្រកម្ពុជា នៅតាមបណ្តាស្ថានីយជញ្ជីងអចល័ត ទូទាំងព្រះរាជាណាចក្រកម្ពុជា នៅក្រសួងសាធារណការ និងដឹកជញ្ជូន។
- ការចុះតាមដានការអនុវត្តច្បាប់នៅរាជធានី ខេត្ត និងអង្គភាពផ្សេងៗបានចំនួន៣២លើក (ច្បាប់ចំនួន៦ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានាចំនួន៤) រួមមានៈ
- ច្បាប់ស្តីពីជលផល នៅខេត្តបាត់ដំបង និងខេត្តកំពត។
- ច្បាប់ស្តីពីព្រៃឈើ នៅខេត្តស្ទឹងត្រែង ឧត្តរមានជ័យ ពោធិ៍សាត់ និងខេត្តព្រះវិហារ។
- ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ នៅខេត្តក្រចេះ កំពត បាត់ដំបង កណ្តាល ព្រះវិហារ និងខេត្តកំពង់ធំ។
- ច្បាប់ស្តីពីទេសចរណ៍ នៅខេត្តសៀមរាប។
- ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ នៅខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ។
- ច្បាប់ស្តីពីការគ្រប់គ្រងឱសថ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ នៅខេត្តបន្ទាយមានជ័យ។
- អនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ និងប្រកាសលេខ០៨៧ អ.ន.ស.ប្រក/នីក.ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការអភិវឌ្ឍដីនៅខេត្តកំពត ព្រះវិហារ បាត់ដំបង កណ្តាល បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ។

- អនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅខេត្តកំពង់ចាម ប៉ៃលិន បន្ទាយមានជ័យ កោះកុង សៀមរាប កំពង់ធំ ស្វាយរៀង និងខេត្តតាកែវ។
- អនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគីច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រនៅទូទាំងព្រះរាជាណាចក្រកម្ពុជា នៅខេត្តព្រះសីហនុ បាត់ដំបង ត្បូងឃ្មុំ បន្ទាយមានជ័យ កណ្តាល តាកែវ ស្វាយរៀង កោះកុង ប៉ៃលិន ព្រៃវែង ឧត្តរមានជ័យ កំពត និងកំពង់ផែរាជធានីភ្នំពេញ។
- អនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតគ្រឹះស្ថានអង្គរជាគ្រឹះស្ថានសាធារណៈរដ្ឋបាល អនុក្រឹត្យលេខ១៥៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះដាក់ស្តែង នៅក្នុងបុរីសណ្ឋាគារអង្គរសៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប។
- ប្រកាសលេខ០៨៧ អ.ន.ស.ប្រក/នីក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការអភិវឌ្ឍដី និងប្រកាសលេខ៩៦៥ សហវ.ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅដ្ឋាន នៅខេត្តបន្ទាយមានជ័យ។
- សេចក្តីជូនដំណឹងលេខ៣៦៧ សជណ.កមច ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីការចុះតាមដាន និងជំរុញឱ្យបណ្តាក្រសួង ស្ថាប័នដែលមានប្រភពចំណូលត្រូវបង់ចូលថវិកាជាតិ និងតាមដានការអនុវត្តកិច្ចសន្យាវិនិយោគផែស្ងួត នៅរាជធានីភ្នំពេញ។
- ការអនុវត្តកិច្ចសន្យាវិនិយោគប្រមូលភាស៊ី នៅខេត្តពោធិ៍សាត់ បាត់ដំបង ស្វាយរៀង ព្រះវិហារ និងខេត្តស្ទឹងត្រែង។

## ៣.៥. ការទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ

នាយកដ្ឋានទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ បានបំពេញការងារដូចខាងក្រោម៖

-ទទួលពាក្យបណ្តឹងចំនួន ១៣៥បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន ៤៦បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន ៨៩បណ្តឹង)៖

-ពាក្យបណ្តឹងកំពុងពិនិត្យចំនួន ៥បណ្តឹង (ឆ្នាំ២០១៩ចំនួន ៥បណ្តឹង)។

-ពាក្យបណ្តឹងរង់ចាំការសម្រេចពីថ្នាក់ដឹកនាំក្រសួងចំនួន ៤បណ្តឹង (ឆ្នាំ២០១៩ចំនួន ៤បណ្តឹង)។

-ពាក្យបណ្តឹងបានបញ្ជូនទៅស្ថាប័នផ្សេងដោះស្រាយចំនួន ១៧បណ្តឹង (ឆ្នាំ២០១៨ ចំនួន ៤បណ្តឹង ឆ្នាំ២០១៩ចំនួន១៣បណ្តឹង)។

-ពាក្យបណ្តឹងត្រៀមបញ្ជូនទៅស្ថាប័នផ្សេងដោះស្រាយមានចំនួន ២បណ្តឹង(ឆ្នាំ២០១៩ចំនួន២បណ្តឹង)។

-ពាក្យបណ្តឹងដែលជាសមត្ថកិច្ចក្រសួងចំនួន២២បណ្តឹង និងសមត្ថកិច្ចមន្ទីររាជធានី-ខេត្តចំនួន៨៩បណ្តឹង (ឆ្នាំ២០១៩ចំនួន៨៩បណ្តឹង)។

-ពាក្យបណ្ដឹងដែលម្ចាស់បណ្ដឹងសុំដកវិញចំនួន១បណ្ដឹង(ឆ្នាំ២០១៨ចំនួន១បណ្ដឹង)។

-ពាក្យបណ្ដឹងកំពុងចុះអង្កេតស្រាវជ្រាវ ចំនួន៦៨បណ្ដឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន២៧បណ្ដឹង និងមន្ទីររាជធានី-ខេត្តចំនួន៤១បណ្ដឹង ក្នុងនោះឆ្នាំ២០១៤ចំនួន៣បណ្ដឹង ឆ្នាំ២០១៦ចំនួន៣បណ្ដឹង ឆ្នាំ២០១៧ចំនួន៧បណ្ដឹង ឆ្នាំ២០១៨ចំនួន១៤បណ្ដឹង និងឆ្នាំ២០១៩ចំនួន៤១បណ្ដឹង)។

-ពាក្យបណ្ដឹងត្រៀមចុះអង្កេតស្រាវជ្រាវចំនួន៤បណ្ដឹង(ឆ្នាំ២០១៩ចំនួន៤បណ្ដឹង)។

-ពាក្យបណ្ដឹងដែលថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកលែងចាត់ការបន្តចំនួន១បណ្ដឹង (ឆ្នាំ២០១៨ ចំនួន១បណ្ដឹង)។

-ពាក្យបណ្ដឹងដែលបានបង្វែរទៅស្ថាប័នផ្សេងដោះស្រាយ ចំនួន១បណ្ដឹង (ឆ្នាំ២០១៦ ចំនួន១បណ្ដឹង)។

-ពាក្យបណ្ដឹងដែលបានបញ្ចប់ការដោះស្រាយចំនួន៦បណ្ដឹង។

-ពាក្យបណ្ដឹងសុំការសម្របសម្រួលពីថ្នាក់ដឹកនាំក្រសួងចំនួន១បណ្ដឹង។

-ពាក្យបណ្ដឹងបានទទួលការឆ្លើយតបចំនួន៨បណ្ដឹង(ឆ្នាំ២០១៨ចំនួន៣បណ្ដឹង ឆ្នាំ២០១៩ចំនួន៥បណ្ដឹង)។

-ពាក្យបណ្ដឹងដែលម្ចាស់បណ្ដឹងសុំជំរុញការដោះស្រាយចំនួន៨បណ្ដឹង(ឆ្នាំ២០១៦ចំនួន៣បណ្ដឹង ឆ្នាំ២០១៧ចំនួន១បណ្ដឹង ឆ្នាំ២០១៩ចំនួន៤បណ្ដឹង)។

-ពាក្យបណ្ដឹងដែលក្រសួងបានធ្វើលិខិតជំរុញការដោះស្រាយ ចំនួន៨បណ្ដឹង(ឆ្នាំ២០១៦ ចំនួន៣បណ្ដឹង ឆ្នាំ២០១៧ចំនួន១បណ្ដឹង ឆ្នាំ២០១៩ចំនួន៤បណ្ដឹង)។

-ពាក្យបណ្ដឹងដែលបានចុះជំរុញការដោះស្រាយចំនួន១បណ្ដឹង (ឆ្នាំ២០១៨ចំនួន១បណ្ដឹង)។

-ពាក្យបណ្ដឹងបានដោះស្រាយចប់ចំនួន២៨បណ្ដឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន៦បណ្ដឹង និងមន្ទីររាជធានី-ខេត្តចំនួន២២បណ្ដឹង ក្នុងនោះឆ្នាំ២០១៧ចំនួន២បណ្ដឹង ឆ្នាំ២០១៨ចំនួន៦បណ្ដឹង ឆ្នាំ២០១៩ ចំនួន២០បណ្ដឹង)។

## ៣.៦. លទ្ធផលការងារអធិការកិច្ច

ឆ្លងតាមការធ្វើអធិការកិច្ចក្នុងឆ្នាំ២០១៩ ក្រសួងបានពិនិត្យឃើញថា ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពតាមបណ្ដារាជធានី ខេត្តបានអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានបានល្អប្រសើរ។

ទន្ទឹមនឹងនោះ ក៏នៅមានចំណុចអវិជ្ជមានមួយចំនួនដែលត្រូវបានពិនិត្យឃើញ និងបានជំរុញឱ្យកែលម្អដូចខាងក្រោម៖

### ៣.៦.១. ការងារអធិការកិច្ច

*ចំណុចខ្វះខាតលើការគ្រប់គ្រងរដ្ឋបាល*

-ការិយាល័យរដ្ឋបាលរបស់មន្ទីរ-អង្គភាពមួយចំនួនបានចុះលេខស្ទួន ចុះលេខរំលង ចុះលេខមិនតាមលំដាប់លំដោយ ចុះលេខលិខិតដោយពុំបានបញ្ជាក់ខ្លឹមសារ និងពុំបានបិទបញ្ជីសៀវភៅចុះលេខលិខិតចេញចូលប្រចាំឆ្នាំ។

-ការគ្រប់គ្រងវត្តមានមន្ត្រីរាជការតាមក្រសួង មន្ទីរ-អង្គភាពមួយចំនួន ពុំទាន់បានត្រឹមត្រូវស្រប តាមអនុក្រឹត្យលេខ៥៦ អនក្រ.បក ចុះថ្ងៃទី១ ខែមករា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា។

-មន្ត្រីនៅតាមមន្ទីរ-អង្គភាពមួយចំនួនមានឈ្មោះចុះបេសកកម្ម ប៉ុន្តែបានចុះហត្ថលេខាលើបញ្ជីវត្តមាន ឬឯកសាររដ្ឋបាលនៅមន្ទីរ-អង្គភាពក្នុងកាលបរិច្ឆេទដូចគ្នា។

-មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តមួយចំនួន ពុំទាន់បានជំរុញ និងមានវិធានការចំពោះការដ្ឋានសំណង់មួយចំនួន ដែលពុំមានលិខិតអនុញ្ញាតបើក និងបិទការដ្ឋានសំណង់ ពុំស្របតាមប្រកាសលេខ៧៦ ប្រក/ដ.ន.ស ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង និងតួនាទីភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ។

-ការគ្រប់គ្រងយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃតម្លើងយានយន្តមួយចំនួននៅមានកម្រិត ពុំស្របតាមអនុក្រឹត្យលេខ១៨០ អនក្រ.បក ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត។

***ចំណុចខ្វះខាតលើការគ្រប់គ្រងហិរញ្ញវត្ថុ***

-ការប្រើប្រាស់ថវិការដ្ឋទេយ្យបុរេប្រទាន ពុំទាន់បានសមស្របតាមសារាចរណែនាំ។

-ភាពយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធចូលថវិការដ្ឋ។

-បានរក្សាទុកសាច់ប្រាក់ក្នុងបេឡាលើសចំនួនកំណត់។

-ការដកចំណូលថវិការដ្ឋយកទៅប្រើប្រាស់ខុសគោលការណ៍ហិរញ្ញវត្ថុ។

-មន្ទីរ-អង្គភាពប្រមូលចំណូលមួយចំនួន ពុំបានប្រើប្រាស់បង្កាន់ដៃទទួលប្រាក់មានទម្រង់ឯកភាពដែលបោះពុម្ពឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការប្រើប្រាស់ពុំទាន់សមស្របតាមសារាចរណែនាំលេខ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់។

-ការសាងសង់ ជួសជុលមួយចំនួន ពុំសមស្របនិងត្រឹមត្រូវតាមគម្រោងដែលបានលើកឡើង។

-ការបញ្ចេញប្រេងឥន្ធនៈ និងសម្ភារការិយាល័យមួយចំនួន ពុំមានឯកសារយុត្តិការពាក់ព័ន្ធឱ្យបានគ្រប់គ្រាន់ ច្បាស់លាស់ និងត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ។

-ការចំណាយថវិការដ្ឋសម្រាប់ទូទាត់ការជួសជុលមធ្យោបាយដឹកជញ្ជូន និងបរិក្ខារបច្ចេកទេសមួយចំនួន ពុំបានបញ្ជាក់ពីអត្តសញ្ញាណ និងពុំមានឯកសារយុត្តិការពាក់ព័ន្ធឱ្យបានគ្រប់គ្រាន់ច្បាស់លាស់ និងត្រឹមត្រូវនីតិវិធីហិរញ្ញវត្ថុ។

-ការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តជូនមន្ត្រី ពុំមានឯកសារយុត្តិការពាក់ព័ន្ធឱ្យបានត្រឹមត្រូវ។

-ពុំទាន់បានចាត់វិធានការតឹងទារបំណុល ស្របតាមអនុក្រឹត្យលេខ៧២ អនក្រ.ប្រក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

-មានភាពយឺតយ៉ាវក្នុងការផ្តល់របបស្បៀកពាក់ និងសម្ភារប្រើប្រាស់ផ្ទាល់ខ្លួនសម្រាប់ពិរុទ្ធជន និងទណ្ឌិត ដែលជាប់ឃុំនៅក្នុងពន្ធនាគារ។

-សាលាដំបូងរាជធានី ខេត្តមួយចំនួនមានភាពយឺតយ៉ាវ ក្នុងការបង់ប្រាក់រង្វាន់មកក្រសួងយុត្តិធម៌។

*ចំណុចខ្វះខាតលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ*

-ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅមានកម្រិត ជាពិសេស នៅតាមសាលាខេត្តមួយចំនួនត្រូវប្រជាជនទន្ទ្រានកាន់កាប់ មួយចំនួនទៀតត្រូវបានអតីតមន្ត្រី និងមន្ត្រីក្នុងរដ្ឋបាលខេត្ត មានផ្ទះក្នុងបរិវេណខេត្ត និងកំពុងស្នាក់នៅ។

-ក្រសួង មន្ទីរអង្គភាពមួយចំនួនពុំទាន់បានអនុវត្តត្រឹមត្រូវតាមសារាចរណែនាំលេខ០៧ សរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងអនុក្រឹត្យ លេខ៦៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ ស្តីពីវិធាន និងនីតិវិធី នៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ លើការងារមួយចំនួនមានជាអាទិ៍៖

+ពុំបានបង្កើតក្រុមការងារបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ នៅតាមអង្គភាពប្រើប្រាស់ ដើម្បីទទួលខុសត្រូវលើការរៀបចំ និងការកត់ត្រាបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

+ពុំបានធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ។

+ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ កើនឡើង ថយចុះ ប្រចាំឆ្នាំពុំទាន់ពេលវេលា។

+ពុំបានកត់ត្រាសម្ភារបច្ចេកទេស ដែលទិញតាមរយៈរដ្ឋទេយ្យបុរេប្រទាន និងក្រសួងផ្តល់ឱ្យចូលក្នុង បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

+មានភាពយឺតយ៉ាវក្នុងការស្នើសុំគោលការណ៍ជម្រះចេញពីបញ្ជីសារពើភណ្ឌនូវទ្រព្យសម្បត្តិរដ្ឋដែលចាស់ទ្រុឌទ្រោម ខូចគុណភាពប្រើប្រាស់លែងកើត។

## ៣.៦.២. ការងារតាមដានការអនុវត្តច្បាប់

ក្រុមការងារ តាមដានការអនុវត្តច្បាប់បានពិនិត្យឃើញចំណុចអវិជ្ជមាន នៅតាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាពតាមបណ្តារាជធានី-ខេត្ត ហើយបានជំរុញឱ្យកែលម្អដូចខាងក្រោម៖

- **ច្បាប់ស្តីពីគយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករ**

-កំណត់ហេតុបទល្មើសច្បាប់គយមួយចំនួនមានភាពខ្វះចន្លោះដូចជា ពុំបានភ្ជាប់មកជាមួយរូបថតល្មើសច្បាប់គយ បញ្ជីវត្ថុមានអង្គភាពដែលចូលរួមបង្ក្រាប លិខិតបញ្ជាបេសកកម្ម និងលិខិតផ្ទេរសិទ្ធិ ពុំបានផ្តិតមេដៃក្នុងលិខិតចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ក្នុងករណីមួយចំនួនដែលអាចកំណត់អត្តសញ្ញាណរបស់ក្រុមហ៊ុន ឬក្រុមហ៊ុនដឹកជញ្ជូនបាន ប៉ុន្តែពុំបានបំពេញក្នុងតារាងព័ត៌មានបន្ថែមអមកំណត់ហេតុល្មើសច្បាប់គយ ការិយាល័យគយ និងរដ្ឋាករ ខណ្ឌមួយចំនួន ពុំបានគូសបន្ទាត់បញ្ចប់ក្នុងចំណុចអធិប្បាយ ការិយាល័យគយ និងរដ្ឋាករ ខណ្ឌមួយចំនួន មានការកោសលុបលើកំណត់ហេតុបទល្មើសច្បាប់គយ។

-មានភាពយឺតយ៉ាវក្នុងការបញ្ជូនកំណត់ហេតុបទល្មើសច្បាប់គយមួយចំនួនទៅតុលាការ។

-មិនទាន់មានវិធានការម៉ឺងម៉ាត់ចំពោះអាជីវកម្មអគារទំនិញរួចពន្ធមួយចំនួន ដែលបានប្តូរទីតាំងដោយគ្មានការអនុញ្ញាត រក្សាទុកវិក្កយបត្រលក់ពុំបានគ្រប់គ្រាន់ លក់ទំនិញដែលបាននាំចូលតាមរបបអគារលក់ទំនិញរួចពន្ធសម្រាប់ប្រើប្រាស់ឱ្យអតិថិជនក្នុងស្រុក និងការធ្វើរបាយការណ៍ជូនរដ្ឋបាលគយមានភាពយឺតយ៉ាវ។

- **ច្បាប់ស្តីពីទេសចរណ៍ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅខេត្តសៀមរាប**

-សណ្ឋាគារ និងមគ្គុទេសក៍ទេសចរណ៍មួយចំនួន បានប្រើប្រាស់អាជ្ញាបណ្ណផុតសុពលភាព គ្មានអាជ្ញាបណ្ណ ឬអាជ្ញាបណ្ណដែលមានភាពមិនត្រឹមត្រូវ។

-ក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍ មគ្គុទេសក៍ទេសចរណ៍ និងសណ្ឋាគារមួយចំនួន មានភាពយឺតយ៉ាវក្នុងការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ ហើយនៅបន្តប្រើប្រាស់អាជ្ញាបណ្ណផុតសុពលភាព។

-ការចេញអាជ្ញាបណ្ណអាជីវកម្ម សេវាកម្មទេសចរណ៍មានភាពយឺតយ៉ាវ។

-កង្វះខាតក្នុងការទប់ស្កាត់ការប្រកបអាជីវកម្មទីភ្នាក់ងារទេសចរណ៍ និងការីទេសចរណ៍ខុសច្បាប់។

- **ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនៅខេត្តកំពត កណ្តាល ក្រចេះ កំពង់ស្ពឺ រតនគិរី និងខេត្តកំពង់ធំ ប្រចាំថ្ងៃនៅក្នុងបញ្ជិកាឬសៀវភៅលក់ឱ្យបានត្រឹមត្រូវ**

-ក្រុមហ៊ុន និងសហគ្រាសមួយចំនួនបានប្រើប្រាស់វិក្កយបត្រលក់ ដែលគ្មានត្រាបញ្ជាក់ការទទួលស្គាល់ដោយមន្ទីររ៉ែ និងថាមពលខេត្ត រាជធានី។

-ក្រុមហ៊ុន និងសហគ្រាសមួយចំនួនអនុវត្តមិនទាន់បានត្រឹមត្រូវ តាមលក្ខខណ្ឌនៅក្នុងអាជ្ញាបណ្ណដូចជា មិនទាន់បានដាក់តម្កល់ប្រាក់ធានាកាតព្វកិច្ចការងារ(អប្បបរមា) មិនទាន់បានទិញធានារ៉ាប់រងសុវត្ថិភាព និងសុខភាពសម្រាប់កម្មករនិយោជិតដែលបំពេញការងារក្នុងប្រតិបត្តិការអាជីវកម្មធនធានរ៉ែ មិនទាន់បានបោះបង្គោលកំណត់ព្រំដែនអាជ្ញាបណ្ណរបស់ខ្លួន និងមិនទាន់បានបង់ប្រាក់តម្កល់សម្រាប់មូលនិធិស្តារការដ្ឋានរ៉ែឡើងវិញនៅឡើយ។

-សហគ្រាសមួយចំនួនមិនទាន់បានណែនាំអស់លទ្ធភាពដល់ម្ចាស់រថយន្ត ដែលដឹកជញ្ជូនរ៉ែចេញពីការដ្ឋានគ្របឱ្យបានជិត ការពារការហុយ ឬជ្រុះធ្លាក់ដែលអាចប៉ះពាល់ដល់បរិស្ថាន ឬបង្កគ្រោះថ្នាក់ជាយថាហេតុ។

-អាជ្ញាធរមានសមត្ថកិច្ចមានភាពយឺតយ៉ាវក្នុងការចេញអាជ្ញាបណ្ណបន្តជូនម្ចាស់អាជីវកម្ម។

- **ច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅខេត្តមណ្ឌលគិរី ស្ទឹងត្រែង និងខេត្តពោធិ៍សាត់**

-ខណ្ឌរដ្ឋបាលព្រៃឈើមួយចំនួនមានចំណុចខ្វះខាត ក្នុងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ដូចជា មិនទាន់បានគ្រប់គ្រងរោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើឱ្យបានត្រឹមត្រូវ ចេញលិខិតអនុញ្ញាតបង្កើតរោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូចមានភាពយឺតយ៉ាវ និងបានបញ្ជូនសំណុំរឿងបទល្មើសព្រៃឈើទៅតុលាការមានភាពយឺតយ៉ាវ។

-ផ្នែករដ្ឋបាលព្រៃឈើមួយចំនួនមិនទាន់បានជម្រះមធ្យោបាយល្មើសច្បាប់ព្រៃឈើ។

-រោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើមួយចំនួន ពុំទាន់ទទួលបានសៀវភៅកត់ត្រាការចរាចរផល អនុផលព្រៃឈើ និងផលិតផលធ្វើពីឈើចូល-ចេញសម្រាប់ឆ្នាំ២០១៩នៅឡើយ។

-រោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ពុំមានកិច្ចសន្យាផ្គត់ផ្គង់ឈើស្របច្បាប់នៅឡើយ។

-នាយផ្នែករដ្ឋបាលព្រៃឈើមួយចំនួន បានចុះហត្ថលេខាលើបទល្មើសព្រៃឈើ ដោយមិនទាន់បានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌នៅឡើយ។

- **ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

-កង្វះខាតរបាយការណ៍តាមដានការអនុវត្តគម្រោងចំពោះលទ្ធកម្មសំណង់។

-កង្វះខាតលើការវាយតម្លៃលក្ខណៈសម្បត្តិរបស់ក្រុមហ៊ុនដែលចូលរួមដេញថ្លៃ។

-ភាពយឺតយ៉ាវក្នុងការចេញលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការដេញថ្លៃ។

-ការអនុវត្តកិច្ចលទ្ធកម្មដែលមានប្រភេទនិងមុខសញ្ញាខុសគ្នានៅក្នុងគម្រោងតែមួយ។

- **អនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ**

-ក្រុមការងារដីរដ្ឋក្រុងព្រះវិហារ និងក្រុមការងារដីរដ្ឋស្រុកឆែប មិនទាន់បានអនុវត្តតួនាទីភារកិច្ចមួយចំនួនដែលមានចែងក្នុងអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ នៅឡើយ រួមមានការប្រមូល និងចងក្រងឯកសារ ព័ត៌មានដើម្បីធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ សង្ខេបមតិយោបល់សាធារណៈដែលបានទទួល និងរៀបចំទិន្នន័យ និងឯកសារចាំបាច់រួមទាំងផែនទីដីរដ្ឋដែលមានបញ្ជាក់ព័ត៌មានទាំងអស់ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី និងផ្តល់មតិយោបល់ក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ។

-គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារបាន និងកំពុងរៀបចំធ្វើផែនទីដីរដ្ឋ ចុះបញ្ជីដីរដ្ឋ និងធ្វើចំណាត់ថ្នាក់ដីរដ្ឋ តាមការណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប៉ុន្តែមិនទាន់បានរួចរាល់នៅឡើយ។

-ដីរដ្ឋចំនួន៦កន្លែង ស្មើនឹង៦ក្បាលដីក្នុងឃុំម្លូព្រៃមួយ ឃុំម្លូព្រៃពីរ ស្រុកឆែប ខេត្តព្រះវិហារ និងដីបម្រុងរដ្ឋ ស្ថិតនៅភូមិហ្មសែត សង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ ត្រូវបានប្រជាពលរដ្ឋក្នុងសហគមន៍ផ្ទាល់ និងអ្នកចំណាកស្រុកពីតំបន់ផ្សេងៗ មកធ្វើការចូលទន្ទ្រានកាន់កាប់ដីរដ្ឋធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន។

- **អនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០១ នៅខេត្តមណ្ឌលគិរី កណ្តាល តាកែវ បន្ទាយមានជ័យ ស្វាយរៀង ព្រះសីហនុ ត្បូងឃ្មុំ កោះកុង ព្រៃវែង កំពត សៀមរាប បាត់ដំបង ស្ទឹងត្រែង និងរាជធានីភ្នំពេញ**

-ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារមួយចំនួនមិនទាន់មានទីតាំងត្រួតពិនិត្យទំនិញរួមគ្នា។

-ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារមួយចំនួនមិនទាន់បានអនុវត្តរបបប្រជុំប្រចាំខែ រៀបចំរបាយការណ៍បូកសរុបការងារប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងពុំទាន់មានបទបញ្ជាផ្ទៃក្នុង សម្រាប់អនុវត្តក្នុងទីស្នាក់ការរបស់ខ្លួននៅឡើយ។

-មន្ត្រីជំនាញប្រចាំការនៅតាមទីស្នាក់ការមួយចំនួនបានបម្រើការងារហួសអាណត្តិ។

-តាមបណ្តាទីស្នាក់ការត្រួតពិនិត្យច្រកទ្វារមួយចំនួន មិនទាន់មានការគ្រប់គ្រងស្ថិតិមធ្យោបាយដឹកជញ្ជូននាំចេញ-នាំចូលឱ្យបានត្រឹមត្រូវនៅឡើយ។

-ការិយាល័យគយ និងរដ្ឋាករមួយចំនួន មានភាពយឺតយ៉ាវ ក្នុងការបញ្ជូនសំណុំរឿងបទល្មើសច្បាប់គយទៅតុលាការ។

-ការិយាល័យគយ និងរដ្ឋាករមួយចំនួន ពុំទាន់បានស្រាវជ្រាវបង្ក្រាបអំពើរត់គេចពន្ធឱ្យបានទាំងស្រុងនៅឡើយ។

- **អនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ នៅខេត្តកំពង់ឆ្នាំង កំពត កណ្តាល កំពង់ធំ ស្វាយរៀង កំពង់ចាម និងខេត្តសៀមរាប**

-សំណង់មួយចំនួនបានសាងសង់រួចរាល់ដោយគ្មានលិខិតអនុញ្ញាតសាងសង់។

-អាជ្ញាធរមានសមត្ថកិច្ចមានភាពយឺតយ៉ាវក្នុងការចេញលិខិតអនុញ្ញាតសាងសង់។

-សំណង់មួយចំនួនបានសាងសង់រួចរាល់ និងមួយចំនួនទៀតកំពុងដំណើរការសាងសង់ដោយពុំមានលិខិតអនុញ្ញាតបើកការដ្ឋាន និងបិទការដ្ឋាន។

-សំណង់រោងចក្រមួយចំនួន ពុំទាន់បានធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន(EIA) រួចរាល់នៅឡើយ។

- **អនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៩ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ**

-ប្រព័ន្ធគ្រប់គ្រងជញ្ជីងថ្លឹងរថយន្ត នៅស្ថានីយជញ្ជីងអចល័តទាំងអស់ជារឿយៗ មានភាពអាក់អួលបច្ចេកទេសក្នុងការថ្លឹងរថយន្តដែលបណ្តាលមកពីមូលហេតុផ្សេងៗ (ប្រព័ន្ធគ្រប់គ្រងជញ្ជីងខូច ដាច់ភ្លើង ភ្លើងខ្សោយ ភ្លៀង ផ្គររន្ទះ...)។

-ការទប់ស្កាត់បទល្មើសរថយន្តដឹកលើសទម្ងន់កម្រិតកំណត់ របស់មន្ត្រី នៅតាមស្ថានីយជញ្ជីងអចល័តមួយចំនួនមិនទាន់បានអស់លទ្ធភាពនៅឡើយ (ដោយសារទីតាំងជញ្ជីងឯកទិស មានការពិបាកឱ្យរថយន្តចូលស្ថានីយ និងមានការកកស្ទះចរាចររថយន្តខ្លះមិនចូលថ្លឹង)។

-ស្ថានីយជញ្ជីងអចល័តបារិត ព្រៃកឯង ក្រសាំង ឃ្លាំងសម្បត្តិ ថ្នល់ទទឹង ថ្នល់កែង មានជ័យ កំពង់ទួល ខែលជ័យ ព្រៃកញ្ចៅ អង្គស្នួល អូរចំណារ លង្វែក រាជានុកូល ឃ្លាំងមឿង ពួក កូនដំរី រលួស ត្រពាំងផ្លុង និងស្ថានីយត្រពាំងក្រហម មានផ្លូវវាងដែលបង្កលក្ខណៈឱ្យរថយន្តដឹកលើសទម្ងន់កម្រិតកំណត់ ធ្វើចរាចរគេចពីស្ថានីយថ្លឹង។

- **ប្រកាសលេខ០៨៧ ដ.ន.ស.ប្រក/នីក. ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការអភិវឌ្ឍដីនៅខេត្តកោះកុង**

-គម្រោងអភិវឌ្ឍដីមួយចំនួន មិនទាន់មានលិខិតអនុញ្ញាតអភិវឌ្ឍដីដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

- **សេចក្តីជូនដំណឹងលេខ៣៦៧ សជណ.កមច និងកិច្ចសន្យាវិនិយោគផែស្ងួតនៅតាមបណ្តាផែស្ងួត ក្នុងរាជធានីភ្នំពេញ**

-ផែស្ងួតមួយចំនួនពុំបានដាក់ជញ្ជីងសម្រាប់ថ្លឹងទំនិញនាំចូល តាមការណែនាំរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ដើម្បីសុក្រឹតភាពនៃការបង់ពន្ធ។

-ប្រតិវេទន៍គយមួយចំនួន មិនមានចុះហត្ថលេខារបស់ជើងសារគយ ឬហត្ថលេខារបស់អ្នកបំពេញបែបបទបញ្ចេញទំនិញពីគយមានភាពមិនត្រឹមត្រូវ។

-មន្ត្រីគយនៅតាមបណ្តាផែស្ងួតមួយចំនួនបានប្រើប្រាស់លិខិតផ្ទេរសិទ្ធិ ដោយពុំបានចុះកាលបរិច្ឆេទ ហត្ថលេខា និងប្រើប្រាស់បណ្ណ ដើងសារគេយហួសសុពលភាព ក្នុងការបំពេញបែបបទបញ្ចេញទំនិញពីគយ។

- **កិច្ចសន្យាវិនិយោគអាជីវកម្មប្រមូលភាស៊ីនៅខេត្តព្រៃវែង កំពត ស្វាយរៀង ស្ទឹងត្រែងពោធិ៍សាត់ និងខេត្តក្រចេះ**

-ក្រុមហ៊ុនវិនិយោគអាជីវកម្មភាស៊ីផ្សារ ចំណតយានយន្ត ចំណតជលយាន និងសត្តឃាតដ្ឋាន មួយចំនួនពុំទាន់បានអនុវត្តឱ្យបានត្រឹមត្រូវតាមកិច្ចសន្យា និងសៀវភៅបន្ទុកដូចជា សាងសង់ហេដ្ឋារចនាសម្ព័ន្ធមិនទាន់បានរួចរាល់ យកភាស៊ីនៅតាមទីតាំងផ្សេងខុសពីការកំណត់ ពុំបានបិទផ្សាយជាសាធារណៈនូវសេចក្តីជូន ដំណឹងស្តីពីថ្លៃភាស៊ីដែលត្រូវប្រមូលពុំទាន់បានរៀបចំសណ្តាប់ធ្នាប់ឱ្យមានរបៀបរៀបរយ ដោយនៅមានអាជីវករមួយចំនួនដាក់តាំងលក់របស់របរនៅក្រោបរិវេណតូប និងលើផ្លូវដើរ ភ្នាក់ងារប្រមូលភាស៊ីមិនបានស្លៀកពាក់ឯកសណ្ឋានឱ្យបានត្រឹមត្រូវ និងទៀងទាត់នៅពេលបំពេញការងារ និងមិនបានប្រើប្រាស់ប័ណ្ណទារភាស៊ីដែលចេញដោយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត។

-អ្នកប្រកបអាជីវកម្មពិឃាតសត្វ នៅសត្តឃាតដ្ឋានមួយចំនួនពុំមានលិខិតអនុញ្ញាតប្រកបអាជីវកម្មពិឃាតសត្វប្រចាំឆ្នាំ ពុំស្របតាមសៀវភៅបន្ទុក។

### ៣.៦.៣. ការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ

ក្រសួងបានទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវបានផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋដែលបានចូលរួមចំណែក ក្នុងការកាត់បន្ថយភាពក្រីក្រ និងកាត់បន្ថយទំនាស់ក្រៅប្រព័ន្ធតុលាការជូនប្រជាពលរដ្ឋដោយបានទទួលពាក្យបណ្តឹងសរុបចំនួន១៣៥បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន៤៦បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន៨៩បណ្តឹង) ក្នុងនោះបណ្តឹងដែលជាសមត្ថកិច្ចរបស់ក្រសួងចំនួន២២បណ្តឹង និងសមត្ថកិច្ចមន្ទីររាជធានី-ខេត្ត ចំនួន៨៩បណ្តឹង បានបញ្ជូនទៅស្ថាប័នផ្សេងដោះស្រាយមានចំនួន១៧បណ្តឹង កំពុងចុះអង្កេតស្រាវជ្រាវចំនួន៦៨បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន២៧បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន៤១បណ្តឹង) បានទទួលការឆ្លើយតបចំនួន៨បណ្តឹង និងបានបញ្ចប់ការដោះស្រាយចំនួន២៨បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន៦បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន២២បណ្តឹង)។

បណ្តឹងដែលបានដោះស្រាយរួចរាល់ទាំង២៨ ករណី រួមមាន៖

១-លោកឧកញ៉ា សូ ងួន អគ្គនាយកផែស្ងួត សូ ងួន ស្នើសុំបញ្ជូនមន្ត្រីអគ្គនាយកដ្ឋានអធិការកិច្ចជួយសម្របសម្រួលករណីការបើកផ្លូវទំហំទទឹង៥ម៉ែត្រ បណ្តោយ៨៥ម៉ែត្រ ឱ្យប្រជាពលរដ្ឋឆ្លងកាត់ក្នុងបរិវេណដីផែស្ងួតរបស់គាត់នៅភូមិចោមចៅ៣ សង្កាត់ចោមចៅ២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ ករណីទំនាស់នេះត្រូវបានដោះស្រាយបញ្ចប់ជាស្ថាពរ ដោយឈរលើយុទ្ធសាស្ត្រឈ្នះឈ្នះ ដែលក្នុងនោះភាគីលោកឧកញ៉ា សូ ងួន បានយល់ព្រម ទទួលយកតាមសំណើសុំរបស់ប្រជាពលរដ្ឋ គឺរៀបចំប្រព័ន្ធលូ និងផ្លូវបេតុងតាមលក្ខណៈស្តង់ដារនៅដើមខែមករា ឆ្នាំ២០២០ ជំនួសការស្នើសុំបើកផ្លូវទំហំទទឹង៥ម៉ែត្រ បណ្តោយ៨៥ម៉ែត្រក្នុងបរិវេណផែស្ងួតរបស់គាត់។ ដោយឡែកបងប្អូនប្រជាពលរដ្ឋបានឯកភាពគ្នាយល់ព្រមដកពាក្យបណ្តឹង ដែលពួកគាត់បានប្តឹងកន្លងមកនៅគ្រប់

ស្ថាប័ន និងបញ្ឈប់ការប្ដឹងព្រមទាំងទទួលយកតាមការអភិវឌ្ឍរបស់លោកឧកញ៉ា សូ ងួន ដើម្បីបញ្ចប់ទំនាស់នេះ។

២-ឈ្មោះ សួន សុភា តំណាងឱ្យឈ្មោះ នេត វ៉ាន់លី និងឈ្មោះ នេត ចាន់ធឿន សុំប្ដឹងអាជ្ញាធរដែនដីដែលបានឃុបឃិតគ្នាយកដីរបស់គាត់ទៅលក់ឱ្យឈ្មួញ នៅភូមិកោះផុស ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្ដាល។ ករណីនេះត្រូវបានដោះស្រាយបញ្ចប់ ដោយឈ្មោះ សួន សុភា យល់ព្រមទទួលយកដីដែលអាជ្ញាធរស្រុកកៀនស្វាយប្រគល់ជូន។

៣-ឈ្មោះ សុទ្ធ សិរីវិចិត្រ ប្ដឹងឈ្មោះ ហុក ចិន្ដា ជនជាតិខ្មែរ និងឈ្មោះ លី យ៉ុងណាំ ជនជាតិកូរ៉េ សញ្ជាតិខ្មែរ ពីបទរំលោភបំពានដីគាត់ទំហំ១ហិកតា នៅភូមិកូនសត្វ ឃុំកូនសត្វ ស្រុកទឹកឈូ ខេត្តកំពត ត្រូវបានដោះស្រាយរួច ដោយអាជ្ញាធរខេត្តកំពតអនុញ្ញាតឱ្យលោកស្រី សុទ្ធ សិរីវិចិត្រមានសិទ្ធិអាស្រ័យផលនៅលើទីតាំងដីដែលលោកស្រីបានប្ដឹងទាមទារ។

៤-ឈ្មោះ ប៊ុន ប៉ាក់ រស់នៅភូមិទួលចា ឃុំសំរោង ស្រុកសំរោង ខេត្តតាកែវ ប្ដឹងលោក កែវ ធឿន និងលោកស្រី ឡាវ ឃីម ថាបានធ្វើតូបលក់ដូរនៅពីមុខតូបរបស់គាត់។ ករណីនេះត្រូវបានដោះស្រាយសម្របសម្រួលបញ្ចប់ ដោយភាគីលោក កែវ ធឿន និងលោកស្រី ឡាវ ឃីមព្រមផ្ដល់ចំណែកដីខ្លះជូនឈ្មោះ ប៊ុន ប៉ាក់។

៥-ប្រជាពលរដ្ឋចំនួន៩គ្រួសារ ដែលមានដីទំហំ៦៨.១៣ហិកតា ស្ថិតនៅភូមិស្រែនាម ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ ប្ដឹងអាជ្ញាធរខេត្តដែលរឹបអូស និងបណ្ដេញពួកគាត់ចេញពីផ្ទះ។ ជម្លោះនេះត្រូវបានដោះស្រាយបញ្ចប់ ដោយប្រជាពលរដ្ឋដែលបានប្ដឹងនោះបានយល់ព្រមទទួលយកដី ដែលអាជ្ញាធរខេត្តក្រចេះផ្ដល់ជូន។

៦-ឈ្មោះ គៅ ហុង ប្រធានអង្គការ CHESSED ប្ដឹងឈ្មោះ ហ៊ាង ឆៃលី និងបក្ខពួកដែលបានរំលោភយកដីរបស់គាត់ទំហំ៣.៣៤៩ហិកតា (បីហិចតា សាមសិបបួនអា ប្រាំបួនសង់ទីអា) ដែលមានទីតាំងនៅភូមិពូតាំង សង្កាត់មនោរម្យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។ ករណីទំនាស់នេះត្រូវបានដោះស្រាយសម្របសម្រួលបញ្ចប់ ដោយភាគីលោក ហ៊ាង ឆៃលី យល់ព្រមប្រគល់ដីទំហំដែលមានទំនាស់ជូនភាគីលោក គៅ ហុង វិញ។

៧-លោក ម៉ៅ សំអឿន នៅភូមិកណ្ដាល សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំងប្ដឹងទាមទារក្ដួរពង្រាបដីស្រែទំហំ៧៣.០៦ហិកតា នៅភូមិថ្មកែវ និងភូមិកំពង់រាំង ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ ក្រុមការងារបានពិនិត្យឃើញថាទីតាំងដីនេះជាដីស្រែប្រជាពលរដ្ឋធ្លាប់ធ្វើស្រែឡើងទឹកក្នុងរដូវវស្សា តាំងពីសម័យដើម ហើយស្ថិតក្នុងតំបន់២ ដែលត្រូវហាមឃាត់មិនឱ្យចេញប័ណ្ណ និងតំបន់ដែនព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប (អនុក្រឹត្យ១៩៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១) ដែលត្រូវការពារ ប៉ុន្តែប្រជាពលរដ្ឋអាចមានសិទ្ធិ អាស្រ័យផលមុនច្បាប់កំណត់តែហាមរាតដីបន្ថែម និងកាប់បំផ្លាញព្រៃលិចទឹក។ ជាក់ស្ដែងទីតាំងនេះ មិនមានព្រៃលិចទឹកទេ មានស្មៅព្រែងដុះមួយចំនួន មានស្នាមភ្លឺស្រែ និងប្រឡាយចាស់ៗ ដែលប្រជាពលរដ្ឋធ្លាប់អាស្រ័យផលយូរហើយ ប៉ុន្តែបានបោះបង់ចោលនៅឆ្នាំ២០១៦ ដោយសារខ្វះប្រព័ន្ធស្រោចស្រព។ នៅជុំវិញទីតាំងដីស្ទើរសុំសុទ្ធតែជាដីស្រែ របស់ប្រជាពលរដ្ឋ ហើយ កន្លែងខ្លះមានប័ណ្ណសំគាល់សិទ្ធិ ក្នុងឆ្នាំ ១៩៩៥។ ដោយ

ទ្បែកដីនេះមិនទាន់មានប័ណ្ណដោយសារមានទំនាស់ព្រំប្រទល់ភូមិ។ ករណីបណ្ដឹងនេះត្រូវបានសម្រប សម្រួលបញ្ចប់ទំនាស់រួចហើយ។

៨-ឈ្មោះ ភួន ផានីស្នើសុំទៅរដ្ឋសភាជួយអន្តរាគមន៍ទៅឯកឧត្តមអភិបាលខេត្តកំពង់ឆ្នាំង ដើម្បីឱ្យលោកអភិបាលស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ប្រគល់ត្រាក់ទ័រ ដែលត្រូវសមត្ថកិច្ចមេព្រៃ និងប៉ូលីសស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ចាប់យករក្សាទុកនៅស្នាក់ការមេព្រៃស្រុកទឹកផុស ខេត្តកំពង់ឆ្នាំងជូនគាត់វិញ។ ក្រុមការងារបានពិនិត្យឃើញថា ទីតាំងដីដែលឈ្មោះ ភួន ផានី បានយកត្រាក់ទ័រទៅភ្ជួរ និងឈូសពង្រាបនេះ ជាដីរបស់ឈ្មោះ ជា វណ្ណដា ដែលបានទិញពីឈ្មោះ ឡុង សុភាព ដោយមានការបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរភូមិ-មេឃុំ។ តែដីនេះស្ថិតនៅក្នុងគម្របព្រៃ ឆ្នាំ២០០២ បច្ចុប្បន្នជាដីព្រៃរិចរិល ហើយនៅជុំវិញតំបន់នេះសុទ្ធតែស្រែ ចំការរបស់ប្រជាពលរដ្ឋប្រើប្រាស់ អាស្រ័យផលយូរហើយ នឹងនៅជិតផ្ទះរបស់ប្រជាពលរដ្ឋក្នុងភូមិឃោតដែរ។ ឈ្មោះ ភួន ផានី គ្រាន់តែស៊ីឈ្នួលភ្ជួរដីឱ្យគេប៉ុណ្ណោះ ដោយភាគីម្ចាស់ដីមានឯកសារបញ្ជាក់ទទួលស្គាល់កម្មសិទ្ធិ ដោយអាជ្ញាធរភូមិ-ឃុំ ហើយគាត់ក៏ពុំបានដឹងថា ដីនេះជាដីរបស់រដ្ឋនោះដែរ។ រដ្ឋបាលព្រៃឈើគួរកំណត់ឱ្យបានច្បាស់កន្លែងណាដែលជាដីព្រៃដែលត្រូវរក្សាទុកកន្លែងណាជាដី ដែលប្រជាពលរដ្ឋអាចប្រើប្រាស់អាស្រ័យផលបាន។ យកផែនទីគម្របព្រៃ២០០២ មកអនុវត្ត សូម្បីតែវត្តអារាម សាលារៀន និងភូមិឋានរបស់ប្រជាពលរដ្ឋមួយចំនួនធំ ក៏ស្ថិតនៅក្នុងដីរបស់រដ្ឋដែរ។ តែករណីនេះ ត្រូវបានរដ្ឋបាលព្រៃឈើខេត្តកំពង់ឆ្នាំង បានកសាងសំណុំរឿង បញ្ជូនទៅលោកព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកំពង់ឆ្នាំង ចោទប្រកាន់ពីបទឈូសឆាយដីព្រៃក្នុងផែនទីគម្របព្រៃ ឆ្នាំ២០០២ គឺផុតពីសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើ និងក្រុមការងារក្រសួងទៅហើយ។

៩-មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកំពង់ឆ្នាំងប្ដឹងប្រជាពលរដ្ឋសាងសង់លូស្ដុកទឹកស្អុយចំនួន៤អណ្ដូងលូ នៅលើដីចំណីផ្លូវលេខ៦៩ (ក្រៅរបងរបស់ម្ចាស់ផ្ទះ) ខាងជើងហាងអង្គរធំស្ថិតនៅភូមិទួលក្រឡាញ់ សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង។ ក្រុមការងារពិនិត្យឃើញថា ម្ចាស់ផ្ទះឈ្មោះ នៅរ៉ាវ៉ែនពិតជាបានសាងសង់លូស្ដុកទឹកស្អុយចំនួន៤ អណ្ដូងលូ នៅលើដីចំណីផ្លូវលេខ៦៩(ក្រៅរបងផ្ទះ)។ ដូច្នេះ ក្រុមការងារប្រគល់ភារកិច្ចជូនអាជ្ញាធរក្រុងធ្វើសេចក្ដីជូនដំណឹងដល់ម្ចាស់ ដើម្បីរុះរើលូស្ដុកទឹកស្អុយដែលសង់លើចំណីផ្លូវជាបន្ទាន់ ដោយទុករយៈពេល៩ថ្ងៃ គិតចាប់ពីថ្ងៃទី២៨ ខែមីនា រហូតដល់ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩។ ក្នុងករណីមិនអនុវត្តតាមសេចក្ដីជូនដំណឹង ក្រុមការងារនឹងអនុវត្តតាមច្បាប់។ បច្ចុប្បន្នគាត់បានរុះរើរួចហើយ។

១០-ឈ្មោះ សាំង សុំ ហៅ កែវ សុំ នៅភូមិដំបូកកោះ ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំងប្ដឹងឱ្យមន្ទីរអធិការកិច្ចខេត្តអន្តរាគមស្នើឱ្យមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខេត្តកំពង់ឆ្នាំង ផ្ដល់សំណុំឯកសារ នៃការចុះបញ្ជីដីធ្លីមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ លេខកធ០០៣២៦១ ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០០០ និងលេខកធ០០៣២២២ ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០០ ដែលមានអ្នកកាន់កាប់ឈ្មោះ ពត ផា ភេទស្រី ជាប្រពន្ធ អ៊ី ទ្រី។ មេភូមិដំបូកកោះ និងមេឃុំស្វាយជ្រុំ បានផ្ដល់ឯកសារនៃការទិញ-លក់ដី ពីឈ្មោះ ពត ផា ឱ្យទៅឈ្មោះ ចាយ សម្បត្តិ ក្នុងឆ្នាំ ២០១៧។ ករណីនេះត្រូវបានបញ្ចប់ដោយអ្នកប្ដឹងបានទទួលអ្វីដែលគាត់ចង់បាន។

១១-ឈ្មោះ វន សំបូរ នៅភូមិសន្ទួច ឃុំស្រែថ្មី ស្រុកលាប្អៀរ ខេត្តកំពង់ឆ្នាំង ប្ដឹងឈ្មោះ ហ៊ឹម បុរី បច្ចុប្បន្នរស់នៅភូមិគ្រោកលិច ឃុំស្រែថ្មី ស្រុកលាប្អៀរ ខេត្តកំពង់ឆ្នាំង ពីបទរំលោភលើទំនុកទុកចិត្ត។ ភាគីទាំងពីរបានព្រមព្រៀងគ្នា ដោយភាគី ហ៊ឹម បូរី បានជំពាក់លុយភាគី វន សំបូរ ចំនួន ២០០០ដុល្លារអាមេរិក តែសុំសងត្រឹមចំនួន១៥០០ដុល្លារអាមេរិក។ ភាគី វន សំបូរ យល់ព្រមតាមការស្នើសុំរបស់ភាគី ហ៊ឹម បូរី និងបានទទួលលុយពីភាគី ហ៊ឹម បូរី ដោយផ្ទាល់ដៃចំនួន១៥០០ដុល្លារអាមេរិក ដើម្បីបញ្ចប់ទំនាស់។

១២-ពាក្យបណ្ដឹងឈ្មោះ លី សីណា នៅភូមិចន្លោះរេន ឃុំស្វាយជ្រុំ ស្រុកលាប្អៀរ ខេត្តកំពង់ឆ្នាំងប្ដឹងធនាគារ អេស៊ីលីដា លើបញ្ហាដកប្រាក់លក់ដីពីគណនីរបស់គាត់មិនបាន។ តាមរបាយការណ៍ធនាគារ នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ ឈ្មោះ លី ស៊ីណា បានដាក់លុយក្នុងគណនីរបស់ខ្លួនចំនួន១០០ដុល្លារអាមេរិក នៅធានាគារអេស៊ីលីដាខេត្តកំពង់ឆ្នាំង និងដកមកវិញចំនួន១០០ដុល្លារអាមេរិកតាមអេធីអឹមក្នុងថ្ងៃតែមួយ ហើយយកលុយចំនួន១០០ដុល្លារអាមេរិក ដដែលនេះ ទៅដាក់នៅធានាគារអេស៊ីលីដាសាខាផ្សេងទៀតនៅភ្នំពេញ នៅស្ទឹងមានជ័យ នៅចោមចៅ និងនៅកំបូល ចំនួន៤លើក មានន័យថាដាក់ដក ដាក់ដកចំនួន៤ដង គឺប្រើតែលុយចំនួន១០០ដុល្លារអាមេរិកដដែល។ ក្រោយមកឈ្មោះ លី សីណា បានសារភាពថា ករណីខ្លួនជាអ្នកប្រឌិតឡើង ដោយសារគាត់សតិមិនគ្រប់ភ្លេចភ្លាំងច្រើន ពីព្រោះនៅពេលគាត់ធ្វើការនៅប្រទេសម៉ាឡេស៊ីគេឱ្យប្រើថ្នាំញៀន ហើយប្តីគាត់បានប្រើអំពើហិង្សាមកលើគាត់ទៀត។ គាត់បានធ្វើការសុំទោសដល់ឯកឧត្តមអភិបាលខេត្ត និងធនាគារអេស៊ីលីដា ជាពិសេសក្រុមការងារចម្រុះខេត្ត។

១៣-ឈ្មោះ ស៊ន ថុន និងប្រពន្ធឈ្មោះ វង រឿន នៅភូមិច្រកសង្កែ ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ស្នើសុំអន្តរាគមន៍ និងជួយរកយុត្តិធម៌ជូនគាត់ ដោយឈ្មោះ ឈឹម សារី បានប្ដឹងគាត់ពីនាក់ប្ដីប្រពន្ធ និងឈ្មោះ ស្រ៊ឹម ឆេងគ័ង នៅសាលាដំបូងខេត្តកំពង់ឆ្នាំង ពីបទលួចលក់អចលនវត្ថុ និងទទួលផលចោរកម្ម។ ករណីនេះលោក ស៊ន ថុន ភាគីក ទទួលស្គាល់ថាលោក ស្រ៊ឹម ឆេងគ័ង អ្នកទិញដីពីគាត់ បានឈូសឆាយ និងជីកកាយក្រវ៉ាត់ព្រំដី ចូលក្នុងដីកម្មសិទ្ធិរបស់លោកស្រី ឈឹម សារី ផ្នែកព្រំខាងជើងទំហំ២០ម៉ែត្រx៣២០ម៉ែត្រ និងព្រំខាងត្បូងទំហំ៥ម៉ែត្រx៣២០ម៉ែត្រ។ ករណីនេះត្រូវបានដោះស្រាយចប់ដោយលោកស្រ៊ឹម ឆេងគ័ងបានប្រគល់ដីដែលបានជីកកាយហួសព្រំនេះឱ្យទៅលោកស្រី ឈឹម សារី វិញ ព្រមទាំងឈូសលុបព្រំដីដែលបានជីកលើសកន្លងមក។ លោកស្រី ឈឹម សារី ភាគីខ បានយល់ព្រមដកពាក្យបណ្ដឹងពីស្ថាប័នតុលាការ។

១៤-លោកស្រី ប៉ិច សោភី នៅភូមិដំណាក់អំពិល ឃុំក្ដុលសែនជ័យ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំងប្ដឹងឈ្មោះ ឡាយ ណារ៉េត និងឈ្មោះ ម៉េង សុធារ៉ា បានឃុបឃិតគ្នារំលោភយកដីកម្មសិទ្ធិគាត់ទំហំ៦៤.៧៥៨ ម៉ែត្រការ៉េ នៅភូមិដំណាក់អំពិល ឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ដែលមានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ០៤០៨០៦០៨-០៨៨៧។ ជាលទ្ធផលនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ ឈ្មោះ ប៉ិច សោភី បានមកដកពាក្យបណ្ដឹង ដោយអះអាងថាឈ្មោះ ម៉េង សុធារ៉ា បានដោះស្រាយគោលនយោបាយជូនគាត់ ជាប្រាក់ ចំនួន១០០០ដុល្លារអាមេរិក ហើយគាត់ក៏យល់ព្រមទទួលយកគោលនយោបាយនោះ ដើម្បីបញ្ចប់ទំនាស់ ព្រមទាំងផ្ទេរប័ណ្ណកម្មសិទ្ធិជូនឈ្មោះ ម៉េង សុធារ៉ា។

១៥-ឈ្មោះ ជុំ សូល និងប្រពន្ធឈ្មោះ ជា ផល្លី នៅភូមិតានៃ ឃុំជៀប ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំងប្តឹងឈ្មោះ កៅ អឿន និងឈ្មោះ ឈុន ហឿន នៅភូមិត្រពាំងរាំង ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំងលើបញ្ហាថតរូបគោ និងគំរាមប្រមាថសម្លាប់។ ករណីនេះត្រូវបានដោះស្រាយបញ្ចប់ទំនាស់ ដោយភាគីទាំងពីរបានធ្វើកិច្ចសន្យា ឈប់ប្តឹងផ្តល់ និងបរិហាកេរ្តិ៍គ្នាទៀតដោយសន្តិវិធី មិនទាមទារសំណងពីគ្នាទៅវិញទៅមក។

១៦-ឈ្មោះ មិន សាម៉ុន ជាប្រជាពលរដ្ឋនៅភូមិត្រពាំងចិកសា សង្កាត់កំពង់ឆ្នាំង ក្រុង កំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំងប្តឹងឈ្មោះ យឹម ឌីម ប្រពន្ធឈ្មោះកែវ ឈឿន និងឈ្មោះ ម៉ៅ សុខហេង ប្រពន្ធឈ្មោះហេង ច័ន្ទថនស្ថិតនៅភូមិ ឃុំជាមួយគ្នាដោយចោទថាពួកគេរំលោភបំពានចាក់ដីបិទប្រព័ន្ធលូរំដោះកាកសំណល់ ចេញពីរោងចក្រMV និងសង់ផ្ទះលើដីចំណីផ្លូវ នៅមុខដីរបស់គាត់។ ក្រុមការងារបានចុះត្រួតពិនិត្យ ហើយរកឃើញថា ឈ្មោះ យឹម ឌីម និងប្រពន្ធឈ្មោះ កែវ ឈឿន ពិតបានសង់ផ្ទះលើដីចំណីផ្លូវមែន។ ក្រុមការងាបានអប់រំណែនាំ និងធ្វើកិច្ចសន្យាឱ្យគាត់រុះរើផ្ទះនោះចេញ ដោយគ្មានលក្ខខណ្ឌ។ ពួកគាត់បានយល់ព្រម និងយល់ព្រមរុះរើផ្ទះចេញ។

១៧-ប្រជាពលរដ្ឋចំនួន៣០គ្រួសារ នៅភូមិព្រៃបេង ឃុំស្គុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ប្តឹងលោក អ៊ុង ចែម ជាមេភូមិ និងលោកស្រីពៅ សំពោន ជាអនុភូមិ នៅភូមិព្រៃបេង ឃុំស្គុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺដែល បានយកដីត្រពាំងទឹករួមភូមិទៅលក់ឱ្យអ្នកផ្សេង។ ករណីនេះត្រូវបានសម្របសម្រួលបញ្ចប់ទំនាស់។

១៨-ឈ្មោះ ប៊ូ ម៉ន នៅភូមិថ្មី ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះស្វាយ ហួន នៅភូមិតាប៉ង ឃុំរលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ឈ្មោះ យាយ ជួ(ហៅយាយស្រួច) នៅភូមិដក់ពរ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ឈ្មោះ អ៊ុយ កឿក ជាមេភូមិថ្មី និងឈ្មោះ ឡុង សុភាព ជាមន្ត្រីសុរិយោដីស្រុកសំរោងទង បានឃុបឃិតគ្នាចុចGPSកំណត់ព្រំចូលក្នុងប្លង់ដីរបស់គាត់ ដែលមានក្បាលដីលេខ៣៩៩។ ករណីនេះត្រូវបានសម្របសម្រួលបញ្ចប់ទំនាស់។

១៩- ឈ្មោះ ព្រំ សុភី នៅភូមិស្វាយក្រវ៉ាន់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ សូវ វុទ្ធី នៅភូមិជាមួយគ្នា ដែលបានចាក់ដីរំលោភចូលព្រំដីរបស់គាត់។ ករណីនេះត្រូវបានសម្របសម្រួលបញ្ចប់ទំនាស់។

២០- ឈ្មោះ សុខ ទូច និងឈ្មោះ សឿន សុភី (កូន) នៅភូមិអំពែភ្នំ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺប្តឹងឈ្មោះ ទៀង សៀន ប្រពន្ធឈ្មោះ ឌុច សេរី និងឈ្មោះ សៀង សុឌីណា (កូន) នៅភូមិជាមួយគ្នា ដែលបានជំទាស់មិនឱ្យក្រុមវាស់វែងជាប្រព័ន្ធចេញកម្មសិទ្ធិ ដែលមានក្បាលដីលេខ១៦៨។ ករណីនេះត្រូវបានសម្របសម្រួលបញ្ចប់ទំនាស់។

២១- ឈ្មោះ សឿន សោភ័ណ្ឌ នៅផ្ទះលេខ៦៦ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ តំណាងឱ្យដើមបណ្តឹងមាន៤គ្រួសារត្រូវជាបងប្អូនបង្កើត ប្តឹងឈ្មោះ ស៊ុំ សុផាន (ម្តាយបង្កើត) និងឈ្មោះ សឿន ប៊ុនហេង (ប្អូនបង្កើត) ដែលបានបដិសេធនូវលិខិតធ្វើអំណោយផ្តាច់ដីសង់លំនៅដ្ឋាន និងដីស្រែ ឱ្យកូនៗចំនួន៤នាក់។ ករណីនេះត្រូវបានដោះស្រាយសម្រេចរួចរាល់ហើយ។

២២- ឈ្មោះ ផាន់ សុភាវ័ន្ត និងឈ្មោះ ផាន់ សុជាវី នៅភូមិព្រៃក្តី សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ ហ៊ុយ សារឿន ហៅយាយស្រួច និងឈ្មោះ ឡេង តិចយូ (កូន) នៅភូមិស្អុះ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ពីបទមិនឱ្យពួកគាត់ឈូសឆាយលើដីកម្មសិទ្ធិលើក្បាលដីលេខ៦៤៩ និងក្បាលដីលេខ៦៥៧។ ករណីនេះត្រូវបានសម្របសម្រួលបញ្ចប់ទំនាស់។

២៣- ឈ្មោះ គៀង ឧត្តម និងប្រពន្ធឈ្មោះ ពៅ សុជាវី បច្ចុប្បន្នរស់នៅជាមួយឈ្មោះ ពៅ សោភា ត្រូវជាបង និងជាម្ចាស់ក្បាលដីលេខ១៦១ នៅភូមិកាប់ទូក សង្កាត់កណ្តោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ សែម ឃីម នៅភូមិជាមួយគ្នា និងជាម្ចាស់ក្បាលដីលេខ១៦២ ដែលបានដាក់លូលើប្រឡាយសាធារណៈ ធ្វើរបងបិតលូទឹក និងសុំផ្ទៀងផ្ទាត់ជើងម៉ែត្ររវាងក្បាលដីលេខ ១៦១ និងក្បាលដីលេខ១៦២។ ករណីនេះត្រូវបានសម្របសម្រួលបញ្ចប់ទំនាស់។

២៤- ឈ្មោះ ចែម យ៉ិល នៅភូមិត្បែង ឃុំវល្លិ៍ស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ប្តឹងអ្នកគួកដេដីចំនួន៣នាក់ មានឈ្មោះ ស៊ិន សួយ ឈ្មោះ ស៊ិន រុន នៅភូមិត្បែង និងឈ្មោះ ឱ រឿន នៅភូមិចំការរដ្ឋ ឃុំវល្លិ៍ស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺដែលមិនព្រមប្រគល់ ប្លង់ដីដែលនៅសល់មួយចំណែកទំហំ២ ៧៦៦ម៉ែត្រការ៉េ ដែលយាយរបស់គាត់ឈ្មោះ ស៊ឹម ប្រាង បានលក់ឱ្យពួកគាត់ទាំង៣នាក់។ ករណីនេះត្រូវបានសម្របសម្រួលបញ្ចប់ទំនាស់។

២៥- ឈ្មោះ ឈុន ម៉េត នៅភូមិកប់ចិន ឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ ឈូ ម៉េងទី នៅផ្ទះ៥៨A ផ្លូវលំ ភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឈ្មោះ ប៉ិច ប៊ុល នៅភូមិថ្មគោល ឃុំសំបូរ និងឈ្មោះ ម៉ៅ គួង នៅភូមិត្រពាំងកន្ទួត ឃុំសំបូរ ដែលមិនព្រមប្រគល់ប្រាក់សរុបតាមកិច្ចសន្យាទិញ-លក់ដី នៅភូមិត្រពាំងកន្ទួត ឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ ករណីនេះត្រូវបានសម្របសម្រួលបញ្ចប់ទំនាស់។

២៦- ឈ្មោះ ឌុម សុខខន និងឈ្មោះ ខេង វាស្នា នៅភូមិថ្មគោល ឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺប្តឹងឈ្មោះ ឈូ ម៉េងទី នៅផ្ទះ៥៨A ផ្លូវលំ ភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និងឈ្មោះ ប៉ិច ប៊ុល នៅភូមិថ្មគោល ឃុំសំបូរ ដែលមិនព្រមប្រគល់ប្រាក់សរុបតាមកិច្ចសន្យាទិញ-លក់ដី នៅភូមិថ្មគោល ឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ ករណីនេះត្រូវបានសម្របសម្រួលបញ្ចប់ទំនាស់។

២៧- ឈ្មោះ ឈុំ សុផល ភូមិរំលោងប្រឃ្លះ សង្កាត់សុព័រទេព ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ សាន ចន្ទី នៅភូមិរកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ មិនព្រមប្រគល់កិច្ចសន្យាទិញ-លក់ដីមកឱ្យគាត់វិញ។ ករណីនេះត្រូវបានសម្របសម្រួលបញ្ចប់ទំនាស់។

២៨- ឈ្មោះ យ៉ែម យ៉េត និងប្រពន្ធឈ្មោះ សៅ ឡូន នៅភូមិព្រៃទទឹង ឃុំហោងសំណំ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺប្តឹងឈ្មោះ សុន ថៃ បានឃុបឃិតគ្នា និងរំលោភយកដីទៅលក់ឱ្យឈ្មោះ នៅ ស និងឈ្មោះ សែម ប៊ិច នៅភូមិពាមរស់ ឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។ ករណីនេះត្រូវបានសម្របសម្រួលបញ្ចប់ទំនាស់។

## ៤. សវនកម្មផ្ទៃក្នុង

នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានបំពេញការងារដូចខាងក្រោម៖

-ចុះតាមដានអនុសាសន៍របស់សវនករ ក្នុងការិយបរិច្ឆេទ២០១៧ នៅតាមបណ្តាសវនដ្ឋានបានចំនួន១១មន្ទីរ គឺមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តស្វាយរៀង ព្រៃវែង រតនគិរី មណ្ឌលគិរី ឧត្តរមានជ័យ បន្ទាយមានជ័យ កោះកុង កំពង់ចាម តាកែវ បាត់ដំបង និងខេត្តប៉ៃលិន។

-ចុះធ្វើសវនកម្មផ្ទៃក្នុងការិយបរិច្ឆេទ២០១៨ នៅតាមទីសវនដ្ឋាន បានចំនួន១៥មន្ទីរ គឺមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកំពត កែប ព្រះសីហនុ កោះកុង កំពង់ចាម តាកែវ បាត់ដំបង ប៉ៃលិន ឧត្តរមានជ័យ សៀមរាប ព្រៃវែង មណ្ឌលគិរី រតនគិរី កំពង់ធំ និងខេត្តព្រះវិហារ។

-ធ្វើរបាយការណ៍ស្តីពីការចុះធ្វើសវនកម្ម នៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកំពត កែប ព្រះសីហនុ កោះកុង កំពង់ចាម តាកែវ បាត់ដំបង ប៉ៃលិន ឧត្តរមានជ័យ សៀមរាប ព្រៃវែង មណ្ឌលគិរី រតនគិរី កំពង់ធំ និងខេត្តព្រះវិហារ។

-រៀបចំសេចក្តីជូនដំណឹង ដល់មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តឧត្តរមានជ័យស្តីពីការកែលម្អកំហុសឆ្គងលើការអនុវត្តនីតិវិធីហិរញ្ញវត្ថុ ដែលប្រតិភូសវនកម្មផ្ទៃក្នុងរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចបានរកឃើញលើការដឹកនាំ ការគ្រប់គ្រងធនធានមនុស្ស ទ្រព្យសម្បត្តិរដ្ឋ និងការប្រើប្រាស់ចំណូល-ចំណាយថវិការដ្ឋ សម្រាប់ការិយបរិច្ឆេទ២០១៨។

-ផ្តល់អនុសាសន៍ ចែករំលែកបទពិសោធន៍ និងធ្វើការណែនាំដល់មន្ទីរទាំងអស់ ឱ្យអនុវត្តការងារបច្ចេកទេស ការដឹកនាំគ្រប់គ្រងមន្ត្រីរាជការ ការងារហិរញ្ញវត្ថុ ជាពិសេសការចំណាយផ្សេងៗ នៅក្នុងសាមីមន្ទីរឱ្យបានត្រឹមត្រូវ មានលក្ខណៈសមស្រប អនុលោមទៅតាមច្បាប់ សារាចរណែនាំផ្សេងៗ និងនីតិវិធីហិរញ្ញវត្ថុតាមបណ្តាឆ្នាំនីមួយៗ។

-នាយកដ្ឋានបានសន្និដ្ឋានថា តាមរយៈការចុះបំពេញភារកិច្ច ការគ្រប់គ្រង និងប្រើប្រាស់សម្ភារបរិក្ខារបច្ចេកទេស សង្ហារឹម និងទ្រព្យសម្បត្តិរដ្ឋដទៃទៀត របស់មន្ទីរទាំងអស់ មានលក្ខណៈល្អប្រសើរជាងបណ្តាឆ្នាំកន្លងមក។ ការងារដឹកនាំ គ្រប់គ្រង និងបែងចែកតួនាទីភារកិច្ច នៃការទទួលខុសត្រូវរបស់មន្ត្រីរាជការ នៅតាមបណ្តាមន្ទីរ បានល្អប្រសើរ។ លើសពីនេះទៀត ការគ្រប់គ្រង និងប្រើប្រាស់កញ្ចប់ថវិការបស់មន្ទីរនានា អនុវត្តបានត្រឹមត្រូវ មានការសន្សំសំចៃ ហើយសម្រេចបានល្អប្រសើ។

## ៥. វិទ្យាស្ថានជាតិអធិការកិច្ច

វិទ្យាស្ថានបានបំពេញការងារដូចខាងក្រោមៈ

-ស្នើសុំ និងទទួលបានការអនុម័តយល់ព្រម លើសារាចរស្តីពីការចាត់តាំងមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលជំនាញអធិការកិច្ចនៅវិទ្យាស្ថានជាតិអធិការកិច្ច។

-ស្នើសុំ និងទទួលបានការអនុម័តយល់ព្រម លើប្រកាសស្តីពីការកំណត់ភារកិច្ចរបស់សាស្ត្រាចារ្យ និងគ្រូឧទ្ទេសសម្រាប់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ច។

-ស្នើសុំ និងទទួលបានការអនុម័តយល់ព្រម លើសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការកំណត់អំពីកម្រិត និងប្រធានបទ សម្រាប់បណ្តុះបណ្តាលវិជ្ជាជីវៈអធិការកិច្ច។

-រៀបចំផែនការថវិកា និងផែនការសកម្មភាពឆ្នាំ២០២០ របស់វិទ្យាស្ថានជាតិអធិការកិច្ច។

-ជ្រើសរើសគ្រូបង្គោលជំនាញវិជ្ជាជីវៈអធិការកិច្ចសម្រាប់វិទ្យាស្ថានជាតិអធិការកិច្ច។

-ផ្តល់ការបណ្តុះបណ្តាលជំនាញអធិការកិច្ចបឋម ជូនមន្ត្រីរាជការ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន៨វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន៣២៧រូប (ស្ត្រីចំនួន ១២២ រូប)។

-សហការជាមួយអង្គការមូលនិធិអាស៊ី និងក្រុមហ៊ុនប្រឹក្សាយោបល់ CPS ផ្តល់ការបណ្តុះបណ្តាលស្តីពី ការកសាងសមត្ថភាពស្រាវជ្រាវជូនមន្ត្រីរាជការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន២០រូប (ស្ត្រីចំនួន៤រូប)។

-ចុះសិក្សាស្រាវជ្រាវអំពីតម្រូវការនៃការបណ្តុះបណ្តាលក្នុងវិស័យអធិការកិច្ច នៅមន្ទីរទំនាក់នងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន២០ខេត្ត។

-បានចុះស្ទង់មតិអំពីការគ្រប់គ្រង និងការអភិវឌ្ឍន៍ការងារអធិការកិច្ច នៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចតាមបណ្តាខេត្តចំនួន៧ខេត្ត។

-បានរៀបចំសំណើសុំបង្កើតគណៈកម្មការកំណត់អំពីកម្រិត និងប្រធានបទសម្រាប់បណ្តុះបណ្តាលវិជ្ជាជីវៈអធិការកិច្ច និងបានរៀបចំប្រជុំគណៈកម្មការចំនួន២លើក។

-បានរៀបចំបញ្ជីឈ្មោះអង្គការ និងស្ថានទូតប្រចាំនៅក្នុងប្រទេសកម្ពុជា ដើម្បីទំនាក់ទំនងស្នើសុំកិច្ចសហប្រតិបត្តិការ។

-បានធ្វើលិខិតទំនាក់ទំនងស្ថានទូត កូរ៉េ អូស្ត្រាលី ឥណ្ឌា សឹង្ហបូរី អាឡឺម៉ង់ ប្រចាំនៅកម្ពុជា និងអង្គការ UNDP, Konrad Adenauer Stiftung, The Asia Foundation, Asian Development Bank។

-បានជួបពិភាក្សាការងារជាមួយលោក MANOJ KUMAR PUJARI លេខាទី២ នៃស្ថានទូតឥណ្ឌាប្រចាំនៅកម្ពុជា ដើម្បីស្នើសុំសហប្រតិបត្តិការ និងការគាំទ្រដល់វិទ្យាស្ថានជាតិអធិការកិច្ច។

-បានទំនាក់ទំនង និងទទួលសៀវភៅចំនួន៣២៦ក្បាល ពីសកលវិទ្យាល័យភូមិន្ទភ្នំពេញ តាមរយៈជំនួយពីអង្គការមូលនិធិអាស៊ី។ សៀវភៅទាំងនោះត្រូវបានរៀបចំដាក់បញ្ចូលក្នុងបណ្ណាល័យ នៃវិទ្យាស្ថានជាតិអធិការកិច្ច។

-បាន និងកំពុងស្រាវជ្រាវ រៀបចំចងក្រង អនុក្រឹត្យ ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង មន្ទីរ និងវិទ្យាស្ថាននានា ដើម្បីទុកជាឯកសារ។

-បានប្រជុំពិភាក្សាជាមួយអង្គការមូលនិធិអាស៊ី ដើម្បីស្នើសុំកិច្ចសហប្រតិបត្តិការ និង ការគាំទ្រ។

-បានជួបប្រជុំពិភាក្សាជាមួយអង្គការមូលនិធិអាស៊ី ដើម្បីធ្វើកិច្ចសហប្រតិបត្តិការ និងការគាំទ្រលើការបណ្តុះបណ្តាល ស្តីពីការកសាងសមត្ថភាពស្រាវជ្រាវ ជូនមន្ត្រីរាជការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បានប្រជុំជាមួយអង្គការមូលនិធិអាស៊ី ដើម្បីជ្រើសរើសក្រុមហ៊ុនប្រឹក្សាយោបល់ សម្រាប់ផ្តល់ការបណ្តុះបណ្តាល ស្តីពីការកសាងសមត្ថភាពស្រាវជ្រាវចំនួន២លើក។

# ៦. ការងារផ្សេងទៀត

## ៦.១ យេនឌ័រ

ក្រុមការងារយេនឌ័រក្រសួងបានបំពេញការងារដូចខាងក្រោម៖

-មន្ត្រីរាជការសរុបចំនួន១ ០៧៧រូប ក្នុងនោះថ្នាក់កណ្តាល ចំនួន៥១៩រូប (ស្ត្រី ចំនួន១៥៦រូប ស្មើនឹង៣៨%) ថ្នាក់មន្ទីររាជធានី-ខេត្ត ចំនួន៤៥៨រូប (ស្ត្រី ចំនួន១១៣រូប ស្មើនឹង១៥%)។ សម្រាប់ឆ្នាំ ២០១៩ រដ្ឋលេខាធិការជាស្ត្រី ចំនួន១រូប ត្រូវបានតែងតាំង និងបានតែងតាំងមន្ត្រីរាជការជាស្ត្រី ក្នុងមុខតំណែងជាអគ្គនាយករង ចំនួន៣រូប អនុប្រធាននាយកដ្ឋាន ចំនួន៨រូប ប្រធានការិយាល័យ ចំនួន៣រូប អនុប្រធានការិយាល័យ ចំនួន៣រូប និងស្ត្រីចូលនិវត្តន៍ ចំនួន២រូប។

-បានរៀបចំអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ក្រោមប្រធានបទ «លើកកម្ពស់សមភាពយេនឌ័រ និងការគាំពារ សង្គមដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស»។

-បានប្រជុំផ្សព្វផ្សាយសេចក្តីសម្រេច ស្តីពីការកែសម្រួលសមាសភាពក្រុមការងារបច្ចេកទេសយេនឌ័រប្រចាំក្រសួង។

-បានរៀបចំសម្របសម្រួល និងចុះហត្ថលេខារួមគ្នាលើអនុស្សរណៈ នៃការយោគយល់គ្នាស្តីពីការលើកកម្ពស់សុខុមាលភាពជូនមន្ត្រីរាជការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចជាមួយមន្ទីរពេទ្យព្រះកេតុមាលា ជាលទ្ធផលនៃការអនុវត្តអនុស្សរណៈនេះ បានជួយដល់មន្ត្រីរាជការ និងសាច់ញាតិបាន ចំនួន៥រូប។

-បានស្វែងយល់អំពីបញ្ហាប្រឈម និងឧបសគ្គនានាចំពោះការអនុវត្តភារកិច្ចក្នុងតួនាទី ក្រុមការងារបច្ចេសទេសយេនឌ័រក្រសួង បានរៀបចំវេទិកាសាធារណៈស្តីពីតម្រូវការ និងបញ្ហាប្រឈមរបស់មន្ត្រីរាជការជាស្ត្រីលើកទី១ចំនួន១លើក ដោយមានមន្ត្រីរាជការជាស្ត្រីចូលរួម ចំនួន៨២នាក់។

-មន្ត្រីរាជការជាស្ត្រីដែលទទួលបានការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពក្នុងប្រទេសមាន ចំនួន ១១៥រូប និងក្រៅប្រទេស ចំនួន១រូប។

-បានរៀបចំវគ្គអប់រំផ្សព្វផ្សាយ ស្តីពីការស្វែងយល់អំពីជម្ងឺទឹមនោមផ្អែម ដោយមានមន្ត្រីរាជការជាបុរស និងស្ត្រីចូលរួម ចំនួន៨៤រូប។

-ឧបត្ថម្ភថវិកា ចំនួន៤៥ម៉ឺនរៀល ដល់មន្ត្រីរាជការជាស្ត្រីរងគ្រោះថ្នាក់ចរាចរណ៍ ចំនួន១រូប។

-ឧបត្ថម្ភថវិកា ចំនួន៦០ម៉ឺនរៀល ដល់មន្ត្រីរាជការជាស្ត្រីសម្រាលមាតុភាព ចំនួន៣រូប។

-ចូលរួមពិធីបុណ្យសពឯកឧត្តម សុខ ផល្លា ទីប្រឹក្សាក្រសួង និងជាប្រធាននាយកដ្ឋានអធិការកិច្ចទី២ នូវថវិកា ចំនួន៥០ម៉ឺនរៀល និង៤០ម៉ឺនរៀល សម្រាប់កម្រងផ្កា។

-ចូលរួមសិក្ខាសាលាពាក់ព័ន្ធនឹងការងារយេនឌ័រ ចំនួន៥លើក។

-បានរៀបចំកម្មវិធីផ្សព្វផ្សាយ ស្តីពីការស្វែងយល់ទស្សនទានយេនឌ័រជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួង ដោយមានការចូលរួម ចំនួន១៨០រូប។

-បានរៀបចំផែនការសកម្មភាពការងារបញ្ជ្រាបយេនឌ័រប្រចាំឆ្នាំ២០២០។

## ៦.២. ការចងសម្ព័ន្ធមេត្រីភាព

កាលពីថ្ងៃទី ៧ ខែមេសា ឆ្នាំ ២០១៩ គណៈប្រតិភូក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដឹកនាំដោយឯកឧត្តម **ឆេង សារឿន** រដ្ឋលេខាធិការប្រចាំការ តំណាងលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** និងក្រុមហ៊ុនម៉ុង ឫទ្ធីគ្រុប និងក្រុមហ៊ុន គូ ហ៊្វឡុង ដែលជាសម្ព័ន្ធមេត្រី បានចុះជួបសំណេះសំណាល ជាមួយអង្គភាព នគរបាលជាតិ នៃវរៈសេនាតូចលេខ៨២៧ និងវរៈសេនាតូចលេខ ២៦៩ ដែលកំពុងឈរជើងនៅភូមិសាស្ត្រ ខេត្តកោះកុង។

ការចុះសាកសួរសុខទុក្ខកងកម្លាំងប្រដាប់អាវុធនៅពេលនេះ គឺជាភស្តុតាងបញ្ជាក់ពីការយកចិត្តទុកដាក់ របស់រាជរដ្ឋាភិបាលកម្ពុជា និងវិស័យឯកជន ដែលតែងតែស្រឡាញ់កងទ័ព កងនគរបាលជាតិយើង និងបញ្ជាក់ពីចលនាស្នេហាជាតិ និងការពារជាតិ របស់ប្រជាជនយើងទាំងមូល ដែលកំពុងក្លាយជាចលនាជាតិមួយយ៉ាងខ្លាំងក្លា។

ក្នុងឱកាសនោះគណៈប្រតិភូក្រសួងបានឧបត្ថម្ភជាគ្រឿងឧបភោគបរិភោគ និងថវិកាមួយចំនួនដែលបានមកពីវិភាគទានពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួង និងសប្បុរសជនជូនដល់កងកម្លាំងនគរបាលដែលបានឈរជើងប្រចាំទិសភូមិភាគខេត្តកោះកុង ចំនួន១២៧នាក់។

## ៦.៣. ការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មាន

ក្រសួងបានបង្កើតក្រុមការងារគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មាន។ ក្រុមការងារបានប្រជុំជាច្រើនលើក ដើម្បីធ្វើផែនការ និងរៀបចំកសាងគេហទំព័រថ្មីរបស់ក្រសួង ធ្វើបច្ចុប្បន្នភាពព័ត៌មាន ដែលមានបញ្ចូលឯកសារសមិទ្ធផលក្រសួង ២០ ឆ្នាំ ឯកសារសន្និបាត ប្រចាំឆ្នាំ ចាប់ពីឆ្នាំ ២០១៨ ទៅ និងតម្លើងកម្មវិធីថ្មី (Application) សម្រាប់ដាក់ពាក្យបណ្តឹងអនឡាញ និងអ៊ីបណ្ណាល័យ។

ក្រសួងក៏បានបង្កើតក្រុមក្នុងកម្មវិធី តេឡេក្រាម ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការប្រាស្រ័យទាក់ទងគ្នាឱ្យបានឆាប់រហ័ស។

## ៦.៤. អ្នកនាំពាក្យក្រសួង

ក្រសួងបានបង្កើតអ្នកនាំពាក្យ ដើម្បីបំពេញការងារប្រតិកម្មរហ័ស ឆ្លើយតបទៅនឹងព្រឹត្តិការណ៍សំខាន់ៗ របស់ក្រសួង និងបញ្ជូនព័ត៌មានទាន់ហេតុការណ៍នានា ដាក់ក្នុងបណ្តាញផ្សព្វផ្សាយ និងគេហទំព័រក្រសួង។

## ៦.៥. ការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ

ក្រសួងបានចូលរួមយ៉ាងសកម្មក្នុងការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដូចខាងក្រោម៖

-ចូលរួមប្រជុំជាប្រចាំ និងសកម្ម ជាមួយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានទីតាំងនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-អនុវត្តសេចក្តីជូនដំណឹង និងសារាចរណែនាំស្តីពីការត្រៀម និងរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០ -២០២២ និងផែនការថវិការបស់ក្រសួង។

-ធ្វើសិក្ខាសាលាត្រួតពិនិត្យពិនិត្យការអនុវត្តន៍ថវិកាកម្មវិធីរយៈពេល៩ខែ នៅសណ្ឋាគារភ្នំពេញ។

-សហការជាមួយអ្នកបច្ចេកទេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការបំពាក់ និងតម្លើងបណ្តាញប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ (FMIS) រួមមានបណ្តាញ សឺរវើរ និងកុំព្យូទ័រ នៅក្រសួង។

-ទំនាក់ទំនងជាប្រចាំជាមួយក្រុមការងារប្រព័ន្ធ FMIS នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាំងពីចាប់ផ្តើមបង្កើត។

-បញ្ជូនក្រុមការងារប្រព័ន្ធFMISក្រសួង ទៅចូលរួមបណ្តុះបណ្តាល ការប្រើប្រាស់ប្រព័ន្ធ FMIS តាមមុខងារ នីមួយៗ ហើយចាប់ផ្តើមអនុវត្តតាំងពីថ្ងៃទី២ ខែមករា ឆ្នាំ២០២០។

-ត្រៀមខ្លួនអនុវត្តថវិកាកម្មវិធីទៅតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## គ. ការប្រឈម

### ១. ការប្រឈមក្នុងផ្នែករដ្ឋបាល កិច្ចការទូទៅ

ផ្នែករដ្ឋបាល កិច្ចការទូទៅ នៅជួបប្រទះការប្រឈមដូចខាងក្រោម៖

- ពុំទាន់បានអនុវត្តផែនការថវិកាតាមកម្មវិធីពេញលេញនៅឡើយ។ ជាក់ស្តែងក្នុងឆ្នាំ២០១៩ ប្រើប្រាស់ថវិកាកម្មវិធីបានតែថវិកាជំពូក៦១ប៉ុណ្ណោះ។
- ថវិកាបុរេប្រទាន មធ្យោបាយធ្វើដំណើររបស់រដ្ឋ និងសម្ភារបច្ចេកវិទ្យានៅមិនសមស្របសម្រាប់ចុះបេសកកម្ម។
- ការកែទម្រង់ផ្ទៃក្នុងនៅមានការលំបាក ដោយតម្រូវការចំណាយមានលើសពីគម្រោងថវិកា។
- ថវិកាក្រសួងមានទំហំតូចដែលពិបាកនឹងបំពេញភារកិច្ច ឱ្យសម្រេចបានជោគជ័យទាំងស្រុង ឬ១០០ភាគរយ។
- ចរន្តលិខិតចេញចូលនៅយឺតយ៉ាវ។
- ការផ្សព្វផ្សាយព័ត៌ាននានាមាននៅមានភាពយឺតយ៉ាវ។
- កង្វះការថែទាំ អនាម័យ និងសណ្តាប់ធ្នាប់។
- វិន័យការងារនៅមានកំរិត ដោយនៅមានអវត្តមានច្រើន។
- ការបែងចែកភារកិច្ចផ្ទៃក្នុងក្រសួង នៅមិនទាន់មានសមភាព ដោយផ្នែកខ្លះរវល់ខ្លាំង និងផ្នែកខ្លះមិនសូវមានការងារធ្វើច្រើន។
- សាមគ្គី និងឯកភាពផ្ទៃក្នុង នៅមានបញ្ហាខ្លះ។
- ពុំទាន់មានដៃគូរអភិវឌ្ឍជាតិ និងអន្តរជាតិ ជួយគាំទ្រលើវិស័យអធិការកិច្ចឱ្យបានទូលំទូលាយ។

### ២. ការប្រឈមក្នុងផ្នែកទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

- ខ្វះមធ្យោបាយធ្វើដំណើរ ជាពិសេសក្នុងបេសកកម្មផ្សព្វផ្សាយច្បាប់។
- ប្រាក់បេសកកម្ម និងប្រេងសាំងនៅមានកំរិត។
- សមត្ថភាពវិភាគ នៃការស្ទង់មតិប្រជាពលរដ្ឋទាក់ទងនឹងការយល់ដឹងពីច្បាប់ជាដើម នៅមានកំរិត។
- សមត្ថភាព តាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នានាទាក់ទងនឹងវិស័យអធិការកិច្ច នៅមានកំរិត។
- ច្បាប់អធិការកិច្ចនៅមិនទាន់បានអនុម័ត ដោយសារក្រសួង ស្ថាប័នមួយចំនួនជំទាស់នឹងបញ្ហាខ្លះដែលជាន់ភារកិច្ចគ្នា។
- បណ្ណាល័យអេឡិចត្រូនិកបានដំណើរការបណ្តើរៗហើយ តែនៅខ្វះសម្ភារៈ បច្ចេកវិទ្យា កុំព្យូទ័រ និងកៅអីសមស្រប។

## ៣. ការប្រឈមក្នុងផ្នែករអធិការកិច្ច

- ខ្វះកិច្ចសហការពីស្ថាប័នពាក់ព័ន្ធ ជាពិសេសស្ថាប័នដែលរងអធិការកិច្ច។
- ជាន់ភារកិច្ចគ្នាជាមួយស្ថាប័នមួយចំនួន ដែលបង្កឱ្យមានការលំបាកក្នុងការបំពេញភារកិច្ច។
- ការគាំទ្រ និងការលើកទឹកចិត្តលើការងារអធិការកិច្ច ពីថ្នាក់ដឹកនាំកំពូល នៅមានកំរិតនៅឡើយ។
- ការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមការងារអធិការកិច្ច និងក្រុមបេសកកម្មផ្សេងទៀតនៅមិនទាន់បានល្អត្រឹមត្រូវ។
- កង្វះមធ្យោបាយធ្វើដំណើររួម។
- ការបើកប្រាក់បេសកកម្ម និងប្រេងឥន្ធនៈនៅមានមានភាពយឺតយ៉ាវ និងភាពរអាក់រអួលខ្លះ។
- ការដោះស្រាយពាក្យបណ្តឹងនៅមានការលំបាក ដោយកង្វះកិច្ចសហការពីស្ថាប័នពាក់ព័ន្ធមានអន្តរាគមន៍ ពីអ្នកមានអំណាច និងកង្វះមធ្យោបាយ សម្ភារៈ និងការលើកទឹកចិត្ត។
- សមត្ថភាពរបស់មន្រ្តីរាជការអធិការកិច្ច និងដោះស្រាយពាក្យបណ្តឹងមួយចំនួនតូចនៅមានកម្រិត។
- កិច្ចសហការជាមួយអង្គភាពអធិការកិច្ចតាមក្រសួង រដ្ឋលេខាធិការដ្ឋាន នៅមានកម្រិត។
- សម្ភារបរិក្ខាមួយចំនួន នៅតាមនាយកដ្ឋាន ដូចជា តុ កៅអី ម៉ាស៊ីនថតចំលង ចាប់ផ្តើមដំណើរការរអាក់រអួល និងចាស់ទ្រុឌទ្រោមជាបន្តបន្ទាប់ ហើយការដោះស្រាយនៅមានភាពយឺតយ៉ាវ។
- របាយការណ៍អធិការកិច្ចមិនទាន់ឯករាជ្យ ដោយតម្រូវឱ្យឆ្លងប្រធានស្ថាប័ន ឬប្រធានអង្គភាពរងអធិការកិច្ច ចុះហត្ថលេខាយល់ព្រមលើលទ្ធផលអធិការកិច្ច។

# ឃ. ទិសដៅការងារបន្ត

ដើម្បីចូលរួមអនុវត្តតាមយុទ្ធសាស្រ្តចតុកោណតំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា និងផែនការសកម្មភាពរបស់ខ្លួន ក្រសួងមានទិសដៅ គោលនយោបាយ និងយុទ្ធសាស្រ្តច្បាស់លាស់ដោយបំពេញភារកិច្ច តាមបេសកកម្មតួនាទី ភារកិច្ច ការទទួលខុសត្រូវរបស់ខ្លួនស្របតាមសភាពការណ៍ជាក់ស្តែង ប្រកបដោយប្រសិទ្ធភាព និងស្មារតីទទួលខុសត្រូវខ្ពស់ដោយត្រូវផ្តោតលើសកម្មភាពអាទិភាពដូចខាងក្រោម៖

## ១.រដ្ឋបាលកិច្ចការទូទៅ

### ១.១. រដ្ឋបាល

លើផ្នែករដ្ឋបាល ក្រសួងត្រូវ៖

-បន្តទំនាក់ទំនងកិច្ចសហការជាមួយរដ្ឋបាលថ្នាក់កណ្តាល គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេសជាមួយរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី។

-បន្តគ្រប់គ្រងកិច្ចការរដ្ឋបាលក្រសួងឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងបន្តកែលម្អ ដោយសម្របសម្រួលគ្រប់បណ្តាអង្គភាព និងមន្ទីររាជធានី-ខេត្ត ជាពិសេសបន្តចូលរួមគ្រប់កំណែទម្រង់រដ្ឋបាលសាធារណៈស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

-បន្តអនុវត្តចរន្តការងាររដ្ឋបាលឱ្យកាន់តែប្រសើរ។

-បន្តទំនាក់ទំនងជាមួយគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ក្នុងការចូលរួមពិធីបុណ្យជាតិ អន្តរជាតិ និងពិធីបុណ្យផ្សេងៗទៀត។

## ១.២. បុគ្គលិក និងធនធានមនុស្ស

លើផ្នែកបុគ្គលិក ក្រសួងត្រូវ៖

-បន្តទំនាក់ទំនង និងសម្របសម្រួលជាមួយក្រសួងមុខងារសាធារណៈលើការងារបុគ្គលិក និងធនធានមនុស្ស។

-បន្តអនុវត្តនូវរាល់ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ លិខិតបទដ្ឋានគតិយុត្តផ្សេងៗរបស់រាជរដ្ឋាភិបាល។

-បន្តធ្វើទំនាក់ទំនងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពាក់ព័ន្ធនឹងការដាក់មន្ត្រី រាជការឱ្យចូលនិវត្តន៍ បាត់បង់សម្បទាវិជ្ជាជីវៈ ឬបាត់បង់សមត្ថភាពការងារ។

-ពង្រឹងការងារពិនិត្យផ្តល់ទិដ្ឋាការលើរបាយការណ៍ស្តីពីស្ថានភាពរដ្ឋបាល និងស្ថានភាពប្រែប្រួលរបស់មន្ត្រីរាជការថ្នាក់រាជធានី-ខេត្តឱ្យបានទាន់ពេលវេលា។

## ១.៣. ហិរញ្ញវត្ថុ និងផ្គត់ផ្គង់

លើផ្នែកហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ក្រសួងត្រូវ៖

-បន្តទំនាក់ទំនងការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារជាតិ និងធនាគារជាតិ ក្នុងកិច្ចការស្នើសុំថវិកានានាតាមខ្ទង់ ជំពូក ដើម្បីបម្រើការងារក្រសួងឱ្យដំណើរការល្អប្រសើរដូចជាថវិកាសម្រាប់បៀវត្ស ដំណើរការរដ្ឋបាលទូទៅ បេសកកម្មក្នុងប្រទេស និងក្រៅប្រទេស។ល។

-បន្តទំនាក់ទំនងការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារជាតិ និងធនាគារជាតិ ក្នុងកិច្ចការស្នើសុំថវិកានានាតាមខ្ទង់ តាមជំពូក តាមសកម្មភាព ចង្កោមសកម្មភាព អនុកម្មវិធី នៃកម្មវិធីដើម្បីបម្រើការងារក្រសួងឱ្យដំណើរការល្អប្រសើរ ដូចជាថវិកាសម្រាប់ការងារបៀវត្សដំណើរការរដ្ឋបាលទូទៅ និងបេសកកម្មក្នុងប្រទេស ។ល។

-ចុះកិច្ចបញ្ជិកាគណនេយ្យជាប្រចាំ និងគ្រប់គ្រងព័ត៌មានវិទ្យាសកម្មភាពហិរញ្ញវត្ថុ គ្រប់គ្រងចំណូល ចំណាយ ឱ្យបានសមស្រប។

-ប្រមូលផ្តុំ និងសម្របសម្រួលជំពូកថវិកាឱ្យសមស្របតាមគម្រោងថវិការដ្ឋ ប្រមូលផ្តុំតម្រូវការ និងសម្របសម្រួលរាល់ការចំណាយ។

-ត្រួតពិនិត្យបច្ចេកទេសនូវការអនុវត្តលទ្ធកម្មសាធារណៈ។

-គ្រប់គ្រង និងត្រួតពិនិត្យជាប្រចាំនូវសន្និធិ។

-ទទួលបែងចែក និងជួសជុល សម្ភារ បរិក្ខារ ជូនបណ្តាអង្គភាពក្រោមឱវាទក្រសួងឱ្យបានសមស្រប និងទាន់ពេលវេលា។

-គ្រប់គ្រង និងបែងចែកប្រេងឥន្ធនៈឱ្យបានសមស្រប និងទាន់ពេលវេលា ជាពិសេសសម្រាប់បេសកកម្ម ឱ្យបានមុនពេលចេញដំណើរ។

-គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ និងធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យរដ្ឋ។

-អនុវត្តកម្មវិធីព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)

### ១.៤. ផែនការ និងស្ថិតិ

លើផ្នែកផែនការ និងស្ថិតិ ក្រសួងត្រូវ៖

-បន្តរៀបចំផែនការថវិកាប្រចាំឆ្នាំ២០២០ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-ត្រៀមរៀបចំរបាយការណ៍សមិទ្ធកម្មស្តីពីលទ្ធផលនៃការអនុវត្តថវិកាឆមាសទី១ឆ្នាំ២០១៩ ដើម្បីបូកសរុបជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-ចុះណែនាំការរៀបចំផែនការយុទ្ធសាស្រ្តថវិកា និងផែនការថវិកាប្រចាំឆ្នាំ២០២០ របស់ក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បន្តបញ្ចូលទិន្នន័យស្ថិតិផ្លូវការដែលមានការចាត់តាំងតាមវិស័យ និងពិនិត្យឡើងវិញជាបណ្តើរៗ។

-ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីសម្រាប់ការិយាល័យដើម្បីអនុវត្តឆ្នាំ២០១៩។

-រៀបចំតារាងតាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។

-ត្រៀមចូលរួមវគ្គបណ្តុះបណ្តាលលើការងារកសាងផែនការឱ្យកាន់តែមានប្រសិទ្ធភាព។

### ១.៥. សហប្រតិបត្តិការអន្តរជាតិ

លើផ្នែកសហប្រតិបត្តិការអន្តរជាតិ ក្រសួងត្រូវ៖

-បន្តទំនាក់ទំនង និងសហប្រតិបត្តិការជាមួយស្ថានទូតចិន និងក្រសួងត្រួតពិនិត្យនៃសាធារណរដ្ឋប្រជាមានិតចិន និងអធិការកិច្ចរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីត្រៀមជំរុញអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងស្ថាប័នទាំងពីរ។

-បន្តសហការជាមួយវិទ្យាស្ថានសន្ទនាមេគង្គ(MDI) និងវិទ្យាស្ថានខុងជឺ នៃរាជបណ្ឌិត្យសភាកម្ពុជា។

-បន្តទំនាក់ទំនងពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍។

-បន្តទំនាក់ទំនងជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

-បន្តការសិក្សាស្រាវជ្រាវបណ្តាប្រទេសជាសមាជិកអាស៊ាន និងអង្គការអន្តរជាតិ។

-ត្រៀមចូលរួមអនុវត្តការងារដែលថ្នាក់ដឹកនាំប្រគល់ជូន។

## ២. ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

### ២.១. នីតិកម្ម

លើផ្នែកនីតិកម្ម ក្រសួងត្រូវ៖

-រៀបចំផែនការសកម្មភាពការងារដើម្បីចុះស្ទង់មតិប្រជាពលរដ្ឋស្តីពីការយល់ដឹងលើច្បាប់ នៅតាមបណ្តាខេត្តនានា។

-ស្រាវជ្រាវប្រមូលឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីបញ្ចូលក្នុងគេហទំព័របណ្ណាល័យអេឡិចត្រូនិចក្រសួង។

-ចូលរួមរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង និងអន្តរក្រសួង។

### ២.២. ការអប់រំផ្សព្វផ្សាយច្បាប់

លើអប់រំ ផ្សព្វផ្សាយច្បាប់ ក្រសួងត្រូវ៖

-រៀបចំផែនការសកម្មភាព និងទំនាក់ទំនងជាមួយអាជ្ញាធររាជធានី-ខេត្ត ដើម្បីធ្វើការផ្សព្វផ្សាយច្បាប់។

-រៀបចំផែនការសកម្មភាពដើម្បីចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃមុន និងក្រោយការផ្សផ្សាយច្បាប់។

-សិក្សាស្រាវជ្រាវឯកសារ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនិងច្បាប់។

-សហការជាមួយនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ដើម្បីរៀបចំបោះពុម្ពអត្ថបទច្បាប់។

### ២.៣. ទំនាក់ទំនងរវាងរាជរដ្ឋាភិបាល និងរដ្ឋសភា-ព្រឹទ្ធសភា

លើផ្នែកទំនាក់ទំនងរវាងរាជរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា ក្រសួងត្រូវ៖

-ចូលរួមប្រជុំអន្តរក្រសួង និងតាមក្រសួង-ស្ថាប័ន។

-ចូលរួមស្តាប់សម័យប្រជុំពេញអង្គ វិសាមញ្ញ នៅមន្ទីររដ្ឋសភា-ព្រឹទ្ធសភា។

-ចុះអមដំណើរជាមួយតំណាងរាស្ត្រ និងគណៈកម្មការនានានៃរដ្ឋសភាជាតិ។

-ចុះអមដំណើរជាមួយគណៈកម្មការនានា ក្រុមសមាជិកព្រឹទ្ធសភាតាមភូមិភាគ និងក្រុមសមាជិកសមាជិកា នៃព្រឹទ្ធសភា។

-រៀបចំផែនការសកម្មភាពចុះធ្វើវេទិកាសាធារណៈ ដើម្បីទទួលសំណូមពរពីប្រជាពលរដ្ឋ។

## ៣. អធិការកិច្ច

### ៣.១. អធិការកិច្ច (លើវិស័យសេដ្ឋកិច្ច រដ្ឋបាលទូទៅ និង សង្គមកិច្ច)

លើផ្នែកអធិការកិច្ច ក្រសួងត្រូវ៖

-បន្តអនុវត្តការងារអធិការកិច្ចដែលពុំទាន់បានធ្វើចប់ក្នុងឆ្នាំ២០១៩។

-អនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០២០។

-ពង្រឹងការងារគ្រប់គ្រងរដ្ឋបាល និងចងក្រងគំរូឯកសារសម្រាប់ត្រៀមលក្ខណៈសម្បត្តិដើម្បីអនុវត្តថវិកាតាមកម្មវិធី។

-រៀបចំ និងកែសម្រួលផែនការប្រតិបត្តិការអធិការកិច្ចឱ្យស្របតាមស្ថានភាពការងារជាក់ស្តែង។

-ប្រមូលចងក្រងឯកសារគតិយុត្តទាំងឡាយដែលមានប្រយោជន៍ដល់ការងារអធិការកិច្ច។

-រៀបចំផែនការសកម្មភាព និងផែនការថវិកាឆ្នាំ២០២១។

-បណ្តុះបណ្តាលមន្ត្រីអធិការកិច្ចតាមរយៈការផ្លាស់ប្តូរបទពិសោធន៍គ្នា។

-អនុវត្តការងារផ្សេងទៀតតាមការសម្រេចរបស់ថ្នាក់ដឹកនាំក្រសួង។

### ៣.២.ការតាមដានការអនុវត្តច្បាប់

លើផ្នែកតាមដានការអនុវត្តច្បាប់ ក្រសួងត្រូវ៖

-បន្តចុះតាមដានត្រួតពិនិត្យរាល់ការអនុវត្តច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងអនុសាសន៍របស់នាយករដ្ឋមន្ត្រី ដែលមិនទាន់បានធ្វើចប់ក្នុងឆ្នាំ២០១៩។

-ស្រាវជ្រាវ ប្រមូល និងចងក្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់ចុះតាមដាន។

-អនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០២០។

-ត្រៀមរៀបចំសេចក្តីជូនដំណឹងស្តីពីការជំរុញកែលម្អលើចំណុចខ្វះខាត ទៅបណ្តាក្រសួង និងស្ថាប័ន។

-អនុវត្តភារកិច្ចផ្សេងៗទៀតតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង។

### ៣.៣. ការទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ

លើផ្នែកទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ ក្រសួងត្រូវ៖

-បន្តទទួលពាក្យបណ្តឹងពីគ្រប់មជ្ឈដ្ឋាននានា រួមទាំងពាក្យបណ្តឹងក្នុងសារព័ត៌មានផងដែរ។

-ត្រៀមខ្លឹមសារឯកសារ "នីតិវិធីនៃការដាក់ពាក្យបណ្តឹង និងការដោះស្រាយពាក្យបណ្តឹង" ដើម្បីដាក់ឆ្លងថ្នាក់ដឹកនាំក្រសួង និងបង្ហោះក្នុងវិបសាយក្រសួង។

-រង់ចាំការអនុញ្ញាតពីថ្នាក់ដឹកនាំក្រសួង ដើម្បីជំរុញការអនុវត្តលទ្ធផលពាក្យបណ្តឹង ដែលបានបញ្ជូនទៅគ្រប់ស្ថាប័ន និងបណ្តារាជធានី-ខេត្តកន្លងមក។

-បន្តនឹងត្រៀមចុះអង្កេតស្រាវជ្រាវពាក្យបណ្តឹងដែលជាសមត្ថកិច្ចក្រសួង។

-អនុវត្តការងារតាមផែនការសកម្មភាព ឆ្នាំ២០២០។

-អនុវត្តភារកិច្ចផ្សេងៗទៀតតាមការសម្រេចរបស់ថ្នាក់ដឹកនាំក្រសួង។

### ៣.៤.ការពង្រឹងស្ថាប័ន និងគ្រប់គ្រងមន្ត្រីរាជការ

លើផ្នែកពង្រឹងស្ថាប័ន និងគ្រប់គ្រងមន្ត្រីរាជការ ក្រសួងត្រូវ៖

-បន្តការងារបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច។

-បន្តពង្រឹងការគ្រប់គ្រងវត្តមាន និងអវត្តមានមន្ត្រីរាជការ។

-បន្តពង្រឹងរបៀបរបបធ្វើការងារ។

-បន្តចូលរួមប្រជុំការងារក្នុងក្រសួង និងអន្តរក្រសួងតាមការអញ្ជើញ និងចាត់តាំងរបស់ថ្នាក់ដឹកនាំក្រសួង។

-បន្តប្រជុំពង្រឹងរបៀបរបបការងារប្រចាំខែ ស្របតាមសេចក្តីកំណត់ស្តីពីការបែងចែកភារកិច្ច និងរបៀបរបប ការងាររបស់អគ្គនាយកដ្ឋានអធិការកិច្ច។

-បន្តបណ្តុះបណ្តាលផ្ទៃក្នុងអគ្គនាយកដ្ឋានទាំងអស់។

## ៤.សវនកម្មផ្ទៃក្នុង

ក្រសួងត្រូវបន្តអនុវត្តការងាររបស់ខ្លួនស្របតាមអនុក្រឹត្យលើលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃសវនកម្មផ្ទៃក្នុងនៅតាមស្ថាប័នក្រសួង និងសហគ្រាសសាធារណៈ និងប្រកាសលេខ០៧៣ ទរពអ.ប្រក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥

ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ ចំណុះនាយកដ្ឋាននៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

## ៥. វិទ្យាស្ថានជាតិអធិការកិច្ច

ដើម្បីឈានឆ្ពោះទៅរកការសម្រេចឲ្យបានផែនការក្រសួង វិទ្យាស្ថានជាតិអធិការកិច្ចកំណត់យកទិសដៅការងារជាយុទ្ធសាស្ត្រចំនួន៨ដូចខាងក្រោម៖

-កសាងលិខិតបទដ្ឋានគតិយុត្ត និងយន្តការពាក់ព័ន្ធ៖

+រៀបចំបទបញ្ជាផ្ទៃក្នុងរបស់វិទ្យាស្ថានជាតិអធិកាតកិច្ច។

+រៀបចំវិធីសាស្ត្រនៃការជ្រើសរើសសិក្ខាកាម គ្រូឧទ្ទេស និងសាស្ត្រាចារ្យ។

+រៀបចំក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនអធិការកិច្ច។

+រៀបចំយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃ។

+រៀបចំលិខិតបទដ្ឋានផ្សេងៗទៀតដែលចាំបាច់។

-អភិវឌ្ឍស្ថាប័ន និងរចនាសម្ព័ន្ធគ្រប់គ្រង៖

+ពង្រឹងសមត្ថភាពមន្ត្រីរាជការវិទ្យាស្ថានជាតិអធិការកិច្ច។

+ស្នើសុំសម្ភារបរិក្ខារសម្រាប់និរន្តរភាពវិទ្យាស្ថានជាតិអធិការកិច្ច បណ្ណាល័យ និងរោងពុម្ព។

+ស្នើសុំមធ្យោបាយធ្វើដំណើរសម្រាប់វិទ្យាស្ថានជាតិអធិការកិច្ច។

+រៀបចំបង្កើតប្រព័ន្ធព័ត៌មានវិទ្យារបស់វិទ្យាស្ថានជាតិអធិការកិច្ច។

+បង្កើតក្រុមប្រឹក្សាភិបាលរបស់វិទ្យាស្ថានជាតិអធិការកិច្ច។

+រៀបចំក្រុមគ្រូបង្គោលជំនាញវិជ្ជាជីវៈអធិការកិច្ចសម្រាប់ការបណ្តុះបណ្តាល។

+ស្នើសុំជ្រើសរើសក្របខ័ណ្ឌមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាសម្រាប់វិទ្យាស្ថានជាតិអធិការកិច្ច។

-ពង្រឹងការគ្រប់គ្រងការងាររដ្ឋបាល និងហិរញ្ញវត្ថុ៖

+ពង្រឹងការគ្រប់គ្រងចំណូល ចំណាយ ផ្គត់ផ្គង់សម្ភារបរិក្ខារ និងសារពើភ័ណ្ឌរបស់វិទ្យាស្ថានជាតិអធិការកិច្ច។

+ពង្រឹងការគ្រប់គ្រងបុគ្គលិក ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភរបស់សាស្ត្រាចារ្យ និងគ្រូ។

+ពង្រឹងការគ្រប់គ្រងសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងអនាម័យរបស់វិទ្យាស្ថានជាតិអធិការកិច្ច។

-ពង្រឹងការងារផែនការ និងស្រាវជ្រាវ៖

+ធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្ររបស់វិទ្យាស្ថានជាតិអធិការកិច្ច។

+រៀបចំផែនការសកម្មភាពរបស់វិទ្យាស្ថានជាតិអធិការកិច្ច។

+រៀបចំផែនការថវិការបស់វិទ្យាស្ថានជាតិអធិការកិច្ច។

+ប្រមូលផ្តុំចងក្រងឯកសារពាក់ព័ន្ធនឹងវិស័យអធិការកិច្ច។

+បកប្រែឯកសារសំខាន់ៗពាក់ព័ន្ធនឹងវិស័យអធិការកិច្ច។

+តាមដានអំពីវឌ្ឍនភាព និងប្រសិទ្ធភាពការងារមន្ត្រីរាជការ ដែលទទួលបានការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈអធិការកិច្ច។

+ស្ទង់មតិអំពីការគ្រប់គ្រង និងការអភិវឌ្ឍន៍ការងារអធិការកិច្ច។

+សិក្សាស្រាវជ្រាវអំពីយន្តការ និងរចនាសម្ព័ន្ធអធិការកិច្ច(តាមលទ្ធភាពជាក់ស្ដែង)។

+សិក្សាស្រាវជ្រាវអំពីការដោះស្រាយបណ្ដឹងតវ៉ា និងបណ្ដឹងបរិហារ(តាមលទ្ធភាពជាក់ស្ដែង)។

+សិក្សាស្រាវជ្រាវអំពីទស្សនៈទូទៅពាក់ព័ន្ធនឹងការងារអធិការកិច្ច(តាមលទ្ធភាពជាក់ស្ដែង)។

+សិក្សាស្រាវជ្រាវអំពីការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានា (តាម លទ្ធភាពជាក់ស្ដែង)។

+រៀបចំសិក្ខាសាលាពិគ្រោះយោបល់ និងផ្សព្វផ្សាយផែនការ យុទ្ធសាស្ត្រ របស់វិទ្យាស្ថានជាតិអធិការកិច្ច(តាមលទ្ធភាពជាក់ស្ដែង)។

-ការងារបណ្ដុះបណ្ដាល៖

+រៀបចំ និងកែលម្អកម្មវិធីបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈអធិការកិច្ច។

+ផ្ដល់ការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈអធិការកិច្ចដល់មន្ត្រីរាជការទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

-ការងារទំនាក់ទំនងសាធារណៈ៖

+ពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្ដាប្រទេសនានា។

+ពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍។

+ពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សា។

# ៦. ការងារផ្សេងៗ

## ៦.១. យេនឌ័រ

លើផ្នែកយេនឌ័រ ក្រសួងត្រូវ៖

-បន្តផ្សព្វផ្សាយអនុសញ្ញាស៊ី-ដ និងអនុសាសន៍ជាគន្លឹះរបស់សម្ដេចតេជោ នាយករដ្ឋមន្ត្រី។

-ធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ បញ្ជ្រាបយេនឌ័រ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បន្តផ្សព្វផ្សាយអំពីស្វែងយល់ទស្សនទានយេនឌ័រ។

-ផ្សព្វផ្សាយអំពីការបញ្ជ្រាបយេនឌ័រ។

-ផ្ដល់វគ្គបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពដល់ស្ត្រីដែលមានតួនាទី។

-បន្តរៀបចំវេទិកាសាធារណៈស្ដីពីតម្រូវការ និងបញ្ហាប្រឈមរបស់មន្ត្រីរាជការជាស្ត្រី។

-បន្តរៀបចំវេទិកាសុខភាព ដោយសហការជាមួយមន្ទីរពេទ្យព្រះកេតុមាលា។

-បន្តជំរុញការអនុវត្តផែនការបញ្ជ្រាបយេនឌ័រ ឱ្យកាន់តែមានប្រសិទ្ធភាពតាមវិស័យទាំងបីនៅថ្នាក់ក្រសួង និងនៅតាមមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្ត។

-រៀបចំផ្តល់ប័ណ្ណសរសើរ និងរង្វាន់ជូនមន្ត្រីរាជការ ដែលជាប់ចំណាត់ថ្នាក់ឆ្នើមក្នុងការជម្រុញយេនឌ័រ។

-បន្តសហប្រតិបត្តិការជាមួយក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការងារយេនឌ័រឱ្យដំណើរការទទួលលទ្ធផលខ្ពស់។

### ៦.២.ការចងសម្ព័ន្ធមេត្រីភាព

ក្រសួងនឹងចូលរួមយ៉ាងសកម្មថែមទៀត ក្នុងការពង្រឹងសម្ព័ន្ធមេត្រីភាព ជាមួយកងវរសេនាតូចនគរបាលព្រំដែន ទាំងពីរអង្គភាព ឱ្យកាន់តែជិតស្និទ្ធ ក្នុងន័យផ្តល់កម្លាំងចិត្ត និងសម្ភារ ដើម្បីបង្កើនជីវភាពរស់នៅរបស់គាត់ឱ្យកាន់តែមានភាពប្រសើរឡើង និងដើម្បីរួមចំណែកថែរក្សាការពារទឹកដីរបស់យើងឱ្យមានសុខសន្តិភាពយូរអង្វែងតរៀងទៅ។

### ៦.៣. ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

-ត្រៀមខ្លួនអនុវត្តថវិកាកម្មវិធីទៅតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

-បន្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបណ្តើរៗជាជំហានៗ ដើម្បីអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យបានជោគជ័យ។

-អនុវត្តការគ្រប់គ្រងថវិកាក្រសួង តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដែលចាប់ផ្តើមអនុវត្តពីថ្ងៃទី ២ ខែមករា ឆ្នាំ២០២០។

## ខ.សេចក្តីសន្និដ្ឋាន

ដោយសារមានផែនការ ច្បាស់លាស់ ក្រសួងបានបំពេញភារកិច្ច ប្រកបដោយទទួលខុសត្រូវខ្ពស់ និងមានប្រសិទ្ធភាព និងជោគជ័យ ទោះជាការងារខ្លះមានការលំបាក ស្មុគស្មាញមានភាពរសើប និងភាពចំរូងចម្រាស់ក្តី។ សមិទ្ធផលការងារ ដូចបានរៀរាប់ខាងដើមបានមកដោយសារមានការដឹកនាំប្រកបដោយបញ្ញាញាណដ៏ភ្លឺស្វាង និងវាងវៃ របស់លោកជំទាវឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី និងដោយសារថ្នាក់ដឹកនាំ មន្ត្រីរាជការ មានសមត្ថភាពពេញលេញ និងជំនាញច្បាស់លាស់ និងមានការយល់ដឹងផ្នែកច្បាប់ ព្រមទាំងក្រមសីលធម៌ស្អាតស្អំ។

ជាការពិត បុគ្គល និងស្ថាប័នមួយចំនួនមិនចូលចិត្ត មិនសប្បាយចិត្ត និងមិនផ្តល់កិច្ចសហការពេញលេញដល់ក្រុមការងារក្រសួង ជាពិសេសក្រុមការងារអធិការកិច្ច ដែលត្រូវចុះទៅបំពេញបេសកកម្ម នៅតាមស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រោះទី១ គេខ្លាចខាតពេលវេលាដ៏មមាញឹករបស់គេ និងគ្មានពេលគ្រប់គ្រាន់ ទទួលក្រុមបេសកកម្មយើង ទី ២ គេមានចំណុចខ្វះខាត ដែលនាំឱ្យគេខ្លាចយើងរកឃើញកំហុសឆ្គងនានា ដែលអាចនាំបញ្ហាធំដល់ពួកគាត់។ ទន្ទឹមនឹងនេះ ក្រសួងនៅមានការប្រឈមជាច្រើន ដូចជានៅតាមស្ថាប័នរដ្ឋមួយចំនួន មិនទាន់ឱ្យតម្លៃការងារអធិការកិច្ច និងមិនចង់សហការ និងមានក្រសួង ស្ថាប័នរដ្ឋមួយចំនួន មានភារកិច្ចស្រដៀងគ្នា ឬជាន់គ្នា ដូចជាគណៈកម្មាធិការដោះស្រាយទំនាស់ដីធ្លី អង្គភាពប្រឆាំងអំពើពុករលួយ អាជ្ញាធរសវនកម្មជាតិ និងអគ្គាធិការដ្ឋាន នៃក្រសួងស្ថាប័នមួយ

ចំនួនទៀត។ ម្យ៉ាងទៀតការអនុវត្តក្រមសីលធម៌របស់ក្រុមការងារចុះធ្វើបេសកកម្មអធិការកិច្ចមួយចំនួនតូច នៅមានការខ្វះខាត និងជួបបញ្ហាខ្លះ។

ទោះជាយ៉ាងនេះក្តី ក៏ក្រសួងបានជម្នះ និងបំពេញតួនាទីទៅតាមច្បាប់អនុញ្ញាត ហើយយើងបានឃើញច្បាស់ថា ការងាររបស់យើង ពិតជាជួយជានាការពង្រឹងប្រសិទ្ធភាពការងារស្ថាប័ន អង្គភាពរដ្ឋ ធានាសុវត្ថិភាព និងសិទ្ធិសេរីភាពជូនប្រជាពលរដ្ឋ និងនាំមកនូវតម្លាភាព កាត់បន្ថយបាននូវបាតុភាពអសកម្មនានា ដូចជាតម្រូវឱ្យអនុវត្តកិច្ចសន្យា រវាងក្រុមហ៊ុននានា ជាមួយរដ្ឋបានល្អ ជួយកាត់បន្ថយ និងលុបបំបាត់ការកេីបកេង និងការប្រេីប្រាស់ទ្រព្យសម្បត្តិរដ្ឋខុសទិសដៅជាដើម។

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចបានតម្រង់ទិស និងណែនាំឱ្យក្រសួងស្ថាប័ន និងអង្គភាពរដ្ឋ បង្កើនការប្រុងប្រយ័ត្ន និងទទួលខុសត្រូវខ្ពស់ ក្នុងសកម្មភាពការងាររបស់ខ្លួន ស្របតាមការកែទម្រង់ស៊ីជម្រៅ ការពង្រឹងនីតិរដ្ឋ និងអភិបាលកិច្ចល្អ។ ដូច្នេះការងារអធិការកិច្ច ពិតជាមានសារៈសំខាន់មិនអាចខ្វះបាន ដើម្បីបម្រើឱ្យផលប្រយោជន៍ជាតិ និងប្រជាពលរដ្ឋយើង ក្នុងពេលដែលព្រះរាជាណាចក្រកម្ពុជា ទទួលបានសន្តិភាពយ៉ាងពិតប្រាកដ និងការអភិវឌ្ឍន៍លើគ្រប់វិស័យ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលមាន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រមុខ។

លទ្ធផលដែលសម្រេចបានកន្លងមកនេះបានធ្វើឱ្យតួនាទីភារកិច្ច ការទទួលខុសត្រូវរបស់ក្រសួងមានសារៈសំខាន់ និងរួមចំណែកដល់ការជំរុញអភិបាលកិច្ចល្អ។ កត្តាជាគន្លឹះដែលនាំឱ្យសម្រេចបាននូវលទ្ធផលខាងលើ គឺដោយសារមានការគាំទ្រ និងការដឹកនាំប្រកបដោយបញ្ញាញាណដ៏ត្រឹមត្រូវ និងភ្លឺស្វាងរបស់លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ដែលតែងតែផ្តល់យោបល់ ការណែនាំ តម្រង់ទិសល្អៗ និងនៅជិតស្និទ្ធ ជាមួយថ្នាក់ដឹកនាំ និងមន្ត្រី រាជការក្រសួង។

លើសពីនេះក្រសួងដំណើរការទៅប្រកបដោយប្រសិទ្ធភាព និងជោគជ័យ អាស្រ័យដោយមានការដឹកនាំ ប្រកបដោយភាពឈ្លាសវៃរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលតែងតែគាំទ្ររាល់សកម្មភាពការងាររបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខិតខំពុះពាររាល់ការលំបាក ប្រឹងប្រែងអនុវត្តការងារប្រកបដោយប្រសិទ្ធភាព សមត្ថភាព និងមនសិការទទួលខុសត្រូវ ខ្ពស់ ក៏ដោយសារមានការគាំទ្រ និងកិច្ចសហការល្អពីគ្រប់មជ្ឈដ្ឋាន ទាំងស្ថាប័នរដ្ឋ ស្ថាប័នមិនមែនរដ្ឋ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋទូទាំងប្រទេស។

ក្នុងឆ្នាំ២០២០ខាងមុខ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច គ្រប់លំដាប់ថ្នាក់ នឹងខិតខំប្រឹងប្រែងជាបន្តទៀត ដើម្បីដោះស្រាយ និងកាត់បន្ថយឱ្យបានជា អតិបរមា នូវចំណុចខ្វះខាតរបស់ក្រសួង ក៏ដូចជាបាតុភាពអសកម្មនានាដែលកើតមានក្នុងសង្គម។ ក្រសួងសូមស្នើ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួង ស្ថាប័ននានា រដ្ឋបាលដែនដីគ្រប់លំដាប់ថ្នាក់ សហគមន៍ និងប្រជាពលរដ្ឋ សូមបន្តចូលរួមសហការ ឱ្យកាន់តែល្អប្រសើរថែមទៀត ដើម្បីសម្រេចបានជោគជ័យ និងសមិទ្ធផលថ្មីៗ បន្ថែមទៀត ជូនជាតិមាតុភូមិនៃយើង។

# ឧបសម្ព័ន្ធ ១. កម្មវិធីសន្និបាត

## កម្មវិធី

### សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និង ទិសដៅការងារ ឆ្នាំ២០២០
### របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

សណ្ឋាគារសុខាភ្នំពេញ ថ្ងៃច័ន្ទទី២០ ខែមករា ឆ្នាំ២០២០

| ម៉ោង | កម្មវិធី | គណៈអធិបតី/ថ្នាក់ដឹកនាំ |
|---|---|---|
| **ពេលព្រឹក** | | |
| ៧:៣០ - ៨:០០ | សមាជិក សមាជិកា សន្និបាតមកដល់ និងចុះឈ្មោះ | |
| ៨:០០ - ៨:៣០ | ថ្នាក់ដឹកនាំ ភ្ញៀវកិត្តិយសអញ្ជើញដល់ | |
| ៨:៣០ | លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន**<br>ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ អញ្ជើញដល់ | |
| ៨:៣០ - ៩:១៥ | **ពិធីបើកសន្និបាត**<br>- ប្រកាសហេតុ (គណៈអធិបតី និងសមាជិកសន្និបាត)<br>- គោរពភ្លេងជាតិ នៃព្រះរាជាណាចក្រកម្ពុជា<br>- សុន្ទរកថាបើកសន្និបាតដោយ **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ<br>- អានរបាយការណ៍សង្ខេបស្តីពីលទ្ធផលការងារឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០របស់ក្រសួងទរពអ ដោយ **ឯកឧត្តមបណ្ឌិត ចាប សុថារិទ្ធ** រដ្ឋលេខាធិការ | -លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ<br>ឯកឧត្តម ឆេង សារឿន<br>ឯកឧត្តម កង ណែម<br>ឯកឧត្តម ថាច់ យន<br>ឯកឧត្តម ឌុច សុវណ្ណារី<br>លោកជំទាវ សុភ័ក្ត ថាវី<br>លោកជំទាវ សុខ វិឡាយ<br>ឯកឧត្តមបណ្ឌិត ហួត ហាក់<br>ឯកឧត្តមបណ្ឌិត ចាប សុថារិទ្ធ<br>លោកជំទាវ វង់ មយូរា<br>ថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន (តាមជាក់ស្តែង) |
| ៩:១៥ - ៩:៣០ | សម្រាក ពិសាភេសជ្ជៈនិងអាហារសម្រន់ | |
| ៩:៣០ - ១១:០០<br><br>១១:០០- ១២:០០ | - បទអន្តរាគមន៍ របស់តំណាងក្រសួង ស្ថាប័ន ថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន រាជធានី-ខេត្ត និងតំណាងមន្ទីរទរពអ រាជធានី-ខេត្ត<br>- ពិភាក្សាលើបទអន្តរាគមន៍ | ឯកឧត្តម ឆេង សារឿន (អ្នកសម្របសម្រួល)<br>ឯកឧត្តម កង ណែម<br>ឯកឧត្តម ថាច់ យន<br>ឯកឧត្តម ឌុច សុវណ្ណារី<br>លោកជំទាវ សុភ័ក្ត ថាវី<br>លោកជំទាវ សុខ វិឡាយ<br>ឯកឧត្តមបណ្ឌិត ហួត ហាក់<br>ឯកឧត្តមបណ្ឌិត ចាប សុថារិទ្ធ |

| | | |
|---|---|---|
| | | លោកជំទាវ វង់ មយូរា |
| ១២:០០- ១៣:៣០ | សម្រាកអាហារថ្ងៃត្រង់ Buffet នៅសណ្ឋាគារ | |
| **ម៉ោង** | **កម្មវិធី** | **គណៈអធិបតី/ថ្នាក់ដឹកនាំ** |
| **ពេលរសៀល** | | |
| ១៣:៣០ - ១៤:៣០ | ពិភាក្សាតាមក្រុម (ចែកជា ៣ ក្រុម) លើរបាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ ២០១៩ និងទិសដៅការងារឆ្នាំ២០២០ ដោយផ្តោតលើប្រធានបទ៣ ដូចខាងក្រោមៈ | |
| | ក្រុមទី១ៈ ប្រធានបទ "ការប្រឈមក្នុងការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា ការតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ និងការផ្សព្វផ្សាយច្បាប់" | ឯកឧត្តម កង ណែម (អ្នកសម្របសម្រួល)<br>លោកជំទាវ សុខ វិឡាយ<br>អនុរដ្ឋលេខាធិការ<br>អគ្គនាយក និងសមាសភាពផ្សេងទៀត<br>(ដូចមានក្នុងតារាងបែងចែក) |
| | ក្រុមទី២ៈ ប្រធានបទ "ការប្រឈមក្នុងការងារអធិការកិច្ច ដោះស្រាយពាក្យបណ្តឹង និងការតាមដានការអនុវត្តច្បាប់" | ឯកឧត្តម ឆេង សារឿន (អ្នកសម្របសម្រួល)<br>ឯកឧត្តម ឌុច សុវណ្ណារី<br>ឯកឧត្តម ថាច់ យន<br>ឯកឧត្តមបណ្ឌិត ហួត ហាក់<br>លោកជំទាវ វង់ មយូរា<br>អនុរដ្ឋលេខាធិការ<br>អគ្គនាយក និងសមាសភាពផ្សេងទៀត<br>(ដូចមានក្នុងតារាងបែងចែក) |
| | ក្រុមទី៣ៈ ប្រធានបទ "ការប្រឈមក្នុងការងារ រដ្ឋបាល ផែនការ បណ្តុះបណ្តាល ហិរញ្ញវត្ថុ និងផ្គត់ផ្គង់" | ឯកឧត្តមបណ្ឌិត ចាប សុថារិទ្ធ<br>(អ្នកសម្របសម្រួល)<br>លោកជំទាវ សុភ័ក្ត ថាវី<br>អនុរដ្ឋលេខាធិការ<br>អគ្គនាយក និងសមាសភាពផ្សេងទៀត<br>(ដូចមានក្នុងតារាងបែងចែក) |
| ១៤:៣០ - ១៥:១៥ | ក្រុមនីមួយៗរាយការណ៍ ពីលទ្ធផលតាមក្រុមៈ<br>-ក្រុមទី១ ដោយឯកឧត្តម កែវ គង់<br>-ក្រុមទី២ ដោយឯកឧត្តម ឈួរ រស្មីឬទ្ធី និង<br>-ក្រុមទី ៣ ដោយ ឯកឧត្តម ប៉ែន ច័ន្ទសុខរិន<br>(មួយក្រុមមានរយៈពេល១០នាទី) | ឯកឧត្តម ឆេង សារឿន<br>(អ្នកសម្របសម្រួល)<br>ឯកឧត្តម កង ណែម<br>ឯកឧត្តម ថាច់ យន<br>ឯកឧត្តម ឌុច សុវណ្ណារី<br>លោកជំទាវ សុភ័ក្ត ថាវី<br>លោកជំទាវ សុខ វិឡាយ<br>ឯកឧត្តមបណ្ឌិត ហួត ហាក់<br>ឯកឧត្តមបណ្ឌិត ចាប សុថារិទ្ធ |

| | | |
|---|---|---|
| | | លោកជំទាវ វង់ មយុរា |
| ១៥:១៥ - ១៥:៣០ | សម្រាក ពិសាភេសជ្ជៈនិងអាហារសម្រន់ | |
| ១៥:៣០ | លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ អញ្ជើញដល់ | |
| ១៥:៣០ - ១៦:៤៥ | **ពិធីបិទសន្និបាត**<br>-អានរបាយការណ៍បូកសរុបលទ្ធផលនៃអង្គសន្និបាតដោយ **ឯកឧត្តមបណ្ឌិត ចាប សុថារិទ្ធ** រដ្ឋលេខាធិការ<br>-សុន្ទរកថាបិទសន្និបាតដោយ **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ<br>-ពិធីបំពាក់គ្រឿងឥស្សរិយយសជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ<br>-បិទកម្មវិធី។ | -លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ<br>ឯកឧត្តម ឆេង សារឿន<br>ឯកឧត្តម កង ណៃម<br>ឯកឧត្តម ថាច់ យន<br>ឯកឧត្តម ឌុច សុវណ្ណារី<br>លោកជំទាវ សុភ័ក្ត ថាវី<br>លោកជំទាវ សុខ វិឡាយ<br>ឯកឧត្តមបណ្ឌិត ហួត ហាក់<br>ឯកឧត្តមបណ្ឌិត ចាប សុថារិទ្ធ<br>លោកជំទាវ វង់ មយុរា<br>តំណាងក្រសួង-ស្ថាប័ន (តាមជាក់ស្តែង) |
| ១៧:៣០ - ២២:៣០ | -ពិធីជប់លៀងអាហារសាមគ្គី (ថ្នាក់ដឹកនាំ សមាជិក សមាជិកាសន្និបាតទាំងអស់ចូលរួម)<br>នៅភោជនីយដ្ឋានកាដូ សង្កាត់ព្រែកលៀប ផ្លូវជាតិលេខ៦ | |

***កំណត់សំគាល់៖***

១) គណៈកម្មាធិការ រៀបចំសន្និបាត សូមរក្សាសិទ្ធិកែប្រែកម្មវិធីក្នុងករណីចាំបាច់។

២) សម្លៀកបំពាក់៖ បុរស៖ អាវធំ ក្រវ៉ាត់ក នារី៖ ប្រពៃណី ។

៣) សូមប្រាប់មុន (Confirm) ចំពោះការចូលរួមជប់លៀងពេលល្ងាច ទី២០ ខែមករា ឆ្នាំ ២០២០ ដល់ក្រុមលេខាធិការដ្ឋានរៀបចំសន្និបាត ដើម្បីងាយស្រួលដល់ការរៀបចំ និងចៀសវាងការខ្វះខ្វាយថវិកា។

៤) ថវិកាជប់លៀងបានមកពីការចូលរួមវិភាគទានដោយស្ម័គ្រចិត្តពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំ និងមន្ត្រី រាជការក្រសួង

៥) សូមទាក់ទងទូរស័ព្ទ ឯកឧត្តម កឹម សុខជា៖ ០១៧៤៦៩៦៩៩ និង លោក ស្រ៊ុន សារ៉ន៖ ០៨៩៧២៩២៩២

# ឧបសម្ព័ន្ធ ២. របាយការណ៍សង្ខេបការងារ ២០១៩-២០២០

## របាយការណ៍សង្ខេប
## ស្តីពី
## ការបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០
## របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

## ក. សេចក្តីផ្តើម

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចបានអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ក្នុងការងារចំបង គឺការទំនាក់ទំនង សម្របសម្រួលរវាងរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា ការចូលរួមតាក់តែង សេចក្តីព្រាងច្បាប់ ការអប់រំផ្សព្វផ្សាយច្បាប់ ការទទួល និងដោះស្រាយ ពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ ការតាមដានការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា និងធ្វើអធិការកិច្ចលើគ្រប់វិស័យ សំដៅ បង្ការ ទប់ស្កាត់ កែលម្អ និងមានវិធានការ ដើម្បីប្រឆាំងនឹងអំពើ ពុករលួយ ការរំលោភដោយអំណាច និងបាតុភាពអសកម្មនានា ដើម្បីពង្រឹងអភិបាលកិច្ចល្អ ការពារ សិទ្ធិរបស់ប្រជាពលរដ្ឋ និងការពារសុវត្ថិភាពសាធារណៈ និងរួមចំណែកដល់ការអភិវឌ្ឍន៍ សេដ្ឋកិច្ច សង្គម។

ក្នុងឆ្នាំ២០១៩ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានសម្រេចនូវ សមិទ្ធផលនានា ជាច្រើនដូចរៀបរាប់ខាងក្រោមៈ

## ខ. សមិទ្ធផលការងារ

### ១. ការងាររដ្ឋបាលកិច្ចការទូទៅ

#### ១.១. ការងាររដ្ឋបាល

-ទទួលលិខិតចូលពីក្រសួង-ស្ថាប័ននានាចំនួន៩៧១ច្បាប់ និងបញ្ជូនលិខិតចេញចំនួន១ ១៨៩ ច្បាប់។

-រៀបចំតាំងបដាពាក្យស្លោក ទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ ក្នុងពិធីបុណ្យជាតិ-អន្តរជាតិ នៅ ទីស្តីការក្រសួង។

-រៀបចំសារលិខិតថ្វាយព្រះពរ និងជូនពរដល់ ព្រះមហាក្សត្រ និងសម្តេចព្រះមហាក្សត្រី ថ្នាក់ដឹកនាំជាតិនានាក្នុងពិធីខួបកំណើតនិង ក្នុងពិធីបុណ្យជាតិ។

-រៀបចំពិធីទទួលជួបសវនាការការងារ រវាងថ្នាក់ដឹកនាំក្រសួងជាមួយគណៈប្រតិភូបរទេស និងឯកឧត្តមឯកអគ្គរាជទូត នៅទីស្តីការក្រសួង។

-រៀបចំប្រជុំតាមកម្មវិធីប្រជុំរបស់ថ្នាក់ដឹកនាំក្រសួង នៅទីស្តីការក្រសួង។

-រៀបចំធ្វើអត្តសញ្ញាណប័ណ្ណជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ។

-រៀបចំលិខិតបង្គាប់ការចាត់មន្ត្រីរាជការ ចូលរួមពិធីបុណ្យជាតិ-អន្តរជាតិ និងទទួល-ជូនដំណើរគណៈប្រតិភូជាន់ខ្ពស់បរទេស មកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា។

-គ្រប់គ្រង ពិនិត្យតាមដានជាប្រចាំនូវការសរសេរ និងរូបថត សរសេរខ្លឹមសារ និងថត សកម្មភាពការងារថ្នាក់ដឹកនាំ និងមន្ត្រីរាជការបញ្ចូលក្នុងគេហទំព័រផ្លូវការរបស់ក្រសួង។

-តាមដានរាល់សកម្មភាពព័ត៌មានដែលចេញតាមវេបសាយក្រសួង និងតាមប្រព័ន្ធ Facebook page។

-ចូលរួមប្រជុំស្តីពីការត្រៀមលក្ខណៈរៀបចំពិធីបុណ្យជាតិ-អន្តរជាតិ និងការត្រៀមលក្ខណៈទទួល-ជូនដំណើរ គណៈប្រតិភូជាន់ខ្ពស់បរទេស នៅគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ចំនួន១០លើក។

**១-២-ការងារបុគ្គលិក និងធនធានមនុស្ស**

ធ្វើសេចក្តីសម្រេចស្តីពី ១) ការបង្កើតគណៈកម្មការតាំងស៊ប់បំពេញសិទ្ធិ នៅក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការ ២) ការបង្កើតគណៈកម្មការដំឡើងឋានន្តរស័ក្តិ ថ្នាក់ ជូនមន្ត្រីរាជការប្រចាំឆ្នាំ២០២០ ៣) ការបង្កើតក្រុមប្រឹក្សាវិន័យរបស់ក្រសួង៤) ការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជម្ងឺអេដស៍ នៅក្រសួង ៥) ការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន៥០រូប ៦) ការទទួលក្របខ័ណ្ឌមន្ត្រីរាជការចំនួន១៣រូប ពីស្ថាប័នផ្សេងឱ្យមកបម្រើការងារក្នុងក្របខ័ណ្ឌក្រសួង ៧) ការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការចំនួន១១រូប ពីក្របខ័ណ្ឌក្រសួង ឱ្យទៅបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងផ្សេង ៨) ការផ្ទេរភារកិច្ចមន្ត្រីរាជការចំនួន៦រូប ក្នុងក្រសួង ៩) ការលុបឈ្មោះមន្ត្រីរាជការចំនួន៦រូប ពីក្របខ័ណ្ឌក្រសួង ១០) ការដាក់មន្ត្រីរាជការចំនួន២រូប ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស និង ១១) ការផ្លាស់ប្តូរមន្ត្រីជាប់កិច្ចសន្យាចំនួន២រូប។

**១-៣-ការងារបណ្តុះបណ្តាល**

-បណ្តុះបណ្តាលជំនាញអធិការកិច្ចបឋម ជូនមន្ត្រីរាជការ ចំនួន៣២៧រូប ស្តីពីមូលដ្ឋានគ្រឹះនៃការងារអធិការកិច្ច គណនេយ្យ ការគ្រប់គ្រងការងាររដ្ឋបាល និងសវនកម្ម នៅវិទ្យាស្ថានជាតិអធិការកិច្ច។

-ចាត់បញ្ជូនមន្ត្រីរាជការចំនួន៥រូប ទៅបណ្តុះបណ្តាលភាសាចិន នៅសាធារណរដ្ឋប្រជាមានិតចិន ២ រូបទៅបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ និងរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល (ករស) តាមអនឡាញ នៅសណ្ឋាគារអង្គរប៉ារ៉ាឌី ខេត្តសៀមរាប ៣រូប ទៅសិក្សាកម្រិតថ្នាក់បរិញ្ញាបត្រ និងថ្នាក់អនុបណ្ឌិត នៅសាកលវិទ្យាល័យឯកទេសកម្ពុជាសាខាខេត្តបាត់ដំបង ១៣រូប ទៅបណ្តុះបណ្តាលស្តីពីជំនាញបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ៤រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីវគ្គថ្នាលថ្មី នៃកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំនយោបាយ នៅអាគារខេមរានី វិថីវិចិត្រសិល្បៈ។

**១-៤-ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់**

-ទំនាក់ទំនងការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារជាតិ និងធនាគារជាតិ ក្នុងកិច្ចការស្នើសុំថវិកានានាតាមខ្ទង់ ជំពូក ដើម្បីបម្រើការងារក្រសួងឱ្យដំណើរការល្អ ដូចជាថវិកាសម្រាប់បៀវត្ស ដំណើរការរដ្ឋបាលទូទៅ បេសកកម្មក្នុងប្រទេស និងក្រៅប្រទេស។ល។

**១-៥-ការងារផែនការ និងស្ថិតិ**

-រៀបចំធ្វើផែនការកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០២០-២០២២ របស់ក្រសួងដែលមានចំនួន៧គម្រោងសម្រាប់ដាក់ជូនថ្នាក់ដឹកនាំពិនិត្យ-សម្រេចដើម្បីផ្ញើជូនក្រសួងផែនការ។

-រៀបចំពង្រាងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ របស់នាយកដ្ឋានផែនការ និងស្ថិតិ។

-រៀបចំរបាយការណ៍វឌ្ឍនភាពលទ្ធផលសម្រេចបាន ឆ្នាំ២០១៦-២០១៨ សម្រាប់ជាធាតុចូលស្តីពីការ រៀបចំរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តឆ្នាំ២០១៩ ស្តីពីការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០។

-រៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០២០-២០២២ របស់ក្រសួងបញ្ជូនទៅក្រសួងផែនការ។

-រៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២០-២០២២ របស់ក្រសួងជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-ទំនាក់ទំនងជាមួយមន្ត្រីជំនាញក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអំពីសារាចរណែនាំរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២។

-ចូលរួមពិធីផ្សព្វផ្សាយក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០ (ថ្នាក់ជាតិ) នៅសណ្ឋាគារភ្នំពេញ។

-ចូលរួមពិធីប្រកាសផ្សព្វផ្សាយការដាក់ឱ្យប្រើប្រាស់ជាផ្លូវការផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ)២០១៩-២០២៣ នៅសណ្ឋាគារសុខាភ្នំពេញ។

-ផ្ញើស្ថិតិផ្លូវការដែលមានការចាត់តាំងតាមវិស័យរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចប្រចាំឆ្នាំ២០១៨ ទៅវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងទីស្តីការគណៈរដ្ឋមន្ត្រី។

-រៀបចំគម្រោងថវិការដ្ឋសម្រាប់គ្រប់គ្រងឆ្នាំ២០២០ រដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី-ខេត្ត ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-កែសម្រួលបច្ចុប្បន្នភាពស្ថិតិទូទៅរបស់ក្រសួង និងបម្រែបម្រួលមន្ត្រីរាជការតាមនាយកដ្ឋាននីមួយៗ ព្រមទាំងថ្នាក់មន្ទីររាជធានី-ខេត្ត។

-រៀបចំកែសម្រួលកម្រិតបច្ចេកទេសគម្រោងផែនការថវិការដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ របស់ក្រសួង។

-បានរៀបចំប្រជុំ និងចូលរួមប្រជុំ ចំនួន១៣លើក។

### ១-៦-ការងារសហប្រតិបត្តិការអន្តរជាតិ

ថ្នាក់ដឹកនាំក្រសួងបានទទួលជួបសវនាការការងារជាមួយៈ

-ឯកឧត្តមលេខាធិការមជ្ឈិមបក្ស និងជាប្រធានគណៈត្រួតពិនិត្យមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម

-ឯកឧត្តម ឯកអគ្គរដ្ឋទូតសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា

-គណៈប្រតិភូសភាបារាំង

-ឯកឧត្តមឯកអគ្គរាជទូតម៉ាឡេស៊ី

-លោក ប្រធានសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយសកលលោក

-លោកជំទាវឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុប

-លោកជំទាវ អនុប្រធានសភានៃខេត្តហ្វូជៀន សាធារណរដ្ឋប្រជាមានិតចិន នៅទីស្តីការក្រសួង។

-រួមពិធីទទួល និងជូនដំណើរគណៈប្រតិភូជាន់ខ្ពស់ដឹកនាំដោយឯកឧត្តម អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម និងជាប្រធានរដ្ឋសាធារណរដ្ឋសង្គមនិយមវៀតណាម

-គណៈប្រតិភូជាន់ខ្ពស់ដឹកនាំដោយឯកឧត្តម ប្រធានាធិបតីនៃសាធារណរដ្ឋកូរ៉េ នៅមុខព្រះបរមរាជវាំង។

-ចាត់ចែង និងសម្របសម្រួលជាមួយភាគីវៀតណាម ដើម្បីរៀបចំដំណើរទស្សនកិច្ចរបស់គណៈប្រតិភូជាន់ខ្ពស់ ក្រសួងទៅសាធារណរដ្ឋសង្គមនិយមវៀតណាម។

-ទំនាក់ទំនងសម្របសម្រួលជាមួយវិទ្យាស្ថានខុងជឺ នៃរាជបណ្ឌិតសភាកម្ពុជា ដើម្បីបញ្ជូនសិក្ខាកាមចំនួន៥រូបទៅសិក្សានៅសាធារណរដ្ឋប្រជាមានិតចិន រយៈពេល១០ខែ។

-ចាត់បញ្ជូនមន្ត្រីជាន់ខ្ពស់១រូប ដើម្បីចូលរួមក្នុងកម្មវិធីទស្សនកិច្ចសិក្សា នៅសាធារណរដ្ឋប្រជាមានិតចិន រយៈពេល៨ថ្ងៃ។

-រៀបចំសម្របសម្រួលកម្មវិធីបដិសណ្ឋារកិច្ច ជូនគណៈប្រតិភូជាន់ខ្ពស់ ដឹកនាំដោយឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការនៃសាធារណរដ្ឋសង្គមនិយមវៀតណាម មកបំពេញទស្សនកិច្ចផ្លូវការ នៅព្រះរាណាចក្រកម្ពុជា។

## ២-ការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

### ២-១-ការងារនីតិកម្ម

-បានរៀបចំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច នៅទីស្តីការក្រសួងចំនួន៣៨លើក។

-បានរៀបចំកិច្ចប្រជុំឆ្លងសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច នៅទីស្តីការក្រសួងចំនួន១លើក។

-ចូលរួមការពារសេចក្តីព្រាងច្បាប់ ស្តីពីអធិការកិច្ចក្នុងកិច្ចប្រជុំជំនាញបច្ចេកទេស នៅទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន៦លើក។

-ចូលរួមប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបណ្ណាសារ នៅទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន១លើក។

-ចូលរួមប្រជុំអន្តរក្រសួង ជាច្រើនលើក

-ចូលរួមសិក្ខាសាលា និងវេទិកានានាជាច្រើនលើក

-បញ្ជូនមន្ត្រីរាជការ ចំនួន៥រូប ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការកសាងសមត្ថភាពស្រាវជ្រាវនៅវិទ្យាស្ថានជាតិអធិការកិច្ច ចំនួន១លើក។

-បានរៀបចំបណ្ណាល័យច្បាប់អេឡិចត្រូនិច ចំនួន១លើក។

-បញ្ចូលអត្ថបទច្បាប់ ចំនួន៤៩៨ច្បាប់ ទៅក្នុងបណ្ណាល័យច្បាប់អេឡិចត្រូនិច។

-បញ្ចូលលិខិតបទដ្ឋានគតិយុត្ត ចំនួន១៨៤លិខិត ទៅក្នុងបណ្ណាល័យច្បាប់អេឡិចត្រូនិច។

-ចុះស្ទង់មតិប្រជាពលរដ្ឋ ស្តីពីការយល់ដឹងលើច្បាប់ភូមិបាល ចំនួន១០លើក នៅខេត្តស្វាយរៀង ចំនួន២លើក ព្រៃវែង ចំនួន២លើក សៀមរាប ចំនួន២លើក កំពង់ធំ ចំនួន២លើក និងខេត្តកែប ចំនួន២លើក ដោយមានអ្នកចូលរួម ចំនួន៩២៥នាក់ (ស្ត្រី ចំនួន៤៤៨ នាក់)។

-ចុះស្ទង់មតិប្រជាពលរដ្ឋ ស្តីពីការយល់ដឹងលើច្បាប់ចរាចរណ៍ផ្លូវគោក នៅខេត្តកំពង់ធំ ចំនួន៧លើក ដោយមានអ្នកចូលរួម ចំនួន៣៨៧នាក់ (ស្ត្រី ចំនួន៧៧នាក់)។

-ចុះស្ទង់មតិសិស្សានុសិស្ស ស្តីពីការយល់ដឹងលើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅខេត្តព្រះសីហនុចំនួន៤លើក ដោយមានអ្នកចូលរួម ចំនួន២២០នាក់ (ស្ត្រី ចំនួន១០៩នាក់)។

**២-២-ការងារអប់រំផ្សព្វផ្សាយច្បាប់**

-ចុះផ្សព្វផ្សាយច្បាប់ ចំនួន១៤៤លើក (អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា ចំនួន២៣លើក និងមន្ទីររាជធានី-ខេត្ត ចំនួន១២១លើក) ដោយមានអ្នកចូលរួម ចំនួន៤៨ ២៤០នាក់ (ស្ត្រី ចំនួន១៩ ៣៧៦នាក់) និងបានទទួលសំណួរ ចំនួន៤ ៦៧៤សំណួរ។

**២-៣-ការងារទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល**

-ចូលរួមប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រីលើសេចក្តីព្រាងច្បាប់ ចំនួន១៧លើក សេចក្តីព្រាងអនុក្រឹត្យ ចំនួន១២លើក និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត ចំនួន១៧លើក។

**២-៤-ការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា**

-ចូលរួមស្តាប់សម័យប្រជុំពេញអង្គរបស់រដ្ឋសភា លើសេចក្តីស្នើច្បាប់ ចំនួន២លើក សេចក្តីព្រាងច្បាប់ចំនួន២០លើក ការបោះឆ្នោតជ្រើសតាំង ចំនួន៤លើក ព្រះរាជសារ ចំនួន២លើក របាយការណ៍របស់រដ្ឋសភា ចំនួន២លើក និងការប្រកាសសុពលភាព ចំនួន១លើក។

-ចូលរួមអមដំណើរជាមួយគណៈកម្មការទី៧នៃរដ្ឋសភា ចំនួន២លើក។

-ចូលរួមស្តាប់សម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភា លើសេចក្តីស្នើច្បាប់ ចំនួន២លើក សេចក្តីព្រាងច្បាប់ចំនួន២០លើក ការប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី ចំនួន៤លើក និងការបោះឆ្នោតជ្រើសតាំង ចំនួន២លើក។

**២-៥-ការងារទំនាក់ទំនងជាមួយប្រជាពលរដ្ឋ**

-រៀបចំវេទិកាសាធារណៈដើម្បីទទួលសំណូមពរពីប្រជាពលរដ្ឋ ចំនួន១០លើក នៅខេត្តបាត់ដំបង ចំនួន២លើក កំពង់ចាម ចំនួន២លើក ព្រៃវែង ចំនួន២លើក កំពត ចំនួន២លើក និងខេត្តពោធិ៍សាត់ ចំនួន២លើក ដោយមានអ្នកចូលរួម ចំនួន២ ៦៥៦នាក់ (ស្ត្រី ចំនួន១ ១៨៥នាក់) និងបានទទួលសំណូមពរពីប្រជាពលរដ្ឋ ចំនួន២៧៣សំណូមពរ។

## ៣-ការងារអធិការកិច្ច

**៣-១-ការងារអធិការកិច្ចទី ១ លើវិស័យសេដ្ឋកិច្ច**

១-ចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋក្នុងការិយបរិច្ឆេទ ២០១៨ និងបណ្តាឆ្នាំពាក់ព័ន្ធនៅក្រសួងចំនួន៩ អង្គភាពថ្នាក់ជាតិចំនួន២ និងមន្ទីរ-អង្គភាពក្នុង២៥ រាជធានី-ខេត្ត ស្មើនឹង៣០៣មន្ទីរ- អង្គភាព។

២-ធ្វើលិខិតជូនដំណឹងស្តីពីការជំរុញការកែលម្អចំណុចខ្វះខាត ទៅក្រសួង-ស្ថាប័នរងអធិការកិច្ច ចំនួន៦០ច្បាប់។

៣-ទទួលលិខិតឆ្លើយតប ស្តីពីការជំរុញការកែលម្អចំណុចខ្វះខាតពីក្រសួង-ស្ថាប័ន អង្គភាព ចំនួន៤ច្បាប់។

**៣-២-ការងារអធិការកិច្ចទី ២ លើវិស័យរដ្ឋបាលទូទៅ**

១-ចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋក្នុងការិយបរិច្ឆេទ ២០១៨ និងបណ្ដាឆ្នាំពាក់ព័ន្ធនៅក្រសួង ចំនួន១ និងមន្ទីរ-អង្គភាពក្នុង២៣រាជធានី-ខេត្ត ស្មើនឹង ២៣៧មន្ទីរ-អង្គភាព។

២-ចុះទំនាក់ទំនង និងក្ដាប់សភាពការការងារអធិការកិច្ចនៅក្រសួង ចំនួន១៤ ។

៣-ទទួលរបាយការណ៍ និងលិខិតជូនជ្រាបពីក្រសួង ចំនួន១១ ។

**៣-៣-ការងារអធិការកិច្ចទី ៣ លើវិស័យសង្គមកិច្ច**

១-ចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋក្នុងការិយបរិច្ឆេទ ២០១៨ និងបណ្ដាឆ្នាំពាក់ព័ន្ធ នៅក្រសួង ចំនួន៧ និងមន្ទីរ-អង្គភាពក្នុង២៥រាជធានី-ខេត្ត ស្មើនឹង ២៣០មន្ទីរ-អង្គភាព។

២-ធ្វើលិខិតជូនដំណឹងស្ដីពីការជំរុញការកែលម្អចំណុចខ្វះខាត ដែលគណៈប្រតិភូបានពិនិត្យឃើញក្នុងការិយបរិច្ឆេទ២០១៨ ចំនួន១៣ច្បាប់ ទៅក្រសួង-ស្ថាប័ន ចំនួន៨ ។

៣-ទទួលលិខិតឆ្លើយតបស្ដីពីការជំរុញការកែលម្អចំណុចខ្វះខាត ចំនួន៥ច្បាប់ ។

**៣-៤-ការងារតាមដានការអនុវត្តច្បាប់**

ចុះតាមដានការអនុវត្តច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានា ចំនួន៣៨លើក រួមមានៈ ការចុះតាមដានការអនុវត្តច្បាប់តាមបណ្ដាក្រសួង-ស្ថាប័ន ចំនួន៥ (ច្បាប់ ចំនួន៣ និងអនុក្រឹត្យចំនួន៧) និងការចុះតាមដានការអនុវត្តច្បាប់នៅរាជធានី ខេត្ត និងអង្គភាពផ្សេងៗបាន ចំនួន៣២លើក (ច្បាប់ចំនួន៦ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានាចំនួន៤)។

**៣-៥-ការងារទទួលពាក្យបណ្ដឹង និងអង្កេតស្រាវជ្រាវ**

ក្រសួងបានទទួលពាក្យបណ្ដឹងចំនួន១៣៥បណ្ដឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន៤៦បណ្ដឹង និងមន្ទីររាជធានី-ខេត្តចំនួន៨៩បណ្ដឹង) ដែលក្នុងនោះ រួមមានៈ

-ពាក្យបណ្ដឹងកំពុងពិនិត្យ ចំនួន៥បណ្ដឹង (ឆ្នាំ២០១៩ចំនួន៥បណ្ដឹង)។

-ពាក្យបណ្ដឹងរង់ចាំការសម្រេចពីថ្នាក់ដឹកនាំក្រសួង ចំនួន៤បណ្ដឹង(ឆ្នាំ២០១៩ចំនួន៤បណ្ដឹង)។

-ពាក្យបណ្ដឹងបានបញ្ជូនទៅស្ថាប័នផ្សេងដោះស្រាយ ចំនួន១៧បណ្ដឹង (ឆ្នាំ២០១៨ ចំនួន៤បណ្ដឹង ឆ្នាំ២០១៩ចំនួន១៣បណ្ដឹង)។

-ពាក្យបណ្ដឹងកំពុងត្រៀមបញ្ជូនទៅស្ថាប័នផ្សេងដោះស្រាយ ចំនួន២បណ្ដឹង (ឆ្នាំ២០១៩ចំនួន២បណ្ដឹង)។

-ពាក្យបណ្ដឹងដែលជាសមត្ថកិច្ចក្រសួងចំនួន២២បណ្ដឹង និងសមត្ថកិច្ចមន្ទីររាជធានី-ខេត្តចំនួន៨៩បណ្ដឹង (ឆ្នាំ២០១៩ចំនួន៨៩បណ្ដឹង)។

-ពាក្យបណ្ដឹងដែលម្ចាស់បណ្ដឹងសុំដកវិញចំនួន១បណ្ដឹង(ឆ្នាំ២០១៨ចំនួន១បណ្ដឹង)។

-ពាក្យបណ្ដឹងកំពុងចុះអង្កេតស្រាវ ជ្រាវចំនួន៦៨បណ្ដឹង(អគ្គនាយកដ្ឋានអធិការកិច្ចចំនួន២៧បណ្ដឹង និងមន្ទីររាជធានី-ខេត្តចំនួន៤១បណ្ដឹង ក្នុងនោះឆ្នាំ២០១៤ចំនួន៣បណ្ដឹង ឆ្នាំ២០១៦ចំនួន៣បណ្ដឹង ឆ្នាំ២០១៧ចំនួន៧បណ្ដឹង ឆ្នាំ២០១៨ចំនួន១៤បណ្ដឹង និងឆ្នាំ២០១៩ចំនួន៤១បណ្ដឹង)។

-ពាក្យបណ្ដឹងត្រៀមចុះអង្កេតស្រាវជ្រាវចំនួន៤បណ្ដឹង(ឆ្នាំ២០១៩ចំនួន៤បណ្ដឹង)។

-ពាក្យបណ្ដឹងដែលថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកលែងចាត់ការបន្ត ចំនួន១បណ្ដឹង។

-ពាក្យបណ្តឹងដែលបានបង្វែរ ទៅស្ថាប័នផ្សេងដោះស្រាយ ចំនួន១បណ្តឹង (ឆ្នាំ២០១៦ ចំនួន១បណ្តឹង)។

-ពាក្យបណ្តឹងដែលបានបញ្ចប់ការដោះស្រាយចំនួន៦បណ្តឹង។

-ពាក្យបណ្តឹងសុំការសម្របសម្រួលពីថ្នាក់ដឹកនាំក្រសួងចំនួន១បណ្តឹង។

-ពាក្យបណ្តឹងបានទទួលការឆ្លើយតបចំនួន៨បណ្តឹង (ឆ្នាំ២០១៨ចំនួន៣បណ្តឹង ឆ្នាំ២០១៩ចំនួន៥បណ្តឹង)។

-ពាក្យបណ្តឹងដែលម្ចាស់បណ្តឹងសុំជំរុញការដោះស្រាយចំនួន៨បណ្តឹង (ឆ្នាំ២០១៦ចំនួន៣បណ្តឹង ឆ្នាំ២០១៧ ចំនួន១បណ្តឹង ឆ្នាំ២០១៩ចំនួន៤បណ្តឹង)។

-ពាក្យបណ្តឹងដែលក្រសួងបានធ្វើលិខិតជំរុញការដោះស្រាយចំនួន៨បណ្តឹង (ឆ្នាំ២០១៦ ចំនួន៣បណ្តឹង ឆ្នាំ២០១៧ ចំនួន១បណ្តឹង ឆ្នាំ២០១៩ ចំនួន៤បណ្តឹង)។

-ពាក្យបណ្តឹងដែលបានចុះជំរុញការដោះស្រាយចំនួន១បណ្តឹង(ឆ្នាំ២០១៨ចំនួន១បណ្តឹង)។

-ពាក្យបណ្តឹងបានដោះស្រាយចប់ចំនួន២៨បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ច ចំនួន៦បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន២២បណ្តឹង ក្នុងនោះឆ្នាំ២០១៧ចំនួន២បណ្តឹង ឆ្នាំ២០១៨ចំនួន៦បណ្តឹង ឆ្នាំ២០១៩ ចំនួន២០បណ្តឹង)។

## ៤. សវនកម្មផ្ទៃក្នុង

-ចុះតាមដានអនុសាសន៍របស់សវនករ ក្នុងការិយបរិច្ឆេទ២០១៧ នៅតាមបណ្តាសវនដ្ឋានបានចំនួន១១មន្ទីរ ការិយបរិច្ឆេទ២០១៨ នៅតាមទីសវនដ្ឋាន បានចំនួន១៥មន្ទីរ

-ធ្វើរបាយការណ៍ស្តីពីការចុះធ្វើសវនកម្មនៅ ១៥មន្ទីរ។

-ធ្វើសេចក្តីជូនដំណឹងដល់មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តឧត្តរមានជ័យស្តីពីការកែលម្អកំហុសឆ្គង លើការអនុវត្តនីតិវិធីហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទ២០១៨។

## ៥. ការងារវិទ្យាស្ថានជាតិអធិការកិច្ច

-បានស្នើសុំ និងទទួលបានការអនុម័តយល់ព្រម លើសារាចរស្តីពីការចាត់តាំងមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលជំនាញអធិការកិច្ចនៅវិទ្យាស្ថានជាតិអធិការកិច្ច។

-បានស្នើសុំ និងទទួលបានការអនុម័តយល់ព្រម លើប្រកាសស្តីពីការកំណត់ភារកិច្ច របស់សាស្ត្រាចារ្យ និងគ្រូឧទ្ទេសសម្រាប់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ច។

-បានស្នើសុំ និងទទួលបានការអនុម័តយល់ព្រមលើសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការកំណត់អំពីកម្រិត និងប្រធានបទ សម្រាប់បណ្តុះបណ្តាលវិជ្ជាជីវៈអធិការកិច្ច។

-បានរៀបចំផែនការថវិកា និងផែនការសកម្មភាពឆ្នាំ២០២០ របស់វិទ្យាស្ថានជាតិអធិការកិច្ច។

-បាន និងកំពុងជ្រើសរើសគ្រូបង្គោលជំនាញវិជ្ជាជីវៈអធិការកិច្ចសម្រាប់វិទ្យាស្ថានជាតិអធិការកិច្ច។

-បានផ្តល់ការបណ្តុះបណ្តាលជំនាញអធិការកិច្ចបឋម ជូនមន្ត្រីរាជការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន៨វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន៣២៧រូប (ស្ត្រីចំនួន១២២រូប)។

-បានសហការជាមួយអង្គការមូលនិធិអាស៊ី និងក្រុមហ៊ុនប្រឹក្សាយោបល់ CPS ផ្តល់ការបណ្តុះបណ្តាលស្តីពី ការកសាងសមត្ថភាពស្រាវជ្រាវ ជូនមន្ត្រីរាជការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន២០រូប (ស្ត្រីចំនួន៤រូប)។

-បានចុះសិក្សាស្រាវជ្រាវអំពីតម្រូវការនៃការបណ្តុះបណ្តាលក្នុងវិស័យអធិការកិច្ច នៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន២០ខេត្ត។

-បានចុះស្ទង់មតិអំពីការគ្រប់គ្រង និងការអភិវឌ្ឍន៍ការងារអធិការកិច្ច នៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចតាមបណ្តាខេត្តចំនួន៧ខេត្ត។

## ៦-ការងារផ្សេងៗទៀត

### ៦-១-ការងារយេនឌ័រ

-បានរៀបចំអបអរសាទរទិវាអន្តរជាតិនារី៨មីនាក្រោមប្រធានបទ«លើកកម្ពស់សមភាពយេនឌ័រ និងការគាំពារ សង្គមដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស»។

-បានប្រជុំផ្សព្វផ្សាយសេចក្តីសម្រេចស្តីពីការកែសម្រួលសមាសភាព ក្រុមការងារបច្ចេកទេសយេនឌ័រប្រចាំក្រសួង។

-បានរៀបចំសម្របសម្រួល និងចុះហត្ថលេខារួមគ្នាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការលើកកម្ពស់សុខុមាលភាពជូនមន្ត្រីរាជការក្រសួង ជាមួយមន្ទីរពេទ្យព្រះកេតុមាលា ជាលទ្ធផលនៃការអនុវត្តអនុស្សរណៈនេះ បានជួយដល់មន្ត្រីរាជការ និងសាច់ញាតិបានចំនួន៥រូប។

-មន្ត្រីរាជការជាស្ត្រីដែលទទួលបានការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពក្នុងប្រទេសមាន ចំនួន ១១៥រូប និងក្រៅប្រទេស ចំនួន១រូប។

-បានរៀបចំវគ្គអប់រំផ្សព្វផ្សាយ ស្តីពីការស្វែងយល់អំពីជម្ងឺទឹមនោមផ្អែម ដោយមានមន្ត្រីរាជការសរុប ចំនួន៨៤រូប។

-ឧបត្ថម្ភថវិកា ចំនួន៤៥ម៉ឺនរៀល ដល់មន្ត្រីរាជការជាស្ត្រីរងគ្រោះថ្នាក់ចរាចរណ៍ ចំនួន១រូប។

-ឧបត្ថម្ភថវិកា ចំនួន៦០ម៉ឺនរៀល ដល់មន្ត្រីរាជការជាស្ត្រីសម្រាលមាតុភាព ចំនួន៣រូប។

-ចូលរួមសិក្ខាសាលាពាក់ព័ន្ធនឹងការងារយេនឌ័រ ចំនួន៥លើក។

-បានរៀបចំកម្មវិធីផ្សព្វផ្សាយ ស្តីពីការស្វែងយល់ទស្សនទានយេនឌ័រជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួង ដោយមានការចូលរួម ចំនួន១៨០រូប។

-បានរៀបចំផែនការសកម្មភាពការងារបញ្ជ្រាបយេនឌ័រប្រចាំឆ្នាំ២០២០។

### ៦.២. ការងារចងសម្ព័ន្ធមេត្រីភាព

ថ្នាក់ដឹកនាំ និងមន្ត្រីរាជក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានចុះសួរសុខទុក្ខ និងសំណេះសំណាលជាមួយកងកម្លាំង ជួរមុខវរសេនាតូចនគរបាលការពារ ព្រំដែនទឹកលេខ ២៦៩ និងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨២៧ នៃគណៈបញ្ជាការនគរបាលជាតិប្រចាំទិសភូមិភាគ៣។ ក្នុងឱកាសនោះក៏មានការឧបត្ថម្ភជាគ្រឿងឧបភោគបរិភោគ និងថវិកាមួយចំនួនដែលបានមកពីសប្បុរសជន សម្រាប់ជូនដល់កងកម្លាំងនគរបាលដែលបានឈរជើង ប្រចាំទិសភូមិភាគខេត្តកោះកុង។

### ៦.៣. ការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ

ក្រសួងបានចូលរួមយ៉ាងសកម្មក្នុងការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដូចខាងក្រោម៖

-ចូលរួមប្រជុំជាប្រចាំ ជាមួយគណៈកម្មាធិការ ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

-អនុវត្តសេចក្តីជូនដំណឹង និងសារាចរណែនាំស្តីពីការត្រៀម និងរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០ -២០២២ និងផែនការថវិការបស់ក្រសួង។

-ធ្វើសិក្ខាសាលាត្រួតពិនិត្យពិនត្យការអនុវត្តន៍ថវិកាកម្មវិធីរយៈពេល៩ខែ នៅសណ្ឋាគារភ្នំពេញ។

-សហការជាមួយអ្នកបច្ចេកទេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការបំពាក់ និងតម្លើងបណ្តាញ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ (FMIS) រួមមានបណ្តាញ សឺរវើរ និងកុំព្យូទ័រ នៅក្រសួង។

-បញ្ជូនក្រុមការងារប្រព័ន្ធFMISក្រសួង ទៅចូលរួមបណ្តុះបណ្តាល ការប្រើប្រាស់ប្រព័ន្ធ FMIS តាមមុខងារ នីមួយៗ ហើយចាប់ផ្តើមអនុវត្តតាំងពីថ្ងៃទី២ ខែមករា ឆ្នាំ២០២០។

## គ. បញ្ហាប្រឈម

ទន្ទឹមនឹងលទ្ធផលទទួលបានខាងលើ ក្រសួងនៅជួបបញ្ហាប្រឈមមួយចំនួនដូចជា៖

-ពុំទាន់មានលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រាន់ពាក់ព័ន្ធនឹងវិស័យអធិការកិច្ច។

-ពុំទាន់បានអនុវត្តផែនការថវិកាកម្មវិធីពេញលេញ ជាក់ស្តែងក្នុងឆ្នាំ២០១៩ ប្រើប្រាស់បានតែថវិកា ជំពូក៦១ប៉ុណ្ណោះ។

-ពុំទាន់មានថវិកាបុរេប្រទាន មធ្យោបាយធ្វើដំណើររបស់រដ្ឋ និងសម្ភារបច្ចេកវិទ្យាមិនសមស្រប សម្រាប់ចុះបេសកកម្ម។

-សមត្ថភាពរបស់មន្ត្រីរាជការអធិការកិច្ចមួយចំនួនតូចនៅមានកម្រិត។

-ពុំទាន់មានដៃគូរអភិវឌ្ឍជាតិ និងអន្តរជាតិ ជួយគាំទ្រលើវិស័យអធិការកិច្ចឱ្យបានទូលំទូលាយ។

-កិច្ចសហការជាមួយអង្គភាពអធិការកិច្ចតាមក្រសួង រដ្ឋលេខាធិការដ្ឋាន នៅមានកម្រិត។

-សម្ភារបរិក្ខាមួយចំនួន នៅតាមនាយកដ្ឋាន ដូចជា តុ កៅអី ម៉ាស៊ីនថតចំលង ចាប់ផ្តើមដំណើរការ អោក់រអួល និងចាស់ទ្រុឌទ្រោមជាបន្តបន្ទាប់។

-កិច្ចសហការរបស់អង្គភាពរងអធិការកិច្ច និងអ្នកពាក់ព័ន្ធមួយចំនួននៅមានកម្រិត។

-របាយការណ៍អធិការកិច្ចមិនទាន់ឯករាជ្យ ដោយតម្រូវឱ្យឆ្លងប្រធានស្ថាប័ន ឬប្រធានអង្គភាពរង អធិការកិច្ច ចុះហត្ថលេខាយល់ព្រមលើលទ្ធផលអធិការកិច្ច។

## ឃ. ទិសដៅការងារបន្ត

### ១. ការងាររដ្ឋបាលកិច្ចការទូទៅ

#### ១.១. ការងាររដ្ឋបាល

-បន្តគ្រប់គ្រងកិច្ចការរដ្ឋបាលក្រសួងឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងបន្តកែលម្អ ដោយធ្វើការ សម្របសម្រួលគ្រប់បណ្តាអង្គភាព និងមន្ទីររាជធានី-ខេត្ត ជាពិសេសបន្តចូលរួមគ្រប់កំណែទម្រង់រដ្ឋបាល សាធារណៈស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

-បន្តអនុវត្តចរន្តការងាររដ្ឋបាលឱ្យកាន់តែប្រសើរ។

-បន្តទំនាក់ទំនងជាមួយគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ក្នុងការចូលរួមក្នុងពិធី បុណ្យជាតិ អន្តរជាតិ និងពិធីបុណ្យផ្សេងៗទៀត។

**១.២. ការងារបុគ្គលិក និងធនធានមនុស្ស**

-បន្តទំនាក់ទំនង និងសម្របសម្រួលជាមួយក្រសួងមុខងារសាធារណៈលើការងារបុគ្គលិក និងធនធានមនុស្ស។

-បន្តអនុវត្តនូវរាល់ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ លិខិតបទដ្ឋានគតិយុត្តផ្សេងៗ របស់រាជរដ្ឋាភិបាល។

-បន្តធ្វើទំនាក់ទំនងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពាក់ព័ន្ធនឹងការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ បាត់បង់សម្បទាវិជ្ជាជីវៈ ឬបាត់បង់សមត្ថភាពការងារ។

-ពង្រឹងការងារពិនិត្យផ្តល់ទិដ្ឋាការលើរបាយការណ៍ស្តីពីស្ថានភាពរដ្ឋបាល និងស្ថានភាពប្រែប្រួលរបស់មន្ត្រីរាជការថ្នាក់រាជធានី-ខេត្តឱ្យបានទាន់ពេលវេលា។

**១.៣. ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់**

-បន្តទំនាក់ទំនងការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារជាតិ និងធនាគារជាតិ ក្នុងកិច្ចការស្នើសុំថវិកានានាតាមខ្ទង់ ជំពូក ដើម្បីបម្រើការងារក្រសួងឱ្យដំណើរការល្អប្រសើរដូចជាថវិកាសម្រាប់បៀវត្ស ដំណើរការរដ្ឋបាលទូទៅ បេសកកម្មក្នុងប្រទេស និងក្រៅប្រទេស។ល។

**១.៤. ការងារផែនការ និងស្ថិតិ**

-បន្តរៀបចំផែនការថវិកាប្រចាំឆ្នាំ២០២០ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-ត្រៀមរៀបចំរបាយការណ៍សមិទ្ធកម្ម ស្តីពីលទ្ធផល នៃការអនុវត្តថវិកាឆមាសទី១ ឆ្នាំ២០១៩ ដើម្បីធ្វើការបូកសរុបជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-ចុះណែនាំការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការថវិកាប្រចាំឆ្នាំ២០២០ របស់ក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បន្តបញ្ចូលទិន្នន័យស្ថិតិផ្លូវការដែលមានការចាត់តាំងតាមវិស័យ និងពិនិត្យឡើងវិញជាបណ្តើរៗ។

-ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីសម្រាប់ការិយាល័យដើម្បីអនុវត្តឆ្នាំ២០១៩។

-រៀបចំតារាងតាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។

-ត្រៀមចូលរួមវគ្គបណ្តុះបណ្តាលលើការងារកសាងផែនការឱ្យកាន់តែមានប្រសិទ្ធភាព។

**១.៥. ការងារសហប្រតិបត្តិការអន្តរជាតិ**

-បន្តទំនាក់ទំនង និងសហប្រតិបត្តិការជាមួយស្ថានទូតចិន និងក្រសួងត្រួតពិនិត្យនៃសាធារណរដ្ឋប្រជាមានិតចិន និងអធិការកិច្ចរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីត្រៀមជំរុញអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងស្ថាប័នទាំងពីរ។

-បន្តសហការជាមួយវិទ្យាស្ថានសន្ទនាមេគង្គ(MDI) និងវិទ្យាស្ថានខុងជឺ នៃរាជបណ្ឌិត្យសភាកម្ពុជា។

-បន្តទំនាក់ទំនងពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍។

-បន្តទំនាក់ទំនងជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

-បន្តការសិក្សាស្រាវជ្រាវបណ្តាប្រទេសជាសមាជិកអាស៊ាន និងអង្គការអន្តរជាតិ។

-ត្រៀមចូលរួមអនុវត្តការងារដែលថ្នាក់ដឹកនាំប្រគល់ជូន។

## ២. ការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

### ២.១. ការងារនីតិកម្ម

-រៀបចំផែនការសកម្មភាពការងារដើម្បីចុះស្ទង់មតិប្រជាពលរដ្ឋស្ដីពីការយល់ដឹងលើច្បាប់។

-ស្រាវជ្រាវប្រមូលឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីបញ្ចូលក្នុងគេហទំព័របណ្ណាល័យអេឡិចត្រូនិច។

-ចូលរួមរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង។

### ២.២. ការងារអប់រំផ្សព្វផ្សាយច្បាប់

-រៀបចំផែនការសកម្មភាព និងទំនាក់ទំនងជាមួយអាជ្ញាធររាជធានី-ខេត្ត ដើម្បីផ្សព្វផ្សាយច្បាប់។

-រៀបចំផែនការសកម្មភាពដើម្បីចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ មុន និងក្រោយការផ្សព្វផ្សាយច្បាប់។

-សិក្សាស្រាវជ្រាវឯកសារ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនិងច្បាប់។

-សហការជាមួយនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ដើម្បីរៀបចំបោះពុម្ពអត្ថបទច្បាប់។

### ២.៣. ការងារទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា

-ចូលរួមប្រជុំអន្តរក្រសួង និងតាមក្រសួង-ស្ថាប័ន។

-ចូលរួមស្ដាប់សម័យប្រជុំពេញអង្គ វិសាមញ្ញ នៅមន្ទីររដ្ឋសភា-ព្រឹទ្ធសភា។

-ចុះអមដំណើរជាមួយតំណាងរាស្ត្រ និងគណៈកម្មការនានានៃរដ្ឋសភាជាតិ។

-ចុះអមដំណើរជាមួយគណៈកម្មការនានា ក្រុមសមាជិកព្រឹទ្ធសភាតាមភូមិភាគ និងក្រុមសមាជិកសមាជិកា នៃព្រឹទ្ធសភា។

-រៀបចំផែនការសកម្មភាពចុះធ្វើវេទិកាសាធារណៈ ដើម្បីទទួលសំណូមពរពីប្រជាពលរដ្ឋ។

## ៣. ការងារអធិការកិច្ច

### ៣.១. ការងារអធិការកិច្ច (វិស័យសេដ្ឋកិច្ច រដ្ឋបាលទូទៅ និងសង្គមកិច្ច)

-បន្តអនុវត្តការងារអធិការកិច្ចដែលពុំទាន់បានធ្វើចប់ក្នុងឆ្នាំ២០១៩។

-អនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០២០។

-ពង្រឹងការងារគ្រប់គ្រងរដ្ឋបាល និងចងក្រងគំរូឯកសារសម្រាប់ត្រៀមលក្ខណៈសម្បត្តិដើម្បីអនុវត្តថវិកាតាមកម្មវិធី។

-រៀបចំ និងកែសម្រួលផែនការប្រតិបត្តិការអធិការកិច្ចឱ្យស្របតាមស្ថានភាពការងារជាក់ស្ដែង។

-ប្រមូលចងក្រងឯកសារគតិយុត្តទាំងឡាយដែលមានប្រយោជន៍ដល់ការងារអធិការកិច្ច។

-រៀបចំផែនការសកម្មភាព និងផែនការថវិកាឆ្នាំ២០២១។

-បណ្ដុះបណ្ដាលមន្ត្រីអធិការកិច្ចតាមរយៈការផ្លាស់ប្ដូរបទពិសោធន៍គ្នា។

### ៣.២. ការងារតាមដានការអនុវត្តច្បាប់

-បន្តចុះតាមដានត្រួតពិនិត្យរាល់ការអនុវត្តច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងអនុសាសន៍របស់នាយករដ្ឋមន្ត្រី ដែលមិនទាន់បានធ្វើចប់ក្នុងឆ្នាំ២០១៩។

-ប្រមូលចងក្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់ចុះតាមដាន។

-អនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០២០។

-ត្រៀមរៀបចំសេចក្តីជូនដំណឹងស្តីពីការជំរុញកែលម្អលើចំណុចខ្វះខាតទៅបណ្តាក្រសួង និងស្ថាប័ន។

-អនុវត្តភារកិច្ចផ្សេងៗទៀតតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង។

### ៣.៣. ការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ

-បន្តរង់ចាំទទួលពាក្យបណ្តឹងពីគ្រប់មជ្ឈដ្ឋាននានា រួមទាំងពាក្យបណ្តឹងក្នុងសារព័ត៌មានផងដែរ។

-បន្ត និងត្រៀមចុះអង្កេតស្រាវជ្រាវពាក្យបណ្តឹងដែលជាសមត្ថកិច្ចក្រសួង។

-ត្រៀមអនុវត្តផែនការសកម្មភាពឆ្នាំ២០២០។

-អនុវត្តភារកិច្ចផ្សេងៗទៀត តាមការសម្រេចរបស់ថ្នាក់ដឹកនាំក្រសួង។

### ៣.៤. ការងារពង្រឹងស្ថាប័ន និងគ្រប់គ្រងមន្ត្រីរាជការ

-បន្តចូលរួមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច។

-បន្តពង្រឹងការគ្រប់គ្រងវត្តមាន និងអវត្តមានមន្ត្រីរាជការ។

-បន្តពង្រឹងរបៀបរបបធ្វើការងារ។

-បន្តចូលរួមប្រជុំការងារក្នុងក្រសួង និងអន្តរក្រសួងតាមការអញ្ជើញ និងចាត់តាំងរបស់ថ្នាក់ដឹកនាំក្រសួង។

-បន្តប្រជុំពង្រឹងរបៀបរបបការងារប្រចាំខែ ស្របតាមសេចក្តីកំណត់ស្តីពីការបែងចែកភារកិច្ច និងរបៀបរបប ការងាររបស់អគ្គនាយកដ្ឋានអធិការកិច្ច។

-បន្តបណ្តុះបណ្តាលផ្ទៃក្នុងអគ្គនាយកដ្ឋាន។

## ៤. ការងារសវនកម្មផ្ទៃក្នុង

-បន្តអនុវត្តការងាររបស់ខ្លួនស្របតាមអនុក្រឹត្យលើលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ និងប្រកាសលេខ០៧៣ ទរពអ.ប្រក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ ចំណុះនាយកដ្ឋាននៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

## ៥. ការងារវិទ្យាស្ថានជាតិអធិការកិច្ច

-កសាងលិខិតបទដ្ឋានគតិយុត្ត និងយន្តការពាក់ព័ន្ធ

-អភិវឌ្ឍស្ថាប័ន និងរចនាសម្ព័ន្ធគ្រប់គ្រង

-ពង្រឹងការគ្រប់គ្រងការងាររដ្ឋបាល និងហិរញ្ញវត្ថុ

-ពង្រឹងការងារផែនការ និងស្រាវជ្រាវ

-ពង្រឹងការងារបណ្តុះបណ្តាល

-ពង្រឹងការងារទំនាក់ទំនងសាធារណៈ

## ៦. ការងារផ្សេងៗ

### ៦.១. ការងារយេនឌ័រ

-បន្តផ្សព្វផ្សាយអនុសញ្ញាស៊ី-ដ ។

-ធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បន្តផ្សព្វផ្សាយអំពីស្វែងយល់ទស្សនទានយេនឌ័រ។

-ផ្សព្វផ្សាយអំពីការបញ្ជ្រាបយេនឌ័រ។

-ផ្តល់វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់ស្ត្រីដែលមានតួនាទី។

-បន្តរៀបចំវេទិកាសាធារណៈស្តីពីតម្រូវការ និងបញ្ហាប្រឈមរបស់មន្ត្រីរាជការជាស្ត្រី។

-បន្តរៀបចំវេទិកាសុខភាព ដោយសហការជាមួយមន្ទីរពេទ្យព្រះកេតុមាលា។

-បន្តជំរុញការអនុវត្តផែនការបញ្ជ្រាបយេនឌ័រឱ្យកាន់តែមានប្រសិទ្ធភាព តាមវិស័យទាំងបី នៅថ្នាក់ក្រសួង និងនៅតាមមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្ត។

-រៀបចំផ្តល់ប័ណ្ណសរសើរ និងរង្វាន់ជូនមន្ត្រីរាជការ ដែលបានជាប់ចំណាត់ថ្នាក់ឆ្នើមក្នុងការជម្រុញការងារយេនឌ័រ។

-បន្តសហប្រតិបត្តិការជាមួយក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការងារយេនឌ័រឱ្យដំណើរការទទួលលទ្ធផលខ្ពស់។

**៦.២. ការចងសម្ព័ន្ធមេត្រីភាព**

ក្រសួងនឹងចូលរួមយ៉ាងសកម្មថែមទៀត ក្នុងការពង្រឹងសម្ព័ន្ធមេត្រីភាព ជាមួយកងវរសេនាតូចនគរបាលព្រំដែន ទាំងពីរអង្គភាព ឱ្យកាន់តែជិតស្និទ្ធ ក្នុងន័យផ្តល់កម្លាំងចិត្ត និងសម្ភារ ដើម្បីបង្កើន ជីវភាពរស់នៅរបស់គាត់ឱ្យកាន់តែមានភាពប្រសើរឡើង និងដើម្បីរួមចំណែកថែរក្សាការពារទឹកដីរបស់យើងឱ្យមានសុខសន្តិភាពយូរអង្វែងតរៀងទៅ។

**៦.៣. ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

-ត្រៀមខ្លួនអនុវត្តថវិកាកម្មវិធីទៅតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

-បន្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបណ្តើរៗ ជាជំហានៗ ដើម្បីអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យបានជោគជ័យ។

-អនុវត្តការគ្រប់គ្រងថវិកាក្រសួង តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដែលចាប់ផ្តើមអនុវត្តពីថ្ងៃទី ២ ខែមករា ឆ្នាំ២០២០។

# ខ. សេចក្តីសន្និដ្ឋាន

ក្រសួងបានបំពេញភារកិច្ច ប្រកបដោយទទួលខុសត្រូវខ្ពស់ និងមានប្រសិទ្ធភាព និងជោគជ័យ ទោះជាការងារខ្លះមានការលំបាក ស្មុគស្មាញមានភាពរសើប និងភាពចំរូងចម្រាស់ក្តី។ សមិទ្ធផលការងារដូចបានរៀបរាប់ខាងដើមបានមកដោយសារមានការដឹកនាំ ប្រកបដោយបញ្ញាញាណដ៏ភ្លឺស្វាង និងវាងវៃរបស់លោកជំទាវ រដ្ឋមន្ត្រី និងដោយសារថ្នាក់ដឹកនាំ មន្ត្រី មានសមត្ថភាពពេញលេញ និងជំនាញច្បាស់លាស់ និងមានការយល់ដឹងផ្នែកច្បាប់ ព្រមទាំងក្រមសីលធម៌ស្អាតស្អំ។

ក្រសួងនៅមានការប្រឈមច្រើន ជាពិសេសគឺកង្វះលិខិតបទដ្ឋានគតិយុត្តិ និងក្រមសីលធម៌ទន់ខ្សោយ និងភាពអសកម្មរបស់មន្ត្រីមួយចំនួន។ ទោះជាយ៉ាងនេះក្តី ក៏ក្រសួងបានជម្នះ និងបំពេញតួនាទីទៅ

តាមច្បាប់អនុញ្ញាត ហើយយើងបានឃើញច្បាស់ថា ការងាររបស់យើងពិតជាជួយធានាការពង្រឹងប្រសិទ្ធភាព ការងារស្ថាប័ន អង្គភាពរដ្ឋ ធានាសុវត្ថិភាព និងសិទ្ធិសេរីភាពជូនប្រជាពលរដ្ឋ និងនាំមកនូវតម្លាភាព កាត់បន្ថយបាននូវបាតុភាពអសកម្មនានា ដូចជាតម្រូវឱ្យអនុវត្តកិច្ចសន្យា រវាងក្រុមហ៊ុននានា ជាមួយរដ្ឋបានល្អ ជួយកាត់បន្ថយ និងលុបបំបាត់ ការកឹបកេង និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋខុសទិសដៅ ជាដើម។

ក្រសួងបានតម្រង់ទិស និងណែនាំឱ្យក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋ បង្កើនការប្រុងប្រយ័ត្ន និងទទួលខុសត្រូវខ្ពស់ ក្នុងសកម្មភាពការងាររបស់ខ្លួន ស្របតាមការកែទម្រង់ ស៊ីជម្រៅ ការពង្រឹងនីតិរដ្ឋ និងអភិបាលកិច្ចល្អ។ ដូច្នេះការងារអធិការកិច្ច ពិតជាមានសារៈសំខាន់មិនអាចខ្វះបាន ដើម្បីបម្រើឱ្យផលប្រយោជន៍ជាតិ និងប្រជាពលរដ្ឋយើង ក្នុងពេលដែលព្រះរាជាណាចក្រកម្ពុជា ទទួលបានសន្តិភាពយ៉ាងពិតប្រាកដ និងការអភិវឌ្ឍន៍លើគ្រប់វិស័យ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ។

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខិតខំពុះពាររាល់ការលំបាក ប្រឹងប្រែងអនុវត្តការងារប្រកបដោយប្រសិទ្ធភាព សមត្ថភាព និងមនសិការទទួលខុសត្រូវ ខ្ពស់ ក៏ដោយសារមានការគាំទ្រ និងកិច្ចសហការល្អពីគ្រប់មជ្ឈដ្ឋាន ទាំងស្ថាប័នរដ្ឋ ស្ថាប័នមិនមែនរដ្ឋ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋទូទាំងប្រទេស។

ក្នុងឆ្នាំ២០២០ ខាងមុខ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច គ្រប់លំដាប់ថ្នាក់ នឹងខិតខំប្រឹងប្រែងជាបន្តទៀត ដើម្បីដោះស្រាយ និងកាត់បន្ថយឱ្យបានជា អតិបរមា នូវចំណុចខ្វះខាតរបស់ក្រសួង ក៏ដូចជាបាតុភាពអសកម្មនានា ដែលកើតមានក្នុងសង្គម។ ក្រសួងសូមស្នើ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួង ស្ថាប័ននានា រដ្ឋបាលដែនដីគ្រប់លំដាប់ថ្នាក់ ប្រជាសហគមន៍ និងប្រជាពលរដ្ឋ សូមបន្តចូលរួមសហការ ឱ្យកាន់តែល្អប្រសើរថែមទៀត ដើម្បីសម្រេចបានជោគជ័យ និងសមិទ្ធផលថ្មីៗ បន្ថែមទៀត ជូនជាតិមាតុភូមិនៃយើង។

# ឧបសម្ព័ន្ធ ៣. របាយការណ៍បូកសរុបសន្និបាត

## របាយការណ៍សង្ខេប
## ស្តីពី
## ការបូកសរុបលទ្ធផលសន្និបាត ឆ្នាំ ២០១៩-២០២០
## របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

(អានដោយឯកឧត្តមបណ្ឌិត **ចាប សុថារិទ្ធ** រដ្ឋលេខាធិការ)

សូមគោរពលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** នាយករដ្ឋមន្ត្រី
ឯកឧត្តមរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអគ្គនាយកដ្ឋានទាំងបី
ឯកឧត្តម នាយកខុទ្ទកាល័យ
ឯកឧត្តម លោកជំទាវ លោក លោកស្រី
អង្គសន្និបាតទាំងមូល ជាទីមេត្រី

ក្នុងរយៈពេលពេញមួយថ្ងៃនេះ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានប្រារព្ធសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ ២០១៩ និងលើកទិសដៅឆ្នាំ ២០២០ ដែលគ្រោងបញ្ចប់នៅពេលល្ងាចនាថ្ងៃនេះ។

អង្គសន្និបាតដែលចូលរួម ដោយថ្នាក់ដឹកនាំក្រសួង ទាំងថ្នាក់ជាតិ និងថ្នាក់រាជធានី-ខេត្ត និងភ្ញៀវកិត្តិយសមកពីបណ្តាក្រសួង ស្ថាប័ន និងរាជធានី ខេត្តទាំងអស់ដែលមានអ្នកចូលរួមសរុបចំនួន ៦០៥ នាក់ បានប្រព្រឹត្តទៅដោយរលូនតាមកម្មវិធីដែលបានគ្រោងទុក។

នៅពេលព្រឹកបន្ទាប់ពី ខ្ញុំបានអានរបាយការណ៍បូកសរុបលទ្ធផលការងារ ឆ្នាំ ២០១៨ និងទិសដៅឆ្នាំ ២០១៩សង្ខេបមក លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី បានថ្លែងសុន្ទរកថាបើកសន្និបាត ដោយបានបញ្ជាក់ពីប្រវត្តិសង្ខេបរបស់ក្រសួង និងតួនាទីភារកិច្ចរបស់ក្រសួង។ លោកជំទាវបានសម្តែងនូវមោទនភាព កោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ ក៏ដូចជាមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងបណ្តាក្រសួង-ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ ដែលបានខិតខំរួមចំណែក ក្នុងកិច្ចសហការជាមួយក្រសួងដើម្បីបំពេញការងារជូនរាជរដ្ឋាភិបាល និងបំរើប្រជាជន លើវិស័យការងារទំនាក់ទំនង សម្របសម្រួលជាមួយរដ្ឋសភា ព្រឹទ្ធសភា ការផ្សព្វផ្សាយច្បាប់ ការងារអធិការកិច្ច ការតាមដានការអនុវត្តច្បាប់ ការទទួលអង្កេត និងដោះស្រាយបណ្តឹងនានា ដើម្បីរួមចំណែកពង្រឹងអភិបាលកិច្ចល្អ ដែលជាឧត្តមប្រយោជន៍របស់សង្គមជាតិទាំងមូល។ លោកជំទាវក៏បានផ្តល់ការណែនាំ ដល់អង្គសន្និបាត ដើម្បីបន្តការពិភាក្សាលើរបាយការណ៍ និងពិភាក្សាតាមក្រុម។

ក្រោយពីសម្រាកពិសាអាហារសម្រន់ពេលព្រឹក អង្គសន្និបាតបានធ្វើកិច្ចប្រជុំរួម (Planary Session) ដោយបើកទូលាយ ឱ្យមានការចូលរួមជាបទអន្តរាគមន៍ ជាការលើកយោបល់ និងសំណួរ

នានាពីអង្គសន្និបាតទាំងមូល។ ជាការឆ្លើយតប គណៈអធិបតី ដែលជាឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការក្រសួង និងសម្របសម្រួលដោយឯកឧត្តម រដ្ឋលេខាធិការប្រចាំការ **ឆេង សារឿន** បានកត់ត្រាទុកជាធាតុចូល និងបានឆ្លើយតប ពន្យល់ និងបកស្រាយជូនអង្គសន្និបាតទៅតាមវិស័យទទួលខុសត្រូវរៀងៗខ្លួនបានយ៉ាងច្បាស់ និងក្បោះក្បាយ។

ក្រោយពីសម្រាកពិសាបាយថ្ងៃត្រង់នៅសណ្ឋាគារសុខា អ្នកចូលរួមសន្និបាតត្រូវបានបែងចែកជាបីក្រុម ដើម្បីពិភាក្សាលើប្រធានបទ ដូចខាងក្រោម៖

- ក្រុមទី១ ដឹកនាំដោយឯកឧត្តម **ភេង ណែម** មានប្រធានបទ "ការប្រឈមក្នុងការងារទំនាក់ទំនងជាមួយរដ្ឋសភា -ព្រឹទ្ធសភា ការតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ និងការផ្សព្វផ្សាយច្បាប់" ។
- ក្រុមទី២ ដឹកនាំដោយឯកឧត្តម **ឆេង សារឿន** មានប្រធានបទ "ការប្រឈមក្នុងការងារអធិការកិច្ច ដោះស្រាយពាក្យបណ្តឹង និងការតាមដានការអនុវត្តច្បាប់" និង
- ក្រុមទី៣ ដឹកនាំដោយឯកឧត្តម **ចាប សុថារិទ្ធ** មានប្រធានបទ "ការប្រឈមក្នុងការងាររដ្ឋបាល ផែនការ ការបណ្តុះបណ្តាល ហិរញ្ញវត្ថុ និងផ្គត់ផ្គង់"

ក្រោយពីពិភាក្សារួច ក្រុមនិមួយៗបាន លើកឡើងពីការប្រឈមដូចខាងក្រោម៖

ក្រុមទី១៖

- ខ្វះមធ្យោបាយធ្វើដំណើរ ជាពិសេសក្នុងបេសកកម្មផ្សព្វផ្សាយច្បាប់។
- ប្រាក់បេសកកម្ម និងប្រេងសាំងនៅមានកំរិត។
- សមត្ថភាពវិភាគនៃការស្ទង់មតិប្រជាពលរដ្ឋទាក់ទងនឹងការយល់ដឹងពីច្បាប់ជាដើម នៅមានកំរិត។
- សមត្ថភាព តាក់តែងសេចក្តីព្រាង ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នានាទាក់ទងនឹងវិស័យអធិការកិច្ច នៅមានកំរិត។
- ច្បាប់អធិការកិច្ចនៅមិនទាន់បានអនុម័ត ដោយសារក្រសួង ស្ថាប័នមួយចំនួនជំទាស់នឹងបញ្ហាខ្លះដែលជាន់ភារកិច្ចគ្នា។

ក្រុមទី២៖

- ខ្វះកិច្ចសហការពីស្ថាប័នពាក់ព័ន្ធ ជាពិសេសស្ថាប័នដែលរងអធិការកិច្ច។
- ជាន់ភារកិច្ចគ្នាជាមួយស្ថាប័នមួយចំនួន ដែលបង្កឱ្យមានការលំបាកក្នុងការបំពេញភារកិច្ច។
- ការគាំទ្រ និងការលើកទឹកចិត្តពីថ្នាក់ដឹកនាំកំពូល នៅមានកំរិតនៅឡើយ។
- ការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមការងារអធិការកិច្ច និងក្រុមបេសកកម្មផ្សេងទៀតនៅមិនទាន់បានល្អត្រឹមត្រូវ។
- កង្វះមធ្យោបាយធ្វើដំណើររួម។
- ប្រាក់បេសកកម្ម នៅមានភាពរអាក់រអួលខ្លះ។
- ការដោះស្រាយពាក្យបណ្តឹងនៅមានការលំបាក ដោយកង្វះកិច្ចសហការពីស្ថាប័នពាក់ព័ន្ធ និងកង្វះមធ្យោបាយ សម្ភារៈ និងការលើកទឹកចិត្ត។

ក្រុមទី៣៖

- ការកែទម្រង់ផ្ទៃក្នុងនៅមានការលំបាក។
- ថវិកាក្រសួងមានទំហំតូច ដែលពិបាកនឹងបំពេញភារកិច្ចឱ្យបានជោគជ័យទាំងស្រុង ឬ ១០០ភាគរយ។
- ចរន្តលិខិតចេញចូលនៅយឺតយ៉ាវ។
- ការផ្សព្វផ្សាយព័ត៌ននានាមាននៅមានភាពយឺតយ៉ាវ។
- កង្វះការថែទាំ អនាម័យ និងសណ្ដាប់ធ្នាប់។
- វិន័យការងារនៅមានកំរិត ដោយនៅមានអវត្តមានច្រើន ។
- ការបែងចែកភារកិច្ចផ្ទៃក្នុងក្រសួង នៅមិនទាន់មានសមភាព ដោយផ្នែកខ្លះរវល់ខ្លាំង និង ផ្នែកខ្លះមិនសូវមានការងារធ្វើច្រើន។
- សាមគ្គី និងឯកភាពផ្ទៃក្នុង នៅមានបញ្ហាខ្លះ។

ទោះជាមានការប្រឈមខ្លះក្ដី ក៏ជារួម សន្និបាតបានវាយតម្លៃ ខ្ពស់ចំពោះជោគជ័យ នៃឆ្នាំ ២០១៩ ដោយថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ខិតខំពុះពាររាល់ការលំបាក ប្រឹងប្រែងអនុវត្តការងារប្រកបដោយប្រសិទ្ធភាព សមត្ថភាព និង មនសិការទទួលខុសត្រូវខ្ពស់ និងដោយសារមានការគាំទ្រ និងកិច្ចសហការល្អពីគ្រប់មជ្ឈដ្ឋាន ទាំងស្ថាប័ន រដ្ឋ ស្ថាប័នឯកជន អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋទូទាំងប្រទេស។

ក្នុងឆ្នាំ ២០២០ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច គ្រប់លំដាប់ថ្នាក់ ប្ដេជ្ញាខិតខំប្រឹងប្រែងជាបន្តទៀត ដើម្បីដោះស្រាយ និងកាត់បន្ថយឱ្យបាន ជា អតិបរមា នូវចំណុចខ្វះខាតរបស់ក្រសួង ក៏ដូចជាបាតុភាពអសកម្មនានាដែលកើតមានក្នុងសង្គម។

ក្រសួងសូមស្នើ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួង ស្ថាប័ននានា រដ្ឋបាលដែនដីគ្រប់លំដាប់ថ្នាក់ ប្រជាសហគមន៍ និងប្រជាពលរដ្ឋ សូមបន្តចូលរួមសហការ ឱ្យកាន់តែល្អប្រសើរថែមទៀត ដើម្បីសម្រេច បានជោគជ័យ និងសមិទ្ធផលថ្មីៗ បន្ថែមទៀត ជូនជាតិមាតុភូមិនៃយើង។

ក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំបាទសូមគោរពអញ្ជើញ លោកជំទាវកិត្តិសង្គហបណ្ឌិត មេត្តាថ្លែង សុន្ទរកថាបិទសន្និបាត សូមគោរពអញ្ជើញ។

# ឧបសម្ព័ន្ធ ៤. សុន្ទរកថា បើកសន្និបាត

**សុន្ទរកថា**

លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន**

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

ក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០២០

របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

សណ្ឋាគារ សុខាភ្នំពេញ រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែមករា ឆ្នាំ ២០២០

**ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា នៃអង្គសន្និបាត ជាទីមេត្រី!**

ជាបឋម ដោយសេចក្តីរីករាយ និងមោទនភាព ខ្ញុំសូមស្វាគមន៍ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ក្រសួង រួមនឹងភ្ញៀវកិត្តិយសទាំងអស់ ដែលបានចូលរួមក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០២០ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចនាពេលនេះ។

យើងជួបជុំគ្នាក្នុងសន្និបាត ដែលមានរយៈពេលពេញមួយថ្ងៃនេះមានគោលបំណងត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបលទ្ធផលការងារដែលក្រសួងសម្រេចបានក្នុងឆ្នាំ២០១៩កន្លងមក ដោយលើកឡើងពីការប្រឈមនានា និងផ្លាស់ប្តូរយោបល់ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះ ដោយដាក់ចេញវិធានការណ៍ និងទិសដៅថ្មីៗ សម្រាប់អនុវត្តបន្តក្នុងឆ្នាំ២០២០ ដើម្បីសម្រេចបានលទ្ធផលទៅតាមផែនការ និងយុទ្ធសាស្ត្រដូចដែលរាជរដ្ឋាភិបាលបានប្រគល់ជូន។

សន្និបាតនេះ មានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួង ទាំងនៅ ថ្នាក់កណ្តាល ទាំងថ្នាក់រាជធានី ខេត្ត និងឯកឧត្តម លោកជំទាវ ជាភ្ញៀវកិត្តិយសដែលអញ្ជើញមកពីស្ថាប័នរដ្ឋផ្សេងៗ ទាំងថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្តជាច្រើនផងដែរ ជាពិសេសតំណាងពីអគ្គាធិការដ្ឋាន នៃក្រសួងស្ថាប័នរដ្ឋ។ ខ្ញុំសូមយកឱកាសដ៏ថ្លៃថ្លានេះថ្លែងអំណរគុណ ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ដែលមានបានចំណាយពេលដ៏មានតម្លៃមកចូលរួមក្នុងពិធីនេះ។

តាមរយៈរបាយការណ៍ដែលចែកជូនអង្គសន្និបាត និងរបាយការណ៍សង្ខេបដែលអានដោយឯកឧត្តមរដ្ឋលេខាធិការ ចាប សុថារិទ្ធ ខ្ញុំពិតជាមានមោទនភាព និងសូមកោតសរសើរថ្នាក់ដឹកនាំ និងជាមន្ត្រីរាជការក្នុងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រួមទាំងមន្ទីរទាំងអស់ ដែលបានខិតខំបំពេញការងារយ៉ាងសកម្ម ប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងឆ្នាំ ២០១៩កន្លងទៅ។ ខ្ញុំក៏សូមអរគុណដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៅបណ្តាក្រសួង-ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ ដែលបានខិតខំរួមចំណែក ក្នុងកិច្ចសហការជាមួយក្រសួង ដើម្បីបំពេញការងារជូនរាជរដ្ឋាភិបាល និងបំរើប្រជាជនលើវិស័យការងារទំនាក់ទំនង សម្របសម្រួលជាមួយរដ្ឋសភា ព្រឹទ្ធសភា ការងារ ផ្សព្វផ្សាយច្បាប់ ការងារអធិការកិច្ច ការទទួល និងដោះស្រាយបណ្តឹងនានា ដើម្បីរួមចំណែកពង្រឹងអភិបាលកិច្ចល្អ ដែលជាឧត្តមប្រយោជន៍របស់សង្គមជាតិទាំងមូល។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គសន្និបាតទាំងមូលជាទីមេត្រី !*

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច គឺជាស្ថាប័នរដ្ឋដែលជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាលមានប្រវត្តិយូរយាមកហើយ និងបានវិវត្តទៅតាមស្ថានការណ៍នយោបាយនៅកម្ពុជា។ យើងពិតជានៅចងចាំបានថា កាលពីឆ្នាំ ១៩៨១ នៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា "**ក្រសួងត្រួតពិនិត្យកិច្ចការរដ្ឋ**" ដែលជាស្ថាប័នគ្រប់គ្រងការត្រួតពិនិត្យ និងអធិការកិច្ច ត្រូវបានបង្កើតឡើងដើម្បីត្រួតពិនិត្យការអនុវត្តច្បាប់ និងដោះស្រាយបាតុភាពអសកម្ម នានាជាពិសេសដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ប្រជាជន។ ក្រោយមក នៅឆ្នាំ ១៩៨៧ ក្រសួងត្រួតពិនិត្យកិច្ចការរដ្ឋត្រូវប្តូរឈ្មោះជា "**ក្រសួងត្រួតពិនិត្យ**" វិញ។ ពេលនោះគ្មានស្ថាប័នទទួលបន្ទុកវិស័យទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភាទេ។

ក្រសួងត្រួតពិនិត្យ ស្ថិតនៅចំណុះក្រុមប្រឹក្សារដ្ឋមន្ត្រី (ដែលបច្ចុប្បន្នយើងហៅថារដ្ឋាភិបាល ឬគណៈរដ្ឋមន្ត្រី) និងមានបណ្តាញរបស់ខ្លួននៅតាមក្រសួង ខេត្ត ក្រុង ខណ្ឌ ស្រុក ស្រុកទីរួមខេត្ត ដែលមានឈ្មោះថា គណៈកម្មាធិការត្រួតពិនិត្យក្រសួង ខេត្ត ក្រុង ខណ្ឌ ស្រុក ទីរួមខេត្ត ដើម្បីធ្វើការងារត្រួតពិនិត្យ និងដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ពលរដ្ឋ ដែលស្ថិតក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន។

ក្រោយពីការបោះឆ្នោតសកលឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលចម្រុះ ក្នុងនីតិកាលទី ១ នៃរដ្ឋសភា (១៩៩៣-១៩៩៨) ស្ថាប័នទទួលបន្ទុកទំនាក់ទំនងរដ្ឋសភា និងស្ថាប័នទទួលបន្ទុកអធិការកិច្ច ត្រូវបានបង្កើតឡើងដាច់ដោយឡែកពីគ្នា។ "រដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា" (ពេលនោះយើងមិនទាន់មានស្ថាប័នព្រឹទ្ធសភាទេ) ជាស្ថាប័នមួយ និង "អគ្គលេខាធិការដ្ឋានអធិការកិច្ច" ជាស្ថាប័នផ្សេងមួយទៀត។ ស្ថាប័នទាំងពីរ ស្ថិតក្រោមចំណុះទីស្តីការគណៈរដ្ឋមន្ត្រីដូចគ្នា។ ក្រោយមកនៅឆ្នាំ ១៩៩៩ ស្ថាប័នទាំងពីរខាងលើ ត្រូវបានប្រាបាច់បញ្ចូលគ្នាទៅជា "ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា- ព្រឹទ្ធសភា និងអធិការកិច្ច" ដែលកំពុងដំណើរការរហូតមកដល់សព្វថ្ងៃ។

ក្រសួងមានភារកិច្ច ដឹកនាំគ្រប់គ្រង សម្របសម្រួលការងារ តាមរយៈទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងធ្វើអធិការកិច្ច លើគ្រប់វិស័យក្នុងព្រះរាជាណាចក្រកម្ពុជា។ បេសកកម្មចំបងរបស់ក្រសួង គឺត្រួតពិនិត្យតាមដានការអនុវត្តច្បាប់ ទប់ស្កាត់អំពើពុករលួយ ភាពអយុត្តិធម៌ក្នុងសង្គម និងការរំលោភបំពានដោយប្រើអំណាច ដើម្បីបំរើប្រយោជន៍បុគ្គល និងបក្សពួក គ្រួសារ និងការពារសិទ្ធរបស់ពលរដ្ឋ និងសុវត្ថិភាពសាធារណៈ ពោលគឺពង្រឹងអភិបាលកិច្ចល្អ ដែលជាស្នូល នៃយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព របស់រាជរដ្ឋាភិបាល។

ដូច្នេះ ការងារសំខាន់ទី ១ របស់ក្រសួងគឺ **ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា** ដែលក្រសួងមានភារកិច្ចសម្របសម្រួល ធ្វើទំនាក់ទំនងរវាងរាជរដ្ឋាភិបាល ជាមួយស្ថាប័នរដ្ឋសភា និងព្រឹទ្ធសភា និងចូលរួមតាក់តែងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាល លើកកម្ពស់ការយល់ដឹងពីច្បាប់ និងការអនុវត្តន៍ច្បាប់ ដោយធ្វើការផ្សព្វផ្សាយច្បាប់យ៉ាងទូលំទូលាយ ជូនដល់ប្រជាពលរដ្ឋនៅទូទាំងប្រទេសឱ្យបានយល់ដឹង។ ក្រៅពីការងារខាងលើ ក្រុមការងារក្រសួងបានចុះទៅដល់គ្រប់ខេត្ត ក្រុង ស្រុក ទីប្រជុំជន ជនបទដាច់ស្រយាល និងសហគមន៍នានា ដើម្បីបើកវេទិកាសាធារណៈ អប់រំ ផ្សព្វផ្សាយច្បាប់ ធ្វើការស្ទាបស្ទង់មតិ ដើម្បីស្វែងយល់ពីទុក្ខលំបាករបស់ប្រជាពលរដ្ឋ ផ្សព្វផ្សាយរាល់អនុសាសន៍ ដ៏ថ្លៃថ្លា

របស់ថ្នាក់ដឹកនាំ ពិសេសកម្មវិធីនយោបាយ ផែនការ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជូនដល់ប្រជាពលរដ្ឋ ហើយពាំនាំនូវសំណូមពររបស់ប្រជាពលរដ្ឋ ជូនរាជរដ្ឋាភិបាលដើម្បីដោះស្រាយ។

ចំណែកការងារសំខាន់ទី២គឺ **ការងារអធិការកិច្ច** ដែលត្រូវអនុវត្តតាមស្ថាប័ន និងអង្គភាពនានាជាប្រចាំ ដែលនេះជាភារកិច្ចដ៏សំខាន់ទាក់ទងនឹងការពង្រឹងការអនុវត្តន៍ច្បាប់ សំដៅធានាប្រឆាំងអំពើពុករលួយ ការរំលោភដោយអំណាច និងបាតុភាពអសកម្មនានា នៅក្នុងជួររដ្ឋបាលសាធារណៈ ក៏ដូចជាផ្នែកមិនមែនរដ្ឋ ដើម្បីធានាការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនៃថវិកា និងទ្រព្យសម្បត្តិរដ្ឋ ការពារសុវត្ថិភាពសាធារណៈ និងការពារសិទ្ធរបស់ប្រជាពលរដ្ឋ។

ក្រៅពីការងារខាងលើ ក្រសួងនៅមានភារកិច្ចច្រើនទៀត ដូចជាការតាមដានការអនុវត្តច្បាប់ ការទទួលពាក្យបណ្ដឹង និងអង្កេតស្រាវជ្រាវ ដោះស្រាយពាក្យបណ្ដឹង បណ្ដុះបណ្ដាលជំនាញអធិការកិច្ច តាមរយៈវិទ្យាស្ថានជាតិអធិការកិច្ច និងរដ្ឋបាលកិច្ចការទូទៅដើម្បីទ្រទ្រង់ដំណើរការ និងពង្រឹងប្រសិទ្ធភាពការងារក្រសួង។

## *អង្គសន្និបាតទាំងមូលជាទីមេត្រី*

ការធ្វើអធិការកិច្ច និងការពង្រឹងការអនុវត្តច្បាប់ និងបង្កើនប្រសិទ្ធភាពការងារពោលគឺសំដៅទៅលើការកាត់បន្ថយ និងទប់ស្កាត់អំពើពុករលួយ ព្រោះអំពើពុករលួយធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរណាស់ដល់ប្រទេសជាតិ ដូចជាបង្កការខាតបង់ថវិការដ្ឋ ទ្រព្យសម្បត្តិសាធារណៈ រាំងស្ទះដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច បង្កឧបសគ្គដល់ធុរកិច្ច និងការបាត់បង់ដល់ការប្រកួតប្រជែង ដោយសេរី និងយុត្តិធម៌ និងរំខានដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងធ្វើឱ្យប្រជាពលរដ្ឋបាត់បង់ជំនឿមកលើរាជរដ្ឋាភិបាល។

អភិបាលកិច្ចល្អជាផ្នែកមួយ យ៉ាងសំខាន់ ក្នុងការជម្រុញ និងគាំទ្រដំណើរការនៃការគ្រប់គ្រងធនធានរបស់ស្ថាប័ន អង្គភាព និងការអភិវឌ្ឍនមួយប្រកបដោយនិរន្តរភាព។ អភិបាលកិច្ចដែលប្រកបដោយសុភវិនិច្ឆ័យ គឺជាអភិបាលកិច្ចល្អដោយការចាត់ចែង និងការគ្រប់គ្រងបញ្ហា និងធនធានសាធារណៈប្រកបដោយប្រសិទ្ធភាពហើយឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍របស់សង្គមជាតិទាំងមូល។ ដោយយល់ឃើញពីសារៈសំខាន់ នៃអភិបាលកិច្ចល្អ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសថា "អភិបាលកិច្ចល្អគឺជាបុរេល័ក្ខ័ណ្ឌសំខាន់បំផុតសម្រាប់ដើម្បីធានាឱ្យមានការអភិវឌ្ឍសង្គម សេដ្ឋកិច្ចប្រកបដោយចីរភាព សមធម៌ និងយុត្តិក្នុងសង្គម" និងយកពាក្យនេះដាក់ជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ។

ការទប់ស្កាត់ និងប្រឆាំងអំពើពុករលួយ និងការជម្រុញអភិបាលកិច្ចល្អទាមទាឱ្យមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័ន អង្គភាព ទាំងវិស័យរដ្ឋ និងឯកជន។ ដោយសារការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើពុករលួយ ត្រូវផ្ដោតទៅលើអភិក្រមជាសារវន្ដ៍ចំនួន ៣ គឺៈ ការអប់រំបង្ការទប់ស្កាត់ជាមុន ការអនុវត្តច្បាប់ និងការចូលរួមគាំទ្រពីមហាជន។ ដូច្នេះការងារអធិការកិច្ច និងការពង្រឹងការអនុវត្តច្បាប់ មិនអាចផ្ដាច់ចេញពីការអប់រំផ្សព្វផ្សាយច្បាប់ជូនដល់មហាជន និងការចូលរួមរបស់ប្រជាជនបានឡើយ។ ដូច្នេះការងារស្នូលដ៏សំខាន់របស់ក្រសួង គឺធានាការដឹកនាំគ្រប់គ្រងរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងនីតិរដ្ឋ ដើម្បីពង្រឹងអភិបាលកិច្ចល្អ និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម។

ចាប់តាំងពីការបង្កើតស្ថាប័ននេះមក ក្រសួងសម្រេចបានលទ្ធផលជាច្រើន ជាពិសេសក្នុងការងារស្នូលដូចជា អធិការកិច្ច ការទទួល និងដោះស្រាយពាក្យបណ្ដឹង (បណ្ដឹងតវ៉ា និងបណ្ដឹងបរិហារ) ការចុះ

ស៊ើបអង្កេតករណីបណ្តឹងពាក់ព័ន្ធទំនាស់ដីធ្លី ការសម្របសម្រួលបញ្ចប់ទំនាស់ពុំរ៉ៃ បានជាច្រើនករណី ការតាមដានការអនុវត្តច្បាប់ ការកែលម្អរចំណុចខ្វះខាតរបស់ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈ លើកិច្ចការរដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ ជម្រុញប្រសិទ្ធិភាព ផលិតភាព និងគុណភាពសេវាសាធារណៈ ដើម្បីបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរ។ លើសពីនេះក្រសួងក៏មានភារកិច្ចធ្វើការអប់រំ បង្ការ ទប់ស្កាត់ និងកែលម្អរកំហុសឆ្គង ក្នុងការអនុវត្តការងាររបស់ក្រសួង-ស្ថាប័ន អង្គភាព គ្រឹះស្ថានសាធារណៈ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីកែលម្អរ ជម្រុញលើកកម្ពស់អភិបាលកិច្ចល្អដែលជាស្នូល នៃយុទ្ធសាស្ត្រចតុកោណគ្រប់ដំណាក់កាល ពីដំណាក់កាលទី១ ដល់ទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា ដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ បានដាក់ចេញ នូវយុទ្ធសាស្ត្រចតុកោណ **ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** ដែលមានបួនដំណាក់កាល។ដោយឡែក រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភាបានប្រកាសដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលជារបៀបវារៈគោលនយោបាយសម្រាប់ដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍប្រទេសជាតិសម្រាប់រយៈពេល៥ឆ្នាំជាបន្តទៀត។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ មានអភិបាលកិច្ចល្អជាស្នូល និងមានមុំបួនគឺ ១) ការអភិវឌ្ឍន៍ធនធានមនុស្ស ២) ការធ្វើពិពិធកម្មសេដ្ឋកិច្ច ៣) ការអភិវឌ្ឍន៍វិស័យឯកជន និងការងារ និង ៤) ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងបរិយាប័ន្ន។ យុទ្ធសាស្ត្រថ្មីនេះបានពង្រីកនូវវិសាលភាព សម្រិតសម្រាំងបន្ថែម និងធ្វើអាទិភាពូបនីយកម្មមុំនីមួយៗ នៃចតុកោណយុទ្ធសាស្ត្រទាំង៤ ព្រមទាំងកែលម្អរបៀបវារៈ គោលនយោបាយ និងយន្តការអនុវត្តមួយចំនួនឲ្យកាន់តែល្អប្រសើរឡើង ដើម្បីកសាងមូលដ្ឋានគ្រឹះចាំបាច់ទាំងឡាយ ក្នុងចក្ខុវិស័យប្រែក្លាយឋានៈរបស់ប្រទេសកម្ពុជា ពីប្រទេសមានចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ព្រមទាំងនាំប្រទេសជាតិយើង ឆ្ពោះទៅកាន់ឋានៈជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ខាងមុខ។

ដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណ រាជរដ្ឋាភិបាលបានដាក់ចេញផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដោយមានកំណត់នូវអាទិភាព សូចនាករ និងក្របខ័ណ្ឌពេលវេលាច្បាស់លាស់ សម្រាប់អនុវត្ត និងយន្តការសម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃផ្អែកលើលទ្ធផលការងារ ព្រមទាំងមានកំណត់ការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន ទៅតាមមុំ ឬវិស័យនីមួយៗ ដើម្បីទទួលបានជោគជ័យទៅតាមផែនការ។ លើសពីនេះទៀត រាជរដ្ឋាភិបាលក៏បានត្រៀមលក្ខណៈជាស្រេច ដើម្បីធ្វើកំណែទម្រង់នានា ក្នុងគោលបំណងពង្រឹងសមត្ថភាពមន្ត្រីរាជការស៊ីវិល និងវិស័យឯកជន ដើម្បីទទួលបានផលចំណេញជាអតិបរិមា ពីការធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់កម្ពុជា ទៅក្នុងសហគមសេដ្ឋកិច្ចអាស៊ាន ក្នុងតំបន់ផ្សេងទៀត និងក្នុងសកលលោក។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏មានសង្គតិភាពផងដែរ ជាមួយនឹងឯកសារគោលនយោបាយ តាមវិស័យដ៏ទៃទៀត របស់រាជរដ្ឋាភិបាល។ ដូច្នេះយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ គឺជាឯកសារមេគ្គុទ្ទេសក៍ច្បាស់លាស់ សម្រាប់តម្រែតម្រង់សកម្មភាពរបស់គ្រប់តួអង្គអភិវឌ្ឍន៍ទាំងអស់ ក្នុងគោលដៅបន្ត និងពង្រឹងកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព សម្រាប់រយៈពេលវែងសំដៅជំរុញ

កំណើនសេដ្ឋកិច្ច បន្តបង្កើតការងារ បែងចែកផល នៃកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងធានាឱ្យបាននូវប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ និងការគ្រប់គ្រងធនធានគ្រប់ប្រភេទរបស់ជាតិ ។

ដោយឡែក ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានរួមចំណែកក្នុងការអនុវត្ត យុទ្ធសាស្ត្រចតុកោណ សំដៅពង្រឹង អភិបាលកិច្ចល្អ និងរួមចំណែកប្រយុទ្ធប្រឆាំងអំពើពុករលួយដែលពិតជា ស្របតាមគោលដៅយុទ្ធសាស្ត្រទី ៤ នៃ"**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤**" គឺ "បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ច នៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃសេវាសាធារណៈ សំដៅបំរើប្រជាជនឱ្យបានកាន់តែប្រសើរឡើង ក៏ដូចជាលើកកម្ពស់បរិយាកាសធុរកិច្ច និងស្ថានភាពអំណោយផលសម្រាប់វិនិយោគ។

ជារួម នៅឆ្នាំ ២០១៩ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចសម្រេចបានជោគជ័យ និងសមិទ្ធផលជាច្រើន ក្នុងការបំពេញភារកិច្ចដែលរាជរដ្ឋាភិបាលបានប្រគល់ជូន ដូចដែលបានលើកឡើងក្នុងរបាយការណ៍ដែលបានចែកជូនអង្គសន្និបាត និងត្រូវបានសង្ខេបដោយឯកឧត្តមរដ្ឋលេខាធិការ។ យើងពិតជាមានមោទនភាព និងអំណរសាទរ ចំពោះលទ្ធផលការងារគ្រប់ផ្នែក គ្រប់វិស័យ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ខិតខំសម្រេចបាន ហើយយើងប្តេជ្ញានឹងបន្តការងារឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យថ្មីៗថែមទៀត។

ជាការពិតណាស់ សមិទ្ធផលទាំងនេះ កើតឡើងចេញជាផ្លែផ្កាបាន ដោយសារការមានការដឹកនាំដ៏ត្រឹមត្រូវ និងផែនការ និងយុទ្ធសាស្ត្រច្បាស់លាស់ រួមនឹងការចូលរួមយ៉ាងសកម្មពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួង ដែលសុទ្ធតែជាតួអង្គសំខាន់ៗមិនអាចខ្វះបាន និងការគាំទ្រ និងកិច្ចសហការពីក្រសួង ស្ថាប័ន និងអង្គភាព នានា។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គសន្និបាតទាំងមូលជាទីមេត្រី !*

ដើម្បីសម្រេចបានជោគជ័យក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តម ដូចបានលើកឡើងខាងលើនេះ ទាមទារឱ្យមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ត្រូវពង្រឹងសមត្ថភាព និងគោរពច្បាប់ និងក្រមសីលធម៌មន្ត្រីរាជការ និងខិតខំបំពេញការងារទៅតាមការចាត់តាំង និងតួនាទីរបស់ខ្លួនគ្រប់ៗគ្នា។

ទន្ទឹមនេះ មន្ត្រីរាជការក៏ត្រូវមានលក្ខណៈសម្បត្តិថ្លៃថ្នូ ស័ក្តិសមជាអ្នកបម្រើដ៏ល្អ របស់ប្រជាជនដោយផ្លាស់ប្តូរឥរិយាបទ ប្រែក្លាយខ្លួនទៅជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព និងជាដៃគូអភិវឌ្ឍន៍ដែលអាចទុកចិត្តបាន សំដៅបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង តាមរយៈការបង្កើនប្រសិទ្ធផលសេវាកម្មសាធារណៈ។ ជាមួយគ្នានេះ មន្ត្រីរាជការក្រសួងទាំងអស់ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានល្អ តាមអភិក្រមទាំងប្រាំ របស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** គឺ៖ "**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**" ដែលយើងត្រូវចងចាំ កុំឲ្យភ្លេចខ្លួន។

ក្នុងឱកាសសន្និបាតរយៈពេលពេញមួយថ្ងៃនេះ ខ្ញុំសូមអំពាវនាវសូមឯកឧត្តម លោកជំទាវ លោក លោកស្រីដែលចូលរួមទាំងអស់មេត្តាបង្កើនស្មារតីយកចិត្តទុកដាក់ ប្រើប្រាស់ពេលវេលាដ៏មានប្រយោជន៍នេះ ជា ពិសេស ក្នុងកិច្ចពិភាក្សាតាមក្រុម ដែលបានបែងចែកតាមវិស័យសំខាន់ៗទាំង បីក្រុម គឺ ក្រុមទី១ "ការប្រឈមក្នុងការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា ការតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ និងការផ្សព្វផ្សាយច្បាប់" ក្រុមទី២) "ការប្រឈមក្នុងការងារអធិការកិច្ច ដោះស្រាយ

ពាក្យបណ្តឹង និងការតាមដានការអនុវត្តច្បាប់” និងក្រុមទី៣) “ការប្រឈមក្នុងការងាររដ្ឋបាល ផែនការ ការបណ្តុះបណ្តាល ហិរញ្ញវត្ថុ និងផ្គត់ផ្គង់” នៅពេលរសៀល ដើម្បីផ្លាស់ប្តូរបទពិសោធន៍ លើកឡើងពីចំណុចល្អៗ និងចំណុចមិនទាន់បានកែលម្អ បញ្ហាប្រឈមទាំងឡាយ ព្រមទាំងលើកនូវដំណោះស្រាយដ៏សមស្រប និងប្រកបដោយប្រសិទ្ធភាព ដើម្បីពិនិត្យសម្រេចដាក់ចុះទិសដៅ និងផែនការ សម្រាប់អនុវត្តបន្ត។

មុននឹងបញ្ចប់ ខ្ញុំសូមជូនពរដល់ឯកឧត្តម លោកជំទាវ ជាគណៈអធិបតី និងសមាជិក សមាជិកា នៃអង្គសន្និបាត ទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងពិធី នាពេលនេះសូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាតឃ្លៀងឡើយ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរឲ្យអង្គសន្និបាត សម្រេចបានជោគជ័យ និង**សូមប្រកាសបើកសន្និបាត**បូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០២០ របស់**ក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឆ្នាំ២០១៩-២០២០ ចាប់ពីពេលនេះតទៅ។**

***សូមអរគុណ !***

# ឧបសម្ព័ន្ធ ៥. សុន្ទរកថាបិទសន្និបាត

## សុន្ទរកថា

លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០២០
របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
សណ្ឋាគារ សុខាភ្នំពេញ រាជធានីភ្នំពេញ, ថ្ងៃទី៤ ខែមេសា ឆ្នាំ ២០១៩

**ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា នៃអង្គសន្និបាត ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយក្រៃលែង ដោយបានចូលរួមជាមួយឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងពិធីបិទសន្និបាតប្រចាំឆ្នាំ២០១៩-២០២០ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចនាពេលនេះ។ ក្នុងគោលបំណងបូកសរុបលទ្ធផលការងារដែលក្រសួងបានសម្រេចក្នុងឆ្នាំ២០១៩កន្លងមក និងដាក់ចេញនូវទិសដៅថ្មីៗ សម្រាប់អនុវត្តបន្តក្នុងឆ្នាំ២០២០ សន្និបាតដែលមានរយៈពេលពេញមួយថ្ងៃនេះ សម្រេចបានលទ្ធផលគួរជាទីមោទនៈ។

ខ្ញុំសូមយកឱកាសដ៏ថ្លៃថ្លានេះថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលជាថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួង ទាំងនៅ ថ្នាក់កណ្តាល ទាំងថ្នាក់រាជធានី ខេត្ត និងឯកឧត្តម លោកជំទាវ ជាភ្ញៀវកិត្តិយសដែលអញ្ជើញមកពីក្រសួង ស្ថាប័ន រាជធានី ខេត្តផ្សេងៗដែលបានចូលរួមក្នុងសន្និបាតក្រសួងយើងខ្ញុំ។

ក្រោយពីដំណើរការពេញមួយថ្ងៃមក សន្និបាតយើង បានដំណើរការយ៉ាងរលូន និងទទួលបានការចូលរួមយ៉ាងសកម្ម រួមមានការពិភាក្សាតាមក្រុម ដោយលើកយកប្រធានបទតាមវិស័យចំបងៗ ក្នុងក្រសួង និងលើកឡើងនូវបទពិសោធន៍ល្អៗ ការប្រឈមនានា និងដំណោះស្រាយ ប្រកបដោយភាពជាក់ស្តែង និងលទ្ធភាពដែលមាន និងទទួលបាននូវលទ្ធផលជាផ្លែផ្កាគួរឱ្យកោតសរសើរ។

នេះបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ពីស្មារតីសាមគ្គី និងការខិតខំបំពេញការងាររបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ទាំងថ្នាក់ជាតិ និងរាជធានី-ខេត្ត ដែលបានខិតខំ ប្រឹងប្រែងបំពេញការងារ រួមគ្នាយ៉ាងសស្រាក់សស្រាំ រៀបចំ និងចូលរួមធ្វើបទបង្ហាញ ពិភាក្សាផ្លាស់ប្តូរយោបល់ល្អៗ ដោយប្រើប្រាស់ចំណេះដឹង និងបទពិសោធន៍ ការងារជាក់ស្តែងក្នុងគោលបំណងស្វែងរកឲ្យឃើញបញ្ហាប្រឈម ហើយបានដាក់ចេញជាផែនការសកម្មភាពសម្រាប់អនាគត។

ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលបានប្រឹងប្រែងបំពេញភារកិច្ចស្នូលរបស់ខ្លួន ប្រកបដោយស្មារតី ទទួលខុសត្រូវខ្ពស់ មានក្រមសីលធម៌វិជ្ជាជីវៈ ទទួលបានលទ្ធផលគួរជាទីមោទនៈ ដើម្បីសម្រេចភារកិច្ចដែលរាជរដ្ឋាភិបាលបានប្រគល់ជូន។ នេះជាមោទនភាព និងកិត្តិយសដ៏ធំធេង ដែលក្រសួងទទួលបានជោគជ័យលើការងារជាច្រើន ក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមរបស់ខ្លួន។

ខ្ញុំក៏សូមថ្លែងនូវអំណរគុណ និងការកោតសរសើរដោយស្មោះ ចំពោះគណៈកម្មាការរៀបចំសន្និបាតដែលដឹកនាំដោយឯកឧត្តមរដ្ឋលេខាធិការប្រចាំការ **ឆេង សារឿន** ដែលបានបំពេញការងារយ៉ាងសកម្មដោយបានរៀបចំសន្និបាតឆ្នាំនេះបានល្អប្រសើរ ជោគជ័យ និងការទទួលខុសត្រូវខ្ពស់។

ខ្ញុំសូមអបអរសាទរ និងគាំទ្ររបាយកាណ៍បូកសរុបការងារ ឆ្នាំ២០១៩ និងទិសដៅ សម្រាប់ឆ្នាំ ២០២០ ដែលអង្គសន្និបាតបានសម្រេច។

*អង្គពិធីទាំងមូលជាទីមេត្រី*

រាជរដ្ឋាភិបាលបានដាក់ចេញយុទ្ធសាស្ត្រចតុកោណ ដែលមានបួនដំណាក់កាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ដើម្បីអភិវឌ្ឍប្រទេសជាតិ លើគ្រប់វិស័យ ដោយកំណត់អាទិភាព សូចនាករ និងក្របខ័ណ្ឌពេលវេលាច្បាស់លាស់ សម្រាប់អនុវត្ត និងយន្តការសម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃផ្អែកលើកលទ្ធផលការងារ ព្រមទាំងមានកំណត់ការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន ដើម្បីទទួលបានជោគជ័យ។

ផែនការយុទ្ធ- សាស្ត្រអភិវឌ្ឍជាតិ២០១៩- ២០២៣ គឺជាការឆ្លុះបញ្ចាំងនូវការប្តេជ្ញាចិត្តជាមួយនឹងស្មារតីទទួលខុសត្រូវខ្ពស់ របស់រាជរដ្ឋាភិបាល ក្នុងការសម្រេចឱ្យបាននូវចក្ខុវិស័យកម្មវិធីនយោបាយភិវឌ្ឍជាតិ ប្រកបដោយចីរភាព ឆ្លើយតបទៅនឹងបរិការណ៍អភិវឌ្ឍសង្គម- សេដ្ឋកិច្ច បញ្ហាប្រឈម និងកាលានុវត្តភាពទាំងឡាយ ដែលជាបញ្ហារួមរបស់សង្គមជាតិយើង ដើម្បីឈានទៅសម្រេចបាននូវគោលដៅអាទិភាពរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា។

ការអនុវត្ត**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៤- ២០១៨** កន្លងមក បានធ្វើឱ្យកម្ពុជាសម្រេចបាននូវសមិទ្ធផលជាច្រើន លើគ្រប់វិស័យជាមួយនឹងកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់អត្រា ៧%ក្នុងមួយឆ្នាំ ដែលធ្វើឱ្យកម្ពុជាសម្រេចបានឋានៈជាប្រទេសមានចំណូល មធ្យមកម្រិតទាប ហើយមូលដ្ឋាន នៃកំណើនសេដ្ឋកិច្ចជាតិក៏កាន់ តែមានពិពិធកម្មច្រើនឡើង ភាពក្រីក្រត្រូវបានកាត់បន្ថយមកនៅ ត្រឹមក្រោម ១០% និងគម្លាត នៃចំណូលក្នុងចំណោមប្រជាជនស្ថិត ក្នុងកម្រិតទាប តាមរយៈការបែងចែកផល នៃកំណើនសេដ្ឋកិច្ចដល់ ប្រជាជនគ្រប់ស្រទាប់ ជាពិសេសការអនុវត្តគោលនយោបាយ ដំឡើងបៀវត្សមន្ត្រីរាជការ និងប្រាក់ឈ្នួលអប្បបរមាជាមួយនឹងការ គិតគូរពីសុខុមាលភាពរបស់កម្មករ ការតភ្ជាប់បណ្តាញអគ្គិសនី និង បណ្តាញទឹកស្អាតក្នុងតម្លៃទាប ការពង្រីកវិសាលភាពបេឡាជាតិ របបសន្តិសុខសង្គម និងមូលនិធិសមធម៌ ។

ជាគោលដៅយុទ្ធសាស្ត្រសម្រាប់អាណត្តិថ្មីនេះ រាជរដ្ឋាភិបាលកម្ពុជានឹងផ្តោតអាទិភាពទៅលើការកែទម្រង់អភិបាលកិច្ចសំដៅពង្រឹងស្ថាប័នសាធារណៈ និងកសាងរដ្ឋបាលស្អាតស្អំ ការវិនិយោគលើមូលធនមនុស្ស ការបង្កើតបរិយាកាសអំណោយផលសម្រាប់ធុរកិច្ច និងការវិនិយោគ ព្រមទាំងការពង្រឹងភាពជាដៃគូក្នុងការអភិវឌ្ឍជាមួយគ្រប់ដៃគូដែលមានការពាក់ព័ន្ធ ពិសេសការពង្រឹងសមត្ថភាពកម្ពុជាសម្រាប់សមាហរណកម្មទៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក ដែលទាំងអស់នេះ នឹងធ្វើឱ្យប្រជាជនគ្រប់ៗរូបមានកម្រិតជីវភាពកាន់តែប្រសើរឡើងឥតឈប់ឈរ ហើយរស់នៅយ៉ាងសុខដុមរមនាក្នុងសង្គមកម្ពុជាមួយ ដែលគោរពគុណធម៌ តម្លៃមនុស្ស សេរីភាព ប្រជាធិបតេយ្យ នីតិរដ្ឋ និងយុត្តិធម៌សង្គម។

ដូចប្រសាសន៍សម្តេចតេជោ នាយករដ្ឋមន្ត្រីបានលើកឡើង រាជរដ្ឋាភិបាលនឹងបន្តអនុវត្តនូវវិធានការមុតស្រួច និងជាក់ស្តែងនានា សំដៅពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា រួមមានៈ កាត់បន្ថយថ្លៃឡូជីស្ទីក ជំរុញការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល កាត់បន្ថយថ្លៃអគ្គិសនី និងធានាស្ថិរភាព នៃការផ្គត់ផ្គង់ បន្តធ្វើសាមញ្ញកម្ម និងស្វ័យប្រវត្តិកម្មនីតិវិធីគយ កាត់បន្ថយចំណាយនៃការធ្វើធុរកិច្ចទាំងផ្លូវការ និងក្រៅផ្លូវការ ជំរុញការកែទម្រង់ និងទំនើបកម្មប្រព័ន្ធពន្ធ ដោយឈរលើគោលការណ៍យុត្តិធម៌ សមធម៌សេវាល្អ អភិបាលកិច្ចល្អ និងអនុលោមភាព និងជំរុញលើកកម្ពស់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ជាងនេះទៅទៀត រាជរដ្ឋាភិបាលក្នុងអាណត្តិថ្មីនេះ បានរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី ៤ តាមរយៈ ការរៀបចំបង្កើតមូលដ្ឋាន និងថ្នាលសម្រាប់ការពង្រីកផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដោយផ្តោតជាសំខាន់ទៅលើការអភិវឌ្ឍវិស័យឌីជីថល ទាំងផ្នែករឹង និងទន់ ការរៀបចំអភិវឌ្ឍធនធានមនុស្ស និងជំនាញស្របតាមបរិការណ៍ថ្មីព្រមទាំងការបង្កើតក្របខ័ណ្ឌគតិយុត្តិ និងបទប្បញ្ញត្តិគាំទ្រដែលមានការពាក់ព័ន្ធ។

ដោយឡែក ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចនៅក្នុងដំណាក់កាលនៃការវិវត្តន៍វិស័យឌីជីធល និងដើម្បីបំរើសេវាកម្មឱ្យកាន់តែល្អប្រសើរជូនប្រជាពលរដ្ឋ ក្រសួងបានតម្លើងកម្មវិធីទទួលពាក្យបណ្តឹងអនឡាញ និងគ្រោងដាក់ឱ្យប្រើប្រាស់អ៊ីបណ្ណាល័យ ដែលប្រជាពលរដ្ឋ អាចដាក់ពាក្យបណ្តឹង និងមើលឯកសារច្បាប់នានាតាមកុំព្យូទ័រ និងទូរស័ព្ទដៃបានយ៉ាងងាយស្រួល។ ក្រសួងបានរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្រ និងគោលនយោបាយជាតិជាច្រើនសំដៅពង្រឹង អភិបាលកិច្ចល្អ និងរួមចំណែកប្រយុទ្ធប្រឆាំងអំពើពុករលួយ និងការពារសិទ្ធប្រជាពលរដ្ឋ ដោយសម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់ ដូចមានក្នុងរបាយការណ៍ដែលដាក់ជូនសន្និបាត។

## *ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គសន្និបាតទាំងមូលជាទីមេត្រី !*

ដើម្បីត្រួតពិនិត្យការអនុវត្តច្បាប់ និងសុវត្ថិភាពសាធារណៈ និងជម្រុញអភិបាលកិច្ចល្អ ប្រទេសជាច្រើនក្នុងពិភពលោក កំពុងប្រើប្រាស់យន្តការគ្រប់គ្រងវិស័យអធិការកិច្ច ដោយមានក្រសួង ឬស្ថាប័នទទួលបន្ទុកអធិការកិច្ច និងច្បាប់ស្តីពីអធិការកិច្ចដែលមានខ្លឹមសារ និងវិសាលភាពខុសៗគ្នា ទៅតាមស្ថានភាពជាក់ស្តែងនៃប្រទេសនិមួយៗ។

យន្តការ ជាស្ថាប័ន និងរចនាសម្ព័ន្ធចាត់តាំង ត្រូវដើរទន្ទឹមគ្នានឹងធនធានមនុស្ស ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ ដើម្បីគ្រប់គ្រងវិស័យអធិការកិច្ច។ ប្រទេសខ្លះមានច្បាប់ស្តីពីអធិការកិច្ច តាមវិស័យជំនាញផ្សេងៗគ្នា ដូចជា៖ ច្បាប់អធិការកិច្ចលើទំនិញនាំចូល អធិការកិច្ចលើការដ្ឋានសំណង់ អធិការកិច្ចអចលនទ្រព្យ អធិការកិច្ចការងារ អធិការកិច្ចសុវត្ថិភាពចំណីអាហារ អធិការកិច្ចរោងចក្រ អធិការកិច្ចនេសាទ អធិការកិច្ចយានយន្ត អធិការកិច្ចគ្រឿងចក្រ អធិការកិច្ចគុណភាពអប់រំជាដើម។

ដោយឡែក នៅព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីអធិការកិច្ច និងច្បាប់ពាក់ព័ន្ធមួយចំនួនទៀតកំពុងស្ថិតនៅជាសេចក្តីព្រាង និងមិនទាន់ត្រូវបានអនុម័តនៅឡើយ។ ក្រុមការងាររៀបចំសេចក្តីព្រាងច្បាប់របស់ក្រសួង បានខិតខំបំពេញភារកិច្ចយ៉ាងមុះមុត ប្រកបដោយចំណេះដឹង និងជំនាញដោយមិនបានពឹងផ្អែកជំនាញការបរទេសឡើយ។ ដោយឆ្លងកាត់ការប្រជុំរាប់សិបដង មកទល់ពេលនេះ ច្បាប់នោះកំពុងស្ថិតក្នុងកិច្ចប្រជុំចង្អៀត មុននឹងដាក់ចូលអន្តរក្រសួងពិនិត្យ និងពិភាក្សា។ យើងពិតជាមានការ

លំបាកក្នុងការតាក់តែងច្បាប់ស្តីពីអធិការកិច្ច ដោយសារកង្វះធនធាន បច្ចេកទេស និងការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធមួយចំនួន។ ខ្ញុំក៏សូមឆ្លៀតឱកាសនេះ សូមថ្លែងអំណរគុណដល់ក្រុមការងារតាក់តែងច្បាប់យើងដែលដឹកនាំដោយលោកជំទាវ **សុខ ទិន្នាយ**។

ទោះជាយើងទទួលបានជោគជ័យ ជាច្រើនក្នុងការងារក្តី ក៏ក្រសួងនៅមានការប្រឈមជាច្រើន ដូចជា៖ ទី១) នៅតាមស្ថាប័នរដ្ឋមួយចំនួនមិនទាន់ឱ្យតម្លៃការងារអធិការកិច្ច និងមិនចង់សហការ ដោយសារគេយល់ថា ក្រុមបេសកកម្មយើង ទៅរកចាប់កំហុសគេ ទី២) ក្រសួង ស្ថាប័នរដ្ឋមួយចំនួនមានការកិច្ចស្រដៀងគ្នា ឬជាន់គ្នា ដូចជាគណៈកម្មាធិការដោះស្រាយទំនាស់ដីធ្លី អង្គភាពប្រឆាំងអំពើពុករលួយ អាជ្ញាធរសេវនកម្មជាតិ អគ្គាធិការ តាមក្រសួង និងក្រសួង ស្ថាប័ន ដែលធ្វើឱ្យមានក្រុមបេសកកម្មច្រើនត្រួតគ្នា ដែលធ្វើឱ្យគេពិបាកទទួល និងខាតពេលវេលា ទី៣) ក្រសួងនៅខ្វះខាតធនធាន និងមធ្យោបាយធ្វើដំណើរ ដើម្បីបំពេញបេសកកម្ម ទី៤) សមាជិកក្រុមការងារចុះធ្វើបេសកកម្មខ្លះមិនបានអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈ ពេញលេញ នៅឡើយ ដោយអ្នកខ្លះបានឆ្លៀតឱកាសយកចំណេញដោយមានការលំអៀងខ្លះ ឬដោយមានការយោគយល់។ ទី ៥) ការងារអធិការកិច្ច ជាពិសេសការដោះស្រាយពាក្យបណ្តឹង គឺជាការងារដែលលំបាក ស្មុគស្មាញមានភាពរសើប និងភាពចំរូងចម្រាស់ច្រើន ដែលទាមទារការតស៊ូ សមត្ថភាព និងជំនាញច្បាស់លាស់ ពីបច្ចេកទេសអធិការកិច្ច និងសមត្ថភាពផ្នែកច្បាប់ ព្រមទាំងក្រមសីលធម៌របស់មន្ត្រី ឬភ្នាក់ងារអធិការកិច្ច។

ទោះជាមានការប្រឈមខ្លះយ៉ាងណាក្តី ក្រសួងបានអនុវត្តភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម ដោយទទួលខុសត្រូវក្នុងនាមរាជរដ្ឋាភិបាល ដែលបានប្រគល់បេសកកម្មឲ្យដឹកនាំ និងគ្រប់គ្រងរាល់កិច្ចការសម្របសម្រួល និងធ្វើទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងធ្វើការងារអធិការកិច្ច លើគ្រប់វិស័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការងារក្នុងវិស័យអធិការកិច្ច ជាចំបងរួមមាន៖ ការត្រួតពិនិត្យលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅតាមបណ្តាក្រសួង ស្ថាប័ននានា ការងារតាមដានការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងអនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាល សំដៅជួយកាត់បន្ថយបាតុភាពអសកម្មនានា និងការងារទទួលពាក្យបណ្តឹង ការងារអង្កេតស្រាវជ្រាវ ដើម្បីទប់ស្កាត់ការរំលោភដោយអំណាច និងរួមចំណែកប្រយុទ្ធប្រឆាំងអំពើពុករលួយ។ ក្រសួងបានចុះធ្វើការងារអធិការកិច្ច និងអង្កេតស្រាវជ្រាវ នៅតាមក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ និងបានធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច។

ក្រសួងសម្រេចបានលទ្ធផលជាច្រើន ក្នុងការងារអធិការកិច្ច ដូចជា៖ ការងារទទួលពាក្យបណ្តឹង (បណ្តឹងតវ៉ា និងបណ្តឹងបរិហារ) ការងារស៊ើបអង្កេតករណីបណ្តឹងពាក់ព័ន្ធទំនាស់ដីធ្លី ការងារសម្របសម្រួលបញ្ចប់ទំនាស់ពុំរ៉ៃ បានជាច្រើនករណី ការងារតាមដានការអនុវត្តច្បាប់ ការកែលម្អរចំណុចខ្វះខាតរបស់ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈ លើកិច្ចការរដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ ជម្រុញប្រសិទ្ធិភាព ផលិតភាព និងគុណភាពសេវាសាធារណៈ ដើម្បីបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរ។ លើសពីនេះក្រសួងក៏បានអប់រំ ណែនាំ បង្ការ ទប់ស្កាត់ និងកែលម្អរកំហុសឆ្គង ក្នុងការអនុវត្តការងាររបស់ក្រសួង-ស្ថាប័ន អង្គភាព គ្រឹះស្ថានសាធារណៈថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមួយចំនួន ដើម្បីកែលម្អរ និងលើកកម្ពស់អភិបាលកិច្ចល្អដែលជាស្នូល នៃយុទ្ធសាស្ត្រចតុកោណទាំងដំណាក់កាលទី១ ទី២ ទី៣ និងទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា។

ជារួម ក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចបានផ្សព្វផ្សាយការយល់ដឹង និង ការអប់រំដល់ប្រជាពលរដ្ឋ ឱ្យយល់ដឹងពីច្បាប់គោលមួយចំនួន ជួយពង្រឹងប្រសិទ្ធភាពការងាររបស់ស្ថាប័ន-អង្គភាពរដ្ឋ ធានាសុវត្ថិភាពសាធារណៈ និងសិទ្ធជូនប្រជាពលរដ្ឋ នាំមកនូវតម្លាភាព និងកាត់បន្ថយបាននូវបាតុភាពអសកម្មនានា ដូចជាការអនុវត្តមិនត្រឹមត្រូវ នៃច្បាប់ លិខិតបទដ្ឋានគតិយុត្ត និង កិច្ចសន្យារវាងក្រុមហ៊ុនឯកជនជាមួយរដ្ឋ ជួយកាត់បន្ថយ និងលុបបំបាត់ការកឹបកេងថវិកា និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋខុសទិសដៅ និងចូលរួមចំណែកក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី !**

ដោយផ្អែកតាមការពិភាក្សាក្នុងសន្និបាត និងដើម្បីឲ្យសម្រេចបាននូវគោលដៅដែលក្រសួងចង់បាន ខ្ញុំសូមស្នើ ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ត្រូវផ្តោតលើអនុសាសន៍ដូចខាងក្រោមនេះៈ

១. ដោយសារការផ្សព្វផ្សាយច្បាប់ ជាតម្រូវការចាំបាច់ ក្រុមការងារក្រសួងត្រូវបន្តយុទ្ធនាការអប់រំ និងផ្សព្វផ្សាយច្បាប់ឲ្យបានទូលំទូលាយគ្រប់២៥ រាជធានី-ខេត្ត ជាពិសេសទៅ តាមទីប្រជុំជន និង ជនបទដាច់ស្រយ៉ាល និងជម្រុញការងារសិក្សាស្ទាបស្ទង់មតិ (Survey) ដោយបណ្តុះបណ្តាលពី វិធីសាស្រ្ត នៃការសិក្សាស្ទាបស្ទង់ និងការវិភាគទិន្នន័យដល់មន្ត្រីដែលពាក់ព័ន្ធ ដើម្បីធ្វើរបាយការណ៍ នៃលទ្ធផលដែលរកឃើញពីការស្ទាបស្ទង់ទាំងនោះ។

២. ត្រូវខិតខំការពារ សេចក្តីព្រាងច្បាប់អធិការកិច្ច ដោយបន្តសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ពន្យល់ពីសារៈសំខាន់នៃការងារអធិការកិច្ច ដើម្បីការពារឱ្យបានជាអតិបរិមា នូវតួនាទី ភារកិច្ចស្នូលរបស់ក្រសួង ស្របតាមច្បាប់ដែលអនុញ្ញាត។

៣. ត្រូវអនុវត្តបន្តនូវកម្មវិធី ទទួលពាក្យបណ្តឹងអនឡាញ និងបណ្ណាល័យ អេឡិចត្រូនិក (e-Library) ដែលតាមរយៈកម្មវិធីទាំងនោះ ប្រជាពលរដ្ឋ អាចដាក់ពាក្យបណ្តឹង និងអាចមើលឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានាតាមកុំព្យូទ័រ និងទូរស័ព្ទដៃបានយ៉ាងងាយស្រួល។ ការអនុវត្តកម្មវិធីគឺជាការសម្រួលការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។

៤. ត្រូវពង្រឹងប្រសិទ្ធភាព ក្នុងបេសកកម្មចុះធ្វើអធិការកិច្ច ការអង្កេត ស្រាវជ្រាវពាក្យបណ្តឹង និង ការតាមដានការអនុវត្តច្បាប់ តាមរយៈការរកព័ត៌មានឲ្យមានតុល្យភាពច្បាស់លាស់ មានភស្តុតាង និង ឯកសារសំអាងគ្រប់គ្រាន់ទាំងអង្គហេតុ និងអង្គច្បាប់។ រាល់ពាក្យបណ្តឹងដែលបញ្ជូនទៅសមត្ថកិច្ចពាក់ព័ន្ធពិនិត្យដោះស្រាយ ត្រូវតាមដាន ស៊ើបសួរព័ត៌មានអំពីវឌ្ឍភាព នៃការដោះស្រាយឲ្យបានច្បាស់លាស់ និង ទាន់ពេលវេលា រួចជូនព័ត៌មានទៅដើមបណ្តឹងវិញ។ ទង្វើនេះបង្ហាញពីការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋ ដែលជាអ្នកផ្តល់សេវាជូនប្រជាពលរដ្ឋ។

៥. មន្ត្រីរាជការក្រសួង ជាពិសេសមន្ត្រី ឬភ្នាក់ងារអធិការកិច្ចត្រូវបន្តពង្រឹងសមត្ថភាពដើម្បីផ្តល់សេវាប្រកបដោយប្រសិទ្ធភាព ដើម្បីជំរុញវប្បធម៌តម្លាភាព និងគណនេយ្យភាព និងរៀបចំ និងអនុវត្ត យុទ្ធសាស្រ្ត អភិវឌ្ឍសមត្ថភាពឱ្យបានទូលំទូលាយ ដើម្បីធានានូវប្រសិទ្ធភាព នៃសេវាសាធារណៈឱ្យកាន់តែប្រសើរឡើង ។

៦. មន្ត្រីរាជការក្នុងក្រសួង និងមន្ទីរទាំងអស់ត្រូវស្វែងយល់អំពីច្បាប់ និងបទបញ្ញត្តិនានាដែលពាក់ព័ន្ធនឹងការងារស្នូលរបស់ក្រសួង ដើម្បីបង្កើនសមត្ថភាព និងមានលទ្ធភាព បកស្រាយ ពន្យល់ ពិភាក្សាវែកញែក ក្នុងការបំពេញភារកិច្ច ជាពិសេសក្នុងការងារអធិការកិច្ច ដោះស្រាយពាក្យបណ្ដឹង តាមដានការអនុវត្តច្បាប់និងផ្សព្វផ្សាយច្បាប់។

៧. វិទ្យាស្ថានជាតិអធិការកិច្ចត្រូវចំខឹមសារ កម្មវិធីបណ្តុះបណ្តាលថ្នាក់បឋម ថ្នាក់មធ្យម និងថ្នាក់ឧត្តម លើជំនាញអធិការកិច្ច និងជំនាញពាក់ព័ន្ធ។ វិទ្យាស្ថាន ក៏ត្រូវបណ្តុះបណ្តាលមុខជំនាញផ្សេងបន្ថែម ក្រៅពីអធិការកិច្ច ដូចជា ជំនាញអប់រំផ្សព្វផ្សាយច្បាប់ ជំនាញការសិក្សាស្រាវជ្រាវ ជំនាញវាយតម្លៃ ជំនាញផ្នែកស្ទាបស្ទង់មតិ និងជំនាញផ្សេងៗទៀត ដែលជាតម្រូវការចាំបាច់របស់ក្រសួង។

៨. ត្រូវបន្តធ្វើការកែទម្រង់ផ្ទៃក្នុងក្រសួងជាបណ្តើរៗ ដើម្បីអនុវត្តថវិកាតាមកម្មវិធី និងអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវធ្វើឲ្យបានហ្មត់ចត់ ច្បាស់លាស់ ជាពិសេសការប្រើប្រាស់កញ្ចប់ថវិកា ឱ្យមានប្រសិទ្ធភាព គណនេយ្យភាព និងសមស្របតាមបទដ្ឋានគតិយុត្ត។

៩. ក្នុងពេលបំពេញបេសកកម្មចុះធ្វើអធិការកិច្ច មន្ត្រី ឬភ្នាក់ងារអធិការកិច្ច ត្រូវគោរពឲ្យបានខ្ជាប់ខ្ជួន និងម៉ឺងម៉ាត់ នូវក្រមសីលធម៌មន្ត្រីរាជការអធិការកិច្ច ដែលបានដាក់ចេញរួចហើយ។ ត្រូវមានភាពទន់ភ្លន់តែម៉ឺងម៉ាត់ ដោយយកច្បាប់ជាធំ។ ត្រូវមានឯកសណ្ឋាន ដូចដែលក្រសួងបានណែនាំរួចហើយ និងត្រូវអនុវត្តឱ្យបានល្អ តាមអភិក្រមទាំងប្រាំ របស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** គឺ៖ “**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**” ដែលយើងត្រូវចងចាំជានិច្ច។

១០. ទោះជាមានស្ថាប័នច្រើន មានភារកិច្ចស្រដៀងគ្នា ឬត្រួតគ្នាក៏ដោយ យើងត្រូវតែពន្យល់ពីសារៈសំខាន់នៃការងារអធិការកិច្ច ដែលជាស្ថាប័នត្រួតពិនិត្យ ជម្រុញអភិបាលកិច្ចនិងប្រសិទ្ធភាពការងារ ដល់ស្ថាប័នផ្សេងៗទៀតឱ្យយល់ និងត្រូវកែទស្សនៈដែលខុសឆ្គងពី “**ការងារត្រួតគ្នា**” ទៅជា “**ការងារបំពេញបន្ថែមគ្នាទៅវិញទៅមក**” ដើម្បីរាជរដ្ឋាភិបាលតែមួយ។

ខ្ញុំពិតជាមានមោទនភាព និងសូមកោតសរសើរ វាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ ក៏ដូចជាមន្ត្រីរាជការ ក្រុមការងារនៃគណៈកម្មការរៀបចំសន្និបាត ដែលបានខិតខំបំពេញការងារយ៉ាងសកម្ម និងដោយស្មារតីទទួលខុសត្រូវខ្ពស់ធ្វើឱ្យសន្និបាតក្រសួងឆ្នាំនេះបានទទួលជោគជ័យគួរជាទីពេញចិត្ត។

ខ្ញុំក៏សូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងបណ្តាក្រសួង-ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ ដែលបានខិតខំរួមចំណែក ក្នុងកិច្ចសហការជាមួយក្រសួង ដើម្បីបំពេញការងារជូនរាជរដ្ឋាភិបាល និងបំរើប្រជាជន លើវិស័យទំនាក់ទំនង សម្របសម្រួលជាមួយរដ្ឋសភា ព្រឹទ្ធសភា ការងារផ្សព្វផ្សាយច្បាប់ ការងារអធិការកិច្ច ការទទួល និងដោះស្រាយបណ្ដឹងនានា ដើម្បីរួមចំណែកពង្រឹងអភិបាលកិច្ចល្អ ដែលជាឧត្តមប្រយោជន៍របស់សង្គមជាតិទាំងមូល។

មុននឹងបញ្ចប់ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមអបអរសាទរចំពោះលទ្ធផលដែលអង្គសន្និបាតសម្រេចបានក្នុងរយៈពេលពេញមួយថ្ងៃនេះ និងជឿជាក់យ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់នឹងបន្តអនុវត្តភារកិច្ចតាមតួនាទីរៀងៗខ្លួន ដោយយកចិត្តទុកដាក់ខ្ពស់ បង្កើតនូវសមិទ្ធផលថ្មីៗថែមទៀត ជូនរាជរដ្ឋាភិបាលដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍របស់ជាតិ។

ខ្ញុំសូមជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ជាទីបញ្ចប់ ខ្ញុំសូមប្រកាសបិទសន្និបាត ក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ឆ្នាំ២០១៩-២០២០ចាប់ពីពេលនេះតទៅ។

*សូមអរគុណ !*